**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សន្តិកម្មតាមមរតកសាសន៍នៅកម្ពុជា

(ស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២៤ ដល់ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០២៤)

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ឃីម ពន្លឺ**

**កញ្ញា គង់ ច័ន្ទម៉ូនីនាថ**

ណែនាំដោយ

លោក **យស បានចំរ៉ុង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឃឹម ពន្លឺ** និង**គង់ ច័ន្ទមុំនីនាថ** ជានិស្សិតត្រូវបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២៤ នាពេលខាងមុខ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០២០-២០២៤។

ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ អនុញ្ញាតឲ្យយើងខ្ញុំ សូមធ្វើការសម្តែងនូវកតញ្ញូ កតវេទី ចំពោះលោកអ្នកដែលមានរាយនាមដូចខាងក្រោម៖

**មាតាបិតាទាំងទ្វេ** កូនសូមសម្តែងនូវមហាកតញ្ញូតាធម៌ជាអនេកប្បការ ដែលលោកបានផ្តល់កំណើតដល់រូបកូន ព្រមទាំងប្រឹងប្រែងគ្រប់បែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាការពារ អប់រំទូន្មាន ប្រៀបប្រដៅរូបកូនប្រកបដោយទឹកចិត្តព្រហ្មវិហារធម៌ទាំងបួន។ ជាងនេះទៅទៀតលោកអ្នកដ៏មានគុណទាំងទ្វេ បានពុះពារប្រឈមមុខរាល់ទុកលំបាកគ្រប់បែបយ៉ាង ដើម្បីឲ្យកូនទទួលបានការសិក្សារៀនសូត្ររហូតដល់បានបញ្ចប់ថ្នាក់ឧត្តមសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច** ជាគ្រឹះស្ថានភាពសិក្សាដែលមិនត្រឹមតែផ្តល់នូវសាស្ត្រាចារ្យល្អៗ មានជំនាញក្នុងការផ្ទេរចំណេះដឹងពិតប្រាកដដល់ពួកយើងប៉ុណ្ណោះទេ ថែមជាកន្លែងជួយហាត់ពត់ លត់ដំ ឥរិយាបថមាយាទ អប់រំស្មារតីឲ្យបណ្តុះខ្លួនក្លាយជាពលរដ្ឋល្អ ជាទំពាំងស្នងឬស្សីដែលប្រទេសជាតិមិនអាចខ្វះបាន។

**លោក លោកស្រីសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច ដែលបានចូលរួមរៀបចំ យកចិត្តទុកដាក់ក្នុងការបង្រៀន ដោយមិនខ្លាចនឿយហត់ និងជំរុញផ្នែកស្មារតី ឲ្យយើងខ្ញុំខិតខំរៀនសូត្រ ក្រេបជញ្ជក់យកចំណេះវិជ្ជា។

ជាពិសេសជាងនេះទៅទៀត សូមធ្វើថ្លែងអំណរគុណជូនចំពោះលោកសាស្ត្រាចារ្យ **យស បានចំរ៉ុង** ជាអ្នកដឹកនាំសារណា ដែលបានជួយគាំទ្រយើងខ្ញុំយ៉ាងពេញទំហឹង ជាប្រទីបបំភ្លឺ តម្រង់ទិសជួយឲ្យយើងខ្ញុំមានវិធីសាស្ត្រកាន់តែច្បាស់លាស់ ធ្វើឲ្យកិច្ចការសារណានេះ លេចចេញជារូបរាងឡើង។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យសេរីបវរជូនដល់លោកអ្នកដ៏មានគុណ ឯឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ សូមប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាន នូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សូមស្វាគមន៍ និងជម្រាបសួរទៅដល់មិត្តៗនិស្សិត ប្រិយមិត្តអ្នកស្រាវជ្រាវ និងអ្នកដែលចង់ស្វែងយល់នូវប្រធានបទ ក៏ដូចជាឯកសារជំនួយស្មារតីជាទីរាប់អាន។ ក្រោយពេលដែលយើងខ្ញុំបានសិក្សាអស់រយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកនីតិសាស្រ្តរួចមក ធ្វើឲ្យយើងខ្ញុំបានទទួលចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនពី ថ្នាក់ដឹកនាំ និងសាស្រ្តាចារ្យ។ ហើយនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន យើងជាក់ស្តែងមានការអនុវត្តច្រើនដែលទាក់ទង ការធ្វើនៅ " **សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា** " ម្យ៉ាងទៀត វាមានការលំបាកយ៉ាងខ្លាំងនៅក្នុងស្វែងយល់អំពីនីតិវិធីនេះ ដែលតម្រូវឲ្យមានការសិក្សាស្វែងយល់ និងស្រាវជ្រាវបន្ថែមទៀតដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន។

ហេតុដែលរុញឱ្យយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទនេះមកធ្វើការរៀបរៀង និងចងក្រងឡើង ដោយខ្ញុំធ្លាប់បានសិក្សាមេរៀនពាក់ព័ន្ធទៅនឹងប្រធានបទមួយនេះពីមុនមក និងមើលឃើញពីចំណុចខ្វះខាត ក៏ដូចជាមន្ទិលសង្ស័យ ឬភាពមិនច្បាស់លាស់មួយចំនួន ទើបយើងខ្ញុំមានការចាប់អារម្មណ៍ចង់សិក្សាស្វែងយល់ ជាពិសេសសង្ឃឹមថានៅក្រោយពេលបានចងក្រង និងស្រាវជ្រាវទៅលើប្រធានបទនេះហើយនឹងបានរកឃើញនូវចំណុចដែលត្រូវបំពេញបន្ថែម ក៏ដូចជាចូលរួមចំណែកលើកជាយោបល់ និងសំណូមពរមួយចំនួនពាក់ព័ន្ធទេទៅនឹងប្រធានបទស្តីពី សន្តតិកម្មតាមមតកសាសន៍នេះ។ លើសពីនេះ យើងខ្ញុំក៏សង្កេតឃើញថាវាជាកម្មវត្ថុ ក៏ដូចជា បញ្ហាចម្បងមួយផ្តោតលើគ្រួសារនៅកម្ពុជា ឬបុគ្គលគ្រប់រូបដែលមានបំណងធ្វើការបែងចែកមត៌កពីសំណាក់បុគ្គលដែលជាម្ចាស់ទ្រព្យតាមឆន្ទៈផ្ទាល់ មុនពេលដែលម្ចាស់ទ្រព្យបានទទួលមរណភាព។

យើងខ្ញុំទាំងពីរនាក់ សូមទទួលយកនូវការរិះគន់ក្នុងនៃស្ថាបនាពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសខុសឆ្គងទាំងឡាយដែលកើតឡើងដោយអចេតនាណាមួយក្តី ឬពាក្យពេចន៍ ឃ្លា វេយ្យាករណ៍ អក្ខរក្រម ដើម្បីជួយកែលំអរកាន់តែល្អ ក៏ដូចជាខ្លឹមសារផ្សេងៗ និងមានភាពសុក្រឹតភាព។

ជាចុងក្រោយយើងខ្ញុំសូមលើកដៃប្រណម្យដោយក្តីគោរពជូនពរ លោក/លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ជួបតែសំណាងល្អ សុភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ចទាំងអស់ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍកម្ពុជាឆ្ពោះទៅរកភាពរីកចម្រើនជាលំដាប់។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ........ ១

## ជំពូកទី១
## សញ្ញាណទូទៅនៃសន្តតិកម្ម

**១.១.ការចាប់ផ្ដើមសន្តតិកម្ម** ........ ៤

**១.២.ប្រភេទនៃសន្តតិកម្ម** ........ ៥

១.២.១.សន្តតិកម្មតាមច្បាប់ ........ ៥

១.២.១.១.សន្តតិកម្មតាមលំដាប់៣ ........ ៦

១.២.១.២.សន្តតិកម្មរបស់សហព័ទ្ធ ........ ៧

១.២.១.៣.សន្តតិកម្មជំនួស ........ ១០

១.២.២.សន្តតិកម្មមានបណ្ដាំ(មតកសាសន៍) ........ ១១

**១.៣.អានុភាពនៃសន្តតិកម្ម** ........ ១២

## ជំពូកទី២
## ការបង្កើតមតកសាសន៍

**២.១.លក្ខខណ្ឌគ្រឹះនៃការបង្កើតមតកសាសន៍** ........ ១៥

២.១.១.សមត្ថភាពរបស់មតកជន ........ ១៥

២.១.១.១.បុគ្គលជានីតិជន ........ ១៦

២.១.១.២.ជននៅក្រោមអាក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ ........ ១៦

២.១.១.៣.បុគ្គលជាអនីតិជនដែលទទួលបានអត្តាធីនភាព ........ ១៧

២.១.២.ការបង្ហាញឆន្ទៈរបស់មតកជន ........ ១៨

២.១.២.១.ការភាន់ច្រឡំ ........ ១៨

២.១.២.២.ការឆបោក ........ ១៩

២.១.២.៣.ការគំរាមគំហែង ........ ១៩

២.១.២.៤.ព័ត៌មានមិនពិត ........ ១៩

២.១.២.៥.ការរំលោភបំពានលើស្ថានភាពពិត ........ ១៩

២.១.៣.កម្មវត្ថុនៃមតកសាសន៍ .......... ២០
២.១.៣.១.សិទ្ធិប្រត្រក្ស.......... ២០
២.១.៣.២.សិទ្ធិតទេយ្យ .......... ២០
២.១.៣.៣.សិទ្ធិខាងបញ្ញា .......... ២០
**២.២.លក្ខខណ្ឌទម្រង់នៃមតកសាសន៍** .......... ២០
២.២.១.ទម្រង់នៃមតកសាសន៍.......... ២១
២.២.១.១.សាក្សី.......... ២១
២.២.១.២.ប្រភេទនៃមតកសាសន៍.......... ២២
ក.មតកសាសន៍ដោយលិខិតយថាភូត .......... ២២
ខ.មតកសាសនដោយលិខិតឯកជន.......... ២៣
គ.មតកសាសន៍ដោយលិខិតសម្ងាត់.......... ២៣
ឃ.មតកសាសន៍ក្នុងស្ថានភាពពិសេស .......... ២៤
ឃ.១.មតកសាសន៍នៃជននៅក្រោមអាណាព្យាលទូទៅ.......... ២៤
ឃ.២.មតកសាសន៍ក្នុងស្ថានភាពពិសេស.......... ២៥
ឃ.៣.មតកសាសន៍នៃជននៅក្រោមអាណាព្យាលទូទៅ .......... ២៦
ឃ.៤.មតកសាសន៍ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត.......... ២៦
ឃ.៥.មតកសាសន៍ជនដែលត្រូវជាប់ឃុំឃាំង និងជនជាប់ក្នុងនាវា ឬ យន្តហោះ .......... ២៨
ឃ.៦.មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ.......... ២៨
ឃ.៧.មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស .......... ២៩
២.២.២.ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ .......... ៣០
២.២.២.១.កាលបរិច្ឆេត និងហត្ថលេខា.......... ៣១
២.២.២.២.ចំណុចសំខាន់ផ្សេងទៀតដែលតម្រូវដោយច្បាប់.......... ៣១
ក.ចំណុចនៃមតកសាសន៍ .......... ៣១
ខ.ការកំណត់ចំណែកមត៌ក .......... ៣១
គ.ចំណុចនៃមតកសាសន៍ .......... ៣២
ឃ.អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន.......... ៣៣
ង.កំណត់នូវអ្នកប្រតិបត្តិមតកសាសន៍.......... ៣៣

# ជំពូកទី៣
# អានុភាពនៃមតកសាសន៍


ក.អានុភាពនៃការកំណត់ចំណែកមត៌ក.......................................................................................៣៤
ខ.ការកំណត់ចំណែកមត៌កករណីសន្តតិជនទទួលមរណភាពជាអាទិ៍..............................................៣៤
គ. អានុភាពចំពោះអាណាព្យាបាលទូទៅ.....................................................................................៣៥
**៣.១.ការយល់ព្រម និងបោះបង់សន្តតិកម្ម**...................................................................................៣៦
៣.១.១.លក្ខខណ្ឌនៃការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់មតកសាសន៍.......................................៣៦
៣.១.២.អំឡុងពេលនៃការយល់ព្រម ឬ បោះបង់មតកសាសន៍......................................................៣៦
៣.១.៣.១.ការយល់ព្រមទាំងស្រុង.............................................................................................៣៨
៣.១.៣.២.យល់ព្រមដោយមានកម្រិត.........................................................................................៣៩
៣.១.៣.៣.ការបោះបង់សន្តតិកម្ម ..............................................................................................៤១
**៣.២.ការប្រតិបត្តិមតកសាសន៍**...........................................................................................៤១
៣.២.១.មូលហេតុបង្កើតឱ្យមានអ្នកប្រតិបត្តិ.............................................................................៤១
៣.២.២.ការជ្រើសតាំងអ្នកប្រតិបត្តិ..........................................................................................៤១
៣.២.៣.ការលាឈប់ និង ការបញ្ឈប់ តួនាទីអ្នកប្រតិបត្តិ...............................................................៤២
៣.២.៤.ការកាន់កាប់មុខងារជាអ្នកប្រតិបត្តិ និង អានុភាព ..............................................................៤១
៣.២.៥.សិទ្ធិ និង តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍.................................................................៤៣
៣.២.៦.កាតព្វកិច្ចអ្នកប្រតិបត្តិ ................................................................................................៤៥
៣.២.៧.បន្ទុកនៃមត៌ក ..........................................................................................................៤៥
**៣.៣.ការសម្រួលចំណែកមត៌ក**.............................................................................................៤៦
៣.៣.១.ផលប្រយោជន៍ពិសេស ...............................................................................................៤៦
៣.៣.១.១.ផលប្រយោជន៍ពិសេសមានតម្លៃតិចជាងចំណែកមត៌ក .............................៤៧
៣.៣.១.២.ផលប្រយោជន៍ពិសេសមានតម្លៃស្មើនឹងចំណែកមត៌ក .............................៤៧
៣.៣.១.៣.ផលប្រយោជន៍ពិសេសមានតម្លៃលើពីចំណែកមត៌ក...............................៤៨
៣.៣.១.៤.ភាគនៃវិភាគទាន.........................................................................................៤៨
៣.៣.១.៥.ប្រទានកម្ម .........................................................................................................៥១

ក.ស្ថានភាពពិសេស ......................................................................................................... ៥២
ខ.នត្ថិភាពនៃសន្តតិជន........................................................................................................... ៥២
ខ.១.នីតិបុគ្គលមត៌ក......................................................................................................... ៥២
ខ.២.ចំណែកចំពោះជនដែលមាននិស្ស័យពិសេស ........................................................................ ៥៤
ខ.៣.មត៌កដែលក្លាយជារបស់រដ្ឋ............................................................................................ ៥៤
គ.ការធ្វើបដិទានកម្មនៃសន្តតិកម្ម.......................................................................................... ៥៤
៣.៣.២.ភាគបម្រុង............................................................................................................. ៥៦
៣.៣.២.១.និយមន័យ.......................................................................................................... ៥៦
៣.៣.២.២.អ្នកដែលមានសិទ្ធិលើភាគបម្រុង.................................................................................. ៥៧
៣.៣.២.៣.លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង .................................................................. ៥៧
៣.៣.២.៤.ចំណែកនៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗ ....................................................................... ៥៨
៣.៣.២.៥.ការកាត់បន្ថយភាគបម្រុង ........................................................................................... ៥៩
៣.៣.២.៦.ការសងផលមកវិញចំពោះបុគ្គលមានសិទ្ធិលើភាគបម្រុង ..................................................... ៦១
៣.៣.២.៧.ការរលត់សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ..................................................... ៦២
ក.អាជ្ញាយុកាល ................................................................................................................ ៦២
ខ.ការបោះបង់ភាគបម្រុង ...................................................................................................... ៦៣
**សេចក្ដីសន្និដ្ឋាន** ............................................................................................................ ៦៤
**អនុសាសន៍** ................................................................................................................... ៦៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ទ្រព្យសម្បត្តិ គឺជាផ្នែកមួយយ៉ាងសំខាន់បំផុតរបស់បុគ្គលម្នាក់ៗក្នុងការរស់នៅជីវភាពប្រចាំថ្ងៃ។ ជាទូទៅមជ្ឈដ្ឋានភាពច្រើន អាចស្គាល់កេរអាករពីដូនតាដែលបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយ ប៉ុន្តែពួកគាត់មិនស្គាល់កេរអាករនោះថាជាអ្វីពិតប្រាកដទេ។ ជាក់ស្តែងពាក្យថាកេរអាករនៅក្នុងការសិក្សាច្បាប់ គេប្រើពាក្យមត៌ក ហើយមត៌កនោះសំដៅទៅលើទ្រព្យសម្បត្តិរបស់ជនដែលទទួលមរណភាព។ ទំនាក់ទំនងសិទ្ធិ និងទ្រព្យសម្បត្តិរបស់បុគ្គលកំពុងនៅមានជីវិតគេហៅថា (កម្មសិទ្ធិ) ចំណែកឯ ទ្រព្យរបស់បុគ្គលដែលបានបាត់បង់អាយុជីវិតទៅហើយ ត្រូវបានប្រែក្លាយពីកម្មសិទ្ធិនោះមកជាមត៌កវិញ។ ការផ្លាស់ប្តូរ ឬការផ្ទេរកម្មសិទ្ធិ រវាងមនុស្សនៅរស់ មកឱ្យមនុស្សរស់នៅ ត្រូវធ្វើតាមរយៈអច្ច័យទាន ឬ សន្តតិកម្ម។ ម៉្យាងវិញទៀត នៅលើពិភពលោករបបសន្តិកម្ម មានគោលការណ៍ពីរប្រភេទចម្បងៗ គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិនឹងគោលការណ៍ជម្រះបញ្ជី។ មានន័យថា សន្តតិជនត្រូវទទួលស្នងមត៌កតែម្តង មុននឹងធ្វើការបែងចែក ឬសងបំណុល ដោយសន្តតិជនមានសិទ្ធិទទួលយកទាំងស្រុង ឬទទួលយកដោយមានកម្រិត ឬលះបង់សន្តតិកម្ម។ ដោយឡែកគោលការណ៍ជម្រះបញ្ជី គឺជាការជម្រះសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ហើយសន្តតិជនអាចស្នងមត៌កបាន តែក្នុងករណី នៅសល់ទ្រព្យសកម្មប៉ុណ្ណោះ និងប្រសិនបើកាតព្វកិច្ចធ្ងន់ធ្ងរ ត្រូវប្រកាសក្ស័យធន។

ពាក្យសន្តតិកម្មក្នុងន័យគតិយុត្តដែលមកពីពាក្យថា ការផ្ទេរ មានន័យថាជាការផ្ទេរនូវសិទ្ធិ និងការណីកិច្ចរបស់មតកជន (អ្នកស្លាប់) ទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ ម៉្យាងវិញទៀត ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិទាក់ទងនឹងសន្តតិកម្មមាន ២(ពីរ) ប្រភេទ គឺសន្តតិកម្មត្រឹមត្រូវតាមច្បាប់ និងសន្តិកម្មតាមបណ្តាំ (មតកសាសន៍) ហើយច្បាប់បានកំណត់នីតិវិធី ក៏ដូចជាដំណើរការយ៉ាងត្រឹមត្រូវ និងច្បាស់លាស់នៅក្នុងការធ្វើសន្តតិកម្មទាំងពីរប្រភេទនេះ។ តាមច្បាប់កម្ពុជាសព្វថ្ងៃ ចំពោះរបបសន្តតិកម្មតាមរយៈមតក៌សាសន៍ ឬបណ្តាំ ក្រមរដ្ឋប្បវេណីបានកំណត់ថាជាសកម្មភាពឯកតោភាគី ដែលត្រូវធ្វើឡើងតាមរយៈទម្រង់កំណត់ដោយច្បាប់ គឺទម្រង់មតកសាសន៍ ជាលិខិតឯកជន ទម្រង់មតកសាសន៍ ដោយលិខិតសម្ងាត់ និងទម្រង់មតកសាសន៍ជាលិខិតយថាភូត។ ការធ្វើសន្តតិកម្មនេះ មិនថាសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍ គឺត្រូវធ្វើឡើងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីទើបនាំឱ្យការធ្វើសន្តតិកម្មនោះ មានសុពលភាព និងអានុភាព។ ដោយប្រធានបទយើងខ្ញុំបានជ្រើសរើស សន្តតិកម្មតាមមតកសាសន៍ មកធ្វើការសិក្សា និងបកស្រាយដោយមានការនិយាយអំពីសញ្ញាណទូទៅ ពាក់ព័ន្ធនឹងសន្តតិកម្មតាមច្បាប់បន្តិចបន្តួច តែប្រធានបទរបស់យើងផ្តោតទៅលើ សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាប៉ុណ្ណោះ។ ហេតុនេះតាមរយៈចង្អុលបង្ហាញ ក៏ដូចជាការជ្រោមជ្រែង និងលើកទឹកចិត្តពីសំណាក់សាស្រ្តាចារ្យណែនាំ ក្នុងនាមជានិស្សិត

នីតិសាស្ត្រ និងប្រជាពលរដ្ឋកម្ពុជាមួយរូប បានសម្រេចលើកយកប្រធានបទ " សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា" នេះមកធ្វើការបកស្រាយ ដើម្បីឱ្យនិស្សិតកំពុងសិក្សា និងនិស្សិតជំនាន់ក្រោយៗទៀតក៏ ដូចជាប្រជាពលរដ្ឋទូទៅបានយល់ពីបញ្ហាសន្តតិកម្មមតកសាសន៍នៅព្រះរាជាណាចក្រកម្ពុជាកាន់តែច្បាស់ និងយល់អំពីការតាក់តែងលិខិតមតកសាសន៍ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដ៏ដូចជាអានុភាពក្រោយពេលម្ចាស់បណ្តាំទទួលមរណភាពចៀសវាង នៅពេលមតកជនបានទទួលមរណភាពហើយ បែរជាបណ្តាំនោះគ្មានអានុភាពទៅវិញ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ផ្អែកទៅតាមការរៀបចំខ្លឹមសារខ្លះៗខាងលើនេះ យើងបានដឹងហើយថាអ្វីនៅជាសន្តតិកម្មដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ហើយសន្តតិកម្មនេះទៀតសោតមានពីរប្រភេទ។ ប៉ុន្តែអ្វីដែលយើងគួរដឹង និងស្វែងយល់ដូចម្តេចខ្លះ? លើសពីនេះ តើមានលក្ខខណ្ឌចែកកំណត់ក្នុងច្បាប់អ្វីខ្លះដែលរាល់ការធ្វើសន្តតិកម្មតាមមតកសាសន៍តាមទម្រង់នេះប្រព្រឹត្តទៅបាន និងមានអានុភាព ដោយគោរពតាមទៅតាមប្បញ្ញត្តិទម្រង់ខាងលើនេះ សន្តតិជនម្នាក់ៗមានសិទ្ធិលើអ្វីខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និងការរៀបចំតាក់តែងនេះធ្វើឡើងក្នុងគោលបំណងចែករំលែកនូវចំណេះដឹងជាមូលដ្ឋាន ដ៏ដូចជាពុទ្ធិក្នុងការត្រិះរិះពិចារណាទៅលើបញ្ហាពាក់ព័ន្ធនៃការបែងចែកមរតក និងកាស្វែងយល់បន្ថែមក្រោយពេលបុគ្គលណាម្នាក់បានទទួលមរណភាព ឬមុនពេលទទួលមរណភាពក្នុងការបង្ហាញឆន្ទៈចុងក្រោយរបស់មតកជន។ ជាពិសេសប្រធានបទមួយនេះពិតជាមានសារៈសំខាន់ដែលបុគ្គលម្នាក់ៗ ឬប្រជាពលរដ្ឋ ក៏ដូចជានិស្សិតក្នុងការស្វែងយល់បន្ថែមក្នុងការបង្កើតចំណេះដឹង។ ម៉្យាងវិញទៀត យើងខ្ញុំចង់ធ្វើយ៉ាងណាក្រោយពេលដែលម្ចាស់បណ្តាំបានធ្វើការផ្ទេរមត៌កទៅតាមលិខិតបណ្តាំ ដោយឆន្ទៈពិតប្រាដករបស់គាត់មានអានុភាពចៀសវាងនៅពេលធ្វើលិខិតមតកសាសន៍នោះ ដោយខុសទម្រង់ ឬបែបបទ នីតិវីធី និងច្បាប់ដែលឈានទៅរកមតកសាសន៍ដែលធ្វើឡើងនោះត្រូវបានលុបចោល និងមិនមានអានុភាព។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះប្រធានបទដែលយើងខ្ញុំបានលើកមកសិក្សាស្រាវជ្រាវនេះ គឺយើងបានចងក្រង ក៏ដូចជាស្រាវជ្រាវផ្តោតសំខាន់ទៅលើក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ រហូតដល់បច្ចុប្បន្នតែប៉ុណ្ណោះ។ ហើយចំណុចសំខាន់មួយដែលយើងខ្ញុំយកមករៀបចំចងក្រងឡើងនោះមានដូចជា៖

- ស្វែងយល់អំពីសញ្ញាណនៃរបបសន្តតិកម្ម
- សញ្ញាណទូទៅនៃសន្តតិកម្មតាមបណ្តាំ (មតកសាសន៍)
- ស្វែងយល់អំពីអានុភាព ក៏ដូចជាសុពលភាពនៃការធ្វើសន្តតិកម្មតាមមតកសាសន៍

- ស្វែងអំពីគោលការណ៍ទូទៅនៃរបបភាគបម្រុង និងការទាមទារភាគបម្រុង

## ៥.សារសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ ក៏ដូចជាការចងក្រងប្រធានបទអ្វីមួយ យើងទាំងពីរអ្នកបានចំណាយពេលជាច្រើនទាំងកម្លាំងកាយ និងកម្លាំងចិត្ត ជាពិសេសការខិតខំព្យាយាម ជម្នះគ្រប់ឧបសគ្គទើបការសិក្សាស្រាវជ្រាវមួយនេះទទួលបានជោគជ័យ។ ជាប្រធានបទដែលខ្ញុំបានលើកឡើងនេះ គឺពិតជាមានសារសំខាន់សម្រាប់យើងខ្ញុំ ក៏ដូចជានិស្សិតទាំងអស់ដូចជា៖

- ទទួលបានចំណេះដឹងពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ
- ទទួលបានឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ
- ស្វែងយល់ ក៏ដូចជាយល់ដឹងកាន់តែលម្អិតទៅលើប្រធានបទដែលបានលើកយកមកស្រាវជ្រាវ
- ជាពិសេសបានបន្សល់ទុកស្នាដៃមួយនេះសម្រាប់សិស្សនិស្សិត ក៏ដូចជាបណ្ដាអ្នកសិក្សាស្រាវជ្រាវទាំងឡាយធ្វើជាមូលដ្ឋានក្នុងការស្វែងយល់ និងទទួលបានចំណេះដឹងបន្ថែម។

## ៦.វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ចំណែកឯវិធីសាស្ត្រក្នុងការស្រាវជ្រាវវិញ យើងខ្ញុំទាំងពីរនាក់បានខិតខំប្រើប្រាស់នូវចំណេះជំនាញ ក៏ដូចជាវិធីសាស្ត្រ ទេពកោសល្យមកធ្វើការចងក្រង និងរៀបចំសារណានេះឡើង ដោយបានដកស្រង់ចេញពីក្រមរដ្ឋប្បវេណី អត្ថបទខ្លឹមសារសំខាន់ៗចេញលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងសៀវភៅរបាយការណ៍នៅតាមបណ្ណាល័យធ្វើការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត ព្រមទាំងឯកសារសិស្សច្បងមួយចំនួនផងដែរ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទនៃសារណាដែលយើងធ្វើនេះ គឺបានបកស្រាយដោយផ្អែកទៅលើក្រមរដ្ឋប្បវេណី សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ឯកសារបទដ្ឋានគតិយុត្តជាច្រើន សៀវភៅរបស់សាស្ត្រាចារ្យ អ្នកនិពន្ធ និងការអនុវត្តជាក់ស្តែងព្រមទាំងគោលការណ៍ដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពី ការធ្វើសន្តតិកម្មតាមមតកសាសន៍ ក្នុងនោះយើងខ្ញុំបានបែងចែក ៣ជំពូកធំៗដូចជា៖

**ជំពូកទី១. សញ្ញាណទូទៅនៃសន្តតិកម្ម**

**ជំពូកទី២. ការបង្កើតមតកសាសន៍**

**ជំពូកទី៣. អានុភាពនៃមតកសាសន៍**

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្តតិកម្ម

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្តតិកម្ម

## ១.១.ការចាប់ផ្តើមសន្តតិកម្ម

ជាក់ស្តែង របបសន្តតិកម្មត្រូវបានបែងចែកជា ២ ប្រភេទ ដែលមានដូចជាគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្ត និងគោលការណ៍ជម្រះបញ្ជី។[1] ក្រមរដ្ឋប្បវេណីនៃច្បាប់ទីប និងក្រមរដ្ឋប្បវេណីជប៉ុន ទៀតសោតបានប្រើប្រាស់ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមកធ្វើជាមូលដ្ឋាន ក្នុងការតាក់តែងជា បទប្បញ្ញត្តិច្បាប់។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាសព្វថ្ងៃស្ថិតនៅក្រោមរបបសន្តតិកម្មដែលគោរព ទៅតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ដោយយោងទៅតាមខ្លឹមសារនៃបទប្បញ្ញត្តិច្បាប់។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនអាចទទួលទាំងស្រុងនូវសិទ្ធិ និងករណីកិច្ចដែលនៅសល់ពីមតកជនដែលជាអ្នកបានទទួលមរណភាព ហើយមត៌កត្រូវបានបែងចែកក្នុងករណីមានសហសន្តតិជនច្រើននាក់។ ក្នុងករណីដែល កាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុពេក ដែលអាចផ្តល់ផលវិបាកដល់សន្តតិជនដែលត្រូវស្នង នោះសន្តតិជនអាចបោះបង់សន្តិកម្ម ឬយល់ព្រមដោយមានកម្រិត ដើម្បីសម្រួលដល់សន្តតិជនត្រូវស្នងកាតព្វកិច្ចដែលនៅសេសសល់។ រីឯគោលការណ៍ជម្រះបញ្ជី គឺជាគោលការណ៍ដែលត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិបំណុល និងកាតព្វកិច្ចរបស់មតកជនពេលដែលសន្តតិកម្មកើតមានឡើង។ សន្តតិជនវិញត្រូវស្នងត្រឹមទ្រព្យនោះតែក្នុងករណីដែលមានទ្រព្យសកម្មតែប៉ុណ្ណោះ។ ក្នុងករណីដែលកាតព្វកិច្ច ធ្ងន់ធ្ងរហួសហេតុពេកដែលអាចផ្តល់ផលពិបាកដល់សន្តតិជនដែលត្រូវស្នង នោះសន្តតិជនត្រូវប្រកាសឲ្យមានក្ស័យធននៃមតកនោះ ដើម្បី កុំឲ្យសន្តតិជនទទួលនូវបន្ទុកកាតព្វកិច្ចធ្ងន់ធ្ងរនោះ។[2]

សន្តតិកម្ម ជារួមត្រូវបានផ្តល់ជានិយមន័យថា ជាការធ្វើលទ្ធកម្មទ្រព្យពីមតកជនដែលបានទទួលមរណភាព ទៅដល់សន្តតិជន។ យោងតាម សទ្ទានុក្រមផ្នែករដ្ឋប្បវេណី " សន្តតិកម្ម (Succession) " គឺជាការផ្ទេរនូវ សិទ្ធិ និងករណីយកិច្ច របស់មតកជនទៅឱ្យសន្តតិជន (Successor) ម្នាក់ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។[3] ដោយផ្អែកតាមនិយមន័យខាងលើ យើងអាចរែកញែកបានថា សន្តតិកម្មអាចធ្វើឡើងតាមច្បាប់ ដោយបញ្ញត្តិសម្រាប់ ការបែងចែកនោះនៅក្នុងក្រមរដ្ឋប្បវេណី និងតាមឆន្ទៈមតកជនដែលបែងចែកមត៌កនោះ។ បន្ថែម

---

[1]“សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរប្បវេណី ភាគ៦ : គន្ថីទី៨ - ទី៩”, ២០១០, ទំព័រ ១

[2] “សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ : គន្ថីទី៨ - ទី៩”, ២០១០, ២០១០ ទំព័រ ១

[3] សទ្ទានុក្រមផ្នែករប្បវេណី, លរ ១៤៣

ពីនេះ ការផ្ទេរកម្មសិទ្ធិពីមតកជនដែលទទួលមរណភាពមកឱ្យមនុស្សនៅរស់សន្តតិជន គឺជាការផ្ទេរនូវបេតិកភណ្ឌ សិទ្ធិ និងករណីយកិច្ចទ្រព្យសម្បត្តិ និងបំណុលទាំងឡាយដែលនៅសេសសល់។ ប៉ុន្តែសិទ្ធិ និងកាតព្វកិច្ច ណាដែលមានលក្ខណៈផ្ដាច់មុខ គឺមិនអាចក្លាយជាកម្មវត្ថុនៃសន្តតិកម្មបានឡើយ។ អាស្រ័យហេតុនេះ ការធ្វើយន្តការ សន្តតិកម្មនេះ គឺអាចធ្វើក្រោម ២ ទម្រង់ ដែលរួមមាន សន្តតិកម្មតាមច្បាប់ និងមតកសាសន៍(តាមឆន្ទៈ)។

សន្តតិកម្មដែលផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្ដាំ ឬ សន្តតិកម្មតាមមតកសាសន៍ ដែលត្រូវបានគេនិយមប្រើប្រាស់ច្រើនក្នុងបរិបទច្បាប់។ ក្នុងករណីមតកជនធ្វើបណ្ដាំដែលជា ទម្រង់របស់សន្តតិកម្មតាមមតកសាសន៍ នោះច្បាប់ត្រូវផ្ដល់អាទិភាពដល់ឆន្ទៈមតកជន ដែលជាម្ចាស់ទ្រព្យបានធ្វើនៅមុនពេលស្លាប់ និងអនុវត្តតាមខ្លឹមសារដែលមានចែងក្នុងលិខិតបណ្ដាំនោះ។ ក្នុងករណីដែលមតកជនមិនបានគ្រោងទុកជាមុនដោយមានអវត្តមាននៃបណ្ដាំនោះរបស់មតកជននោះ ចាំបាច់ត្រូវអនុវត្តយន្តការតាមច្បាប់ ដើម្បីបែងចែកចំណែកឱ្យសន្តតិជន។ យន្តការដែលត្រូវអនុវត្ត គឺមានទម្រង់ជា សន្តតិកម្មតាមច្បាប់ ទៅតាមការកំណត់ ដោយបទប្បញ្ញត្តិ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។[4]

### ១.២. ប្រភេទនៃសន្តតិកម្ម

ដោយយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាចក្រកម្ពុជាសន្តតិកម្មត្រូវបានបែងចែងជាពីរប្រភេទ គឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មមានបណ្ដាំ (មតកសាសន៍)។

#### ១.២.១.សន្តតិកម្មតាមច្បាប់

**សន្តតិកម្មតាមច្បាប់** ៖ ជាការផ្ទេរសិទ្ធិ និងកាតព្វកិច្ចនៃទ្រព្យទាំងអស់របស់មតកជន មកឱ្យជនដែលត្រូវបានចាត់ទុកថាជាសន្តតិជន តាមច្បាប់កំណត់ ដោយសារគ្មានលិខិតបណ្ដាំរបស់មតកជនអំពីវិធីបែងចែកចំណែកមត៌កទៅឱ្យជនដែលត្រូវបានចាត់ទុកជាសន្តតិជន តាមលក្ខណៈសមភាពជាក់ស្ដែងនៃចំណែកមត៌កទៅឱ្យសន្តតិជន។[5]

ការបង្កើតឱ្យមានសន្តតិកម្មតាមច្បាប់ពិតជាមានសារៈសំខាន់ណាស់ សម្រាប់ជួយសម្រួលដល់ការបែងចែកមត៌ករបស់មតកជន ជាពិសេស ក្នុងពេលដែលមតកជនមិនបានបន្សល់ទុកនូវបណ្ដាំតាមឆន្ទៈសម្រាប់ធ្វើការបែងចែកទ្រព្យសម្បត្តិមុនពេលដែលខ្លួនទទួលមរណភាព។ លើសពីនេះ ការកំណត់ឱ្យមានសន្តតិកម្មតាមច្បាប់អាចជួយសម្រួល ឬទប់ស្កាត់វិវាទរវាងសមាជិកគ្រួសារ ឬបងប្អូនសាច់ញាតិរបស់មតកជន ដោយហេតុថា

[4] “ក្រមរដ្ឋប្បវេណីកម្ពុជា”, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៤៥។

[5] “ក្រមរដ្ឋប្បវេណីកម្ពុជា”,លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៥១។

ច្បាប់នឹងធ្វើការកំណត់អំពីជនណាដែលមានសិទ្ធិតាមផ្លូវច្បាប់ទៅលើចំណែកមត៌ករបស់មតកជនមុនគេ។ ប្រសិនបើច្បាប់មិនបានកំណត់អំពីសន្តតិកម្មតាមច្បាប់ ហើយលំដាប់នៃសន្តតិជនមិនត្រូវបានកំណត់ អាចនាំឱ្យមានភាពមិនច្បាស់លាស់ក្នុងការបែងចែកមត៌ករបស់ជនដែលបានស្លាប់ទៅ និងអាចនាំឱ្យសាច់ញាតិរបស់មតកជន ឬបុគ្គលដែលអាចទទួលបានប្រយោជន៍ពីមត៌កមានជម្លោះក្នុងការបែងចែកមត៌ក ឬទ្រព្យសម្បត្តិរបស់មតកជនជាដើម។ ដូច្នេះហើយ បានជាបទប្បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចូលមកបំពេញនូវតម្រូវការនៃការបែងចែកមត៌ករបស់មតកជន ដើម្បីចៀសវាងការបង្កឱ្យមានជម្លោះ ភាពស្មុគស្មាញ និងចំណាយពេលជាច្រើនក្នុងការបែងចែកមត៌ករបស់មតកជន។

➢ ដើម្បីអោយសន្តតិជនទទួលសន្តិកម្មបាន សន្តតិជនត្រូវមានលក្ខណះសម្បត្តិដូចខាងក្រោមះ

- ជនដែលមានជីវិត(លើកលែងទារកក្នុងគភ៌)
- ជនដែលមិនត្រូវបានផ្តាច់មត៌ក
- ជនដែលមិនមែនជាអភ័ព្វបុគ្គល[6]

ក្នុងករណីគ្មានបណ្តាំមត៌ក ច្បាប់កំណត់ថា កេរមតកត្រូវចែកទៅឱ្យសន្តតិជនដែលមាន ៣ លំដាប់។ ជាគោលការណ៌ សន្តតិជនរបស់មតកជន មានចំនួន ៣ លំដាប់ដោយផ្អែកតាមមាត្រា១១៥៦ មាត្រា១១៥៦ និងមាត្រា១១៦០ នៃក្រមរដ្ឋប្បវេណី ដែលមានដូចខាងក្រោមះ

### ១.២.១.១.សន្តតិជនក្នុង ៣ លំដាប់

សន្តតិកម្មទាំង ៣ លំដាប់ ត្រូវបានច្បាប់ចែងក្នុងមាត្រា ដែលរួមមានះ

មាត្រា ១១៥៦ _សន្តតិជនដែលមានលំដាប់ទី១

១- កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកមតកស្មើៗគ្នា។

មាត្រា ១១៥៩_សន្តតិជនដែលមានលំដាប់ទី២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាងគេមុន។

២- ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមតិកស្មើៗគ្នា។

[6] “ក្រមរដ្ឋប្បវេណីកម្ពុជា”,លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៥១។

មាត្រា ១១៦០_សន្តតិកម្មដែលមានលំដាប់ទី៣
១- បើមតកជនពុំមានទាំងបព្វាញាតិផ្ទាល់ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។
២- បើបងប្អូនមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមតកភាគស្មើៗគ្នា។ ប៉ុន្តែ ចំណែកមតិករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមតិករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា។
៣- បញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមតិកក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជា សន្តតិជន យោងតាមបញ្ញត្តិ នៃកថាខណ្ឌទី១ និង ទី២ ខាងលើនេះ បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។

**ដោយផ្អែកតាមមាត្រាខាងលើ សន្តតិជនទាំង៣រួមមាន៖**

1. សន្តតិជនលំដាប់ទី១ : ជាកូនរបស់មតកជន ទោះកូនបង្កើត កូនសុំក្តី ត្រូវមានចំណែកស្មើៗគ្នា។
2. សន្តតិជនលំដាប់ទី២ : ករណីមតកជនពុំមានបច្ឆាញាតិផ្ទាល់ ឬកូននោះទេ បុព្វញាតិផ្ទាល់ដូចជាឪពុកម្តាយ ត្រូវទទួលចំណេកមត៌កស្មើគ្នា។
3. សន្តតិជនលំដាប់ទី៣ : ក្នុងករណីមតកជននោះពុំមានបច្ឆាញាតិ និងបុព្វបុព្វញាតិផ្ទាល់ទេ បងប្អូនបង្កើតនឹងក្លាយទៅជាសន្តតិជន ដែលត្រូវទទួលចំណែកមតកស្មើៗគ្នា។ ប៉ុន្តែចំពោះបងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នា ត្រូវទទួលបានចំណែកតែ ១/២ នៃចំណែកបងប្អូនមានឪពុក និងម្តាយទាំងសងខាងដូចគ្នា។

### ១.២.១.២.សន្តតិកម្មរបស់សហព័ទ្ធ

មាត្រា ១១៦១_សន្តតិកម្មរបស់សហព័ទ្ធ
១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។
២- នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញាត្តិនៃផ្នែកទី១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ។

ក្នុងករណីដែលមតកជន មានសហព័ទ្ធ នោះសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។ សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ។ សន្តតិកម្មបានឡើយ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ។

មាត្រា ១១៦២_ចំណែកមតិក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជសន្តតិជន ចំណែកមតិករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ៖

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមតិកស្មើគ្នា។

ខ-បើសហព័ទ្ធ និង ឱពុកម្តាយរបស់មតកជន ជាសន្តតិជន ចំណែកមតិក របស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមតិករបស់ឱពុក ម្តាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី)។ ប៉ុន្តែ បើ ឱពុក ឬ ម្តាយ របស់មតកជន តែម្នាក់នៅរស់ ឱពុក ម្តាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមតិកស្មើគ្នា។

គ- បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឱពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែក មតិករបស់សហព័ទ្ធ ត្រូវជា ១ភាគ២ (មួយភាគពីរ) ឯចំណែកមតិករបស់បុព្វញាតិផ្ទាល់ ក្រៅពីឱពុកម្តាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវ ១ភាគ២ (មួយភាគពីរ)

ក្រៅពីសហព័ទ្ធ បើមានសន្តតិជនផ្សេងទៀតក្នុងលំដាប់ទី៣ (មិនថាលំដាប់ទី១, ២, ឬ ៣, ) សហព័ទ្ធត្រូវតែទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននេះជានិច្ច ហើយការអនុវត្តបែបនេះ ក៏មានលក្ខណៈស្រដៀងទៅនឹងក្រមរដ្ឋប្បវេណីជប៉ុន មាត្រា៨៩០ផងដែរ។[7] សន្មតថាមតកជន មានបច្ឆាញាតិផ្ទាល់ ដែលជាកូន ឬក៏មានសន្តតិជនជំនួសកូននោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយសន្តតិជននោះ។ ប្រសិនបើ បុព្វញាតិផ្ទាល់របស់មតកជននោះ ដែលជាសន្តតិជនលំដាប់ទី២ ទទួលសន្តតិកម្ម សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយសន្តតិជននោះដែរ ។ ប្រសិនបើមតកជនណាម្នាក់ គ្មានសន្តតិជនចាប់ពីលំដាប់ទី១ ដល់លំដាប់ទី៣

[7] " ក្រមរដ្ឋប្បវេណីជប៉ុ", Cill Code of Japan (Part IV and Part V ( Tentative translation), Act No. 89 of April 27, 1896,

Translation date: January 30, 2024 Article 890 The spouse of a decedent shall always be an heir. In this case, if there is a person to become an heir pursuant to the provisions of Article 887 or the preceding Article, the spouse shall be of the same rank as that person.
Retrieved from: http://www.japanesclawtranslation.go.jp/law/detail/?id=2252&vm=2&rc=02&ncw=1

នោះទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯងដោយយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី១ ដោយអត្ថន័យនេះ ត្រូវបានបន្សល់ទុកតាំងពីក្រមរដ្ឋប្បវេណីចាស់[8]មកម្ល៉េះ។[9]

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជននឹងត្រូវបានបែងចែក ដោយផ្អែកតាមមាត្រា១១៦២ នៃក្រមរដ្ឋប្បវេណី ដែលដូចនឹងតាមការកំណត់ដូចខាងក្រោមៈ

ករណីទី១-បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះដែលត្រូវជាកូនរបស់មតកជន សន្តតិជនទាំងអស់ត្រូវទទួលចំណែកមត៌កស្មើៗគ្នា។

ករណីទី២-បើសហព័ទ្ធ និងឪពុកម្តាយជាសន្តតិជន នោះសន្តតិជនទាំង៣រូប ត្រូវទទួលបានចំណែក១/៣ ស្មើៗគ្នា។ បើមតកជនមានឪពុកឬម្តាយតែម្នាក់ នោះសហព័ទ្ធ និងឪពុកឬម្តាយដែលនៅរស់ត្រូវទទួលចំណែក១/២ស្មើគ្នា។

ករណីទី៣-បើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ ឬបងប្អូនបង្កើត ឬសន្តតិជនជំនួស នោះចំណែកមតករបស់សហព័ទ្ធ ត្រូវជា ១/២ ឯចំណែកមតកបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ ឬបងប្អូនបង្កើត ឬសន្តតិជនជំនួសត្រូវជា១/២។ [10]

ការទទួលចំណេកមត៌ករបស់សហព័ទ្ធឱ្យស្ថិតនៅលំដាប់ស្មើជាមួយនឹងសន្តតិជនដែលផ្អែកតាមមាត្រា ១១៦១ កថាខណ្ឌទី២នេះ ពិតជាឆ្លុះបញ្ចាំងពីតថភាពសង្គមសព្វថ្ងៃ ដែលផ្តល់តម្លៃដល់គោលការណ៍ ការងារក្រៅផ្ទះស្មើនឹងការងារគេហដ្ឋាន និងផ្តល់នូវគុណធម៌សង្គម ឬសមភាពរវាងបុរស និងនារីដែលមានក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ហើយក៏បានធ្វើបដិប្បញ្ញត្តិកម្មក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលចាត់ទុកសហព័ទ្ធ ដែលជាប្រពន្ធនៅលំដាប់ទី៤។ ការកំណត់ក្នុងក្រមរដ្ឋប្បវេណីចាស់ខុសនេះ បានធ្វើទៅដោយមានការពិចារណាថា វាស្របនឹងបរិបទសង្គមនាសម័យកាលនោះ ដោយនីតិបញ្ញត្តិករព្រមទាំងបញ្ញត្តិស្របគ្នានឹងការអនុញ្ញាត បុរសជាស្វាមីអាចមានប្រពន្ធច្រើន (របបទ្វេពន្ធភាព) នឹងប្រពន្ធវិញពុំអាចមានប្តីច្រើនឡើយដែលបង្ហាញពី វិសមភាពនៃសិទ្ធិរវាង បុរស និងនារី។

[8] មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា។

[9] “សេចក្តីកំណត់ចម្រចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩”, ២០១០, មាត្រា ១១៦១។

[10] “ក្រមរដ្ឋប្បវេណីកម្ពុជា”, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៦២។

### ១.២.១.៣.សន្តតិកម្មជំនួស

សន្តតិកម្មជំនួស អាចអនុវត្តទៅបានតែក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម។ នោះក្នុងករណីបែបនេះ កូនរបស់ជននោះក្នុងត្រូវក្លាយទៅជាសន្តតិជនជំនួសដោយផ្អែកលើមាត្រា១១៥៧ថ្មី។

មាត្រា ១១៥៧ថ្មី_
១. បើកកូនរបស់មតកជន បានទទួលមរណភាព នៅមុន ឬ ព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវ នឹងល័ក្ខខណ្ឌដែលបានកំណត់ក្នុងបទបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ) ខាងលើនេះ ឬ ដោយការផ្តាច់មត៌កកូនរបស់បុគ្គល នោះត្រូវក្លាយទៅជាសន្តតិជនជំនួស។ ប៉ុន្តែបញ្ញាតិ នេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គល ដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន។
២. បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមាន ហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស។

ផ្អែកតាមកថាខណ្ឌទី១ នៃមាត្រា១១៥៧ថ្មី ប្រសិនបើកូនរបស់មតកជនបានទទួលមរណភាពមុនពេលដែល សន្តតិកម្ម ត្រូវបានចាប់ផ្តើមនោះកូនរបស់ជននោះ ឬចៅរបស់មតកជននោះ ត្រូវក្លាយទៅជាសន្តតិជន។ ក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាព ក្រោយពេលចាប់ផ្តើមសន្តតិកម្ម កូនមតកជនដែលទទួលមរណភាពនោះទទួលសន្តតិកម្មរបស់មតកជនរួច ទើបកូនរបស់ជននោះនឹងទទួលសន្តតិកម្មបន្តទៀតដោយសារតែជនបានទទួលមរណភាពហើយ។ ប្រសិនបើចៅរបស់មតកជនមិនអាច ឬអាចទទួលសន្តតិកម្មជាក់ស្តែងដោយអាស្រ័យលើពេលមុន ឬពេលក្រោយនៃមរណភាពរបស់កូនមតកជនត្រូវបានគេយល់ថាមិនមានភាពសមរម្យឡើយ អាស្រ័យហេតុនេះទើប របបសន្តតិកម្មជំនួសលេចចេញជារូបភាពក្នុងការគ្រប់គ្រងស្ថានភាពបែបនេះ។

ការណ៍ដែលកូនរបស់មតកជនត្រូវបាត់បង់សិទ្ធិជាសន្តតិជន ដោយសារមូលហេតុដូចជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ ត្រូវបានមតកជនផ្តាច់មត៌កជាអាទិ៍ ទោះបីជាសាមីខ្លួននេះបានបាត់បង់សិទ្ធិជារឿងដែលមិនអាចចៀសវាងបានក៏ដោយ ក៏ប៉ុន្តែកូនរបស់សាមីជនដែលបានបាត់បង់សិទ្ធជាសន្តតិជននោះ មិនគួរមានការបាត់បង់សិទ្ធិជាសន្តតិជន ជាក់ស្តែង ដោយគ្មានកំហុសឡើយព្រោះវាមានលក្ខណៈមិនសមស្របអាស្រ័យហេតុនេះ បានជាគេទទួលស្គាល់ការធ្វើ សន្តតិកម្មជំនួស ដើម្បីកុំអោយមានភាពមិនសមស្របបែបនេះ។

បន្ថែមពីនេះ ឃ្លានេះ " បានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម " ក៏ត្រូវរាប់បញ្ចូលទាំងការទទួលមរណភាពព្រមគ្នារបស់សន្តតិជន និងមតកជនផងដែរ។ នៅពេលដែលមានករណីបែបនេះ យើងមិនត្រូវធ្វើសន្តតិកម្មទៅវិញទៅមកបានទេ។[11] បន្ថែមពីនេះ វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១១៥៧ថ្មីនេះ ចែងថាក្នុងករណីដែលមតកជន បានធ្វើការសុំកូនធម្មតានោះ នោះកូនរបស់កូនសុំធម្មតានោះ មិនអាចក្លាយជា សន្តតិជនជំនួសបានទេ។ ហេតុនោះកូនរបស់កូនសុំធម្មតា ដែលបានកើតក្រោយពីពេលមតកជនបានធ្វើការ សុំកូនគឺជាបច្ចាញាតិផ្ទាល់របស់មតកជន។ អាស្រ័យហេតុនេះ កូនរបស់កូនសុំនោះអាចទទួលសន្តតិកម្ម ជំនួសបាន។ ឯឃ្លា " អនុវត្តជាបន្តបន្ទាប់" គឺត្រូវបានអនុវត្តក្នុងករណីដែលមានមរណភាពរបស់សន្តតិជនជំនួស មុនពេលដែលមានការចាប់ផ្តើមសន្តតិកម្ម ដើម្បីបើកជាផ្លូវមួយសម្រាប់ការធ្វើសន្តតិកម្មជំនួសបន្តទៀត។ ជាធម្មតា មតកជនអាចមានកូនចៅ និងចៅទួត ហើយកូន និងចៅរបស់មតកជនក៏អាចទទួលមរណភាព អាស្រ័យ ហេតុនោះចៅទួតនឹងក្លាយជាសន្តតិជនជំនួសដោយផ្អែកតាមកថាខណ្ឌទី២នៃមាត្រានេះ។ ប្រសិនបើចៅទួតនេះ បានទទួលមរណភាពដូចគ្នា គេនៅតែទទួលស្គាល់សន្តតិកម្មជំនួសបន្តបន្ទាប់ទៀត។ ម្យ៉ាងទៀត សន្តតិកម្មជំនួសជាបន្តបន្ទាប់នេះ អាចអនុវត្តចំពោះតែសន្តតិជនដែលជាកូនរបស់មតកជនប៉ុណ្ណោះ។ ប្រសិនបើមតកជន មានបងប្អូនបង្កើតជាសន្តតិជនវិញ ច្បាប់អាចទទួលស្គាល់នូវការធ្វើសន្តតិកម្មជំនួសត្រឹមតែមួយតំណប៉ុណ្ណោះ ( សូមមើលសេចក្តីកំណត់នៃមាត្រា ១១៦០)។[12]

### ១.២.២.សន្តតិកម្មតាមមានបណ្តាំ( មតកសាសន៍ )

**សន្តតិកម្មតាមមតកសាសន៍** ៖ ជាមធ្យោបាយបែងចែកមត៌កតាមឆន្ទៈរបស់មតកជន ក្រៅពីការកំណត់របស់ច្បាប់ ប៉ុន្តែមតកជន មិនអាចកំណត់អំពីវិធីបែងចែកដែលមានលក្ខណៈប៉ះពាល់ដល់ភាគបម្រុង ដែលជាសិទ្ធិរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះឡើយ។

រៀបចំលិខិតបណ្តាំមត៌កមានសារៈសំខាន់ចំពោះម្ចាស់បណ្តាំដែល មានបំណងចង់ធ្វើបណ្តាំ ដោយការសម្តែងឆន្ទៈចុងក្រោយដោយផ្ទាល់របស់ម្ចាស់បណ្តាំក្នុងការបែងចែកមត៌ក និងមានភាពប្រសើរចំពោះម្ចាស់ទ្រព្យចូលដល់ស្ថានភាពចាស់ជរា ឬគ្មានសហព័ទ្ធជាដៃគូអាចបន្តគ្រប់គ្រងបាន ពីព្រោះវាផ្តល់ឱ្យមតកជន (ម្ចាស់ទ្រព្យ) មានលទ្ធភាពក្នុងការពិនិត្យពីគុណសម្បត្តិរបស់សន្តតិជនដែលត្រូវទទួល ពីរបៀបចាត់ចែងទ្រព្យរបស់ខ្លួន និងការស្វែងរកអ្នកប្រតិបត្តិមតកសាសន៍សំរាប់ជួយខ្លួនផងដែរ។ ជាពិសេសច្បាប់បានផ្តល់សិទ្ធិ និងគោរពទៅលើឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំក្នុងការបែងចែកមត៌ករបស់គាត់ដោយសេរី លើកលែងតែមានការបំពានទៅលើភាគ

[11] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ : គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៥៥។

[12] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ : គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៥៧។

បម្រុងប៉ុណ្ណោះ។ លើសពីនេះ ការរៀបចំលិខិតបណ្តាំ ឬការធ្វើសន្តតិកម្ម តាមមតកសាសន៍នេះទៀតសោតនឹងធ្វើឱ្យមតកជននៅតែជាម្ចាស់កម្មសិទ្ធិរបស់ខ្លួន ដែលអាចចៀសវាងបាននូវហានិភ័យទាំងឡាយកើតឡើងពេលកំពុងមានជីវិតរស់នៅ ហើយវាក៏អាចជួយការពារវិវាទ ឬជម្លោះពីក្នុងចំណោមសន្តតិជនដោយប្រការណាមួយពីបញ្ហាទទួលបានទ្រព្យសម្បត្តិតិច ឬច្រើននោះផងដែរ។ លើសពីនេះទៀត ការបែងចែកទ្រព្យសម្បត្តិ ក៏ដូចជាការចាត់ចែងទ្រព្យសម្បត្តិទៀតសោតក៏បានផ្តល់សារៈសំខាន់ និងអត្ថប្រយោជន៍មួយចំនួនទៀតដែរមានដូចជាៈ

- ជួយសម្រួល និងជួយបញ្ចៀសរាល់វិវាទក្នុងគ្រួសារ ឬវិវាទទាយាទក្នុងការបែងចែកចំណែកមត៌កពីព្រោះតែមតកសាសន៍នេះត្រូវបានធ្វើឡើងដោយឆន្ទៈរបស់មតកជនពេលនៅមានជីវិត ដែលបានកំណត់យ៉ាងច្បាស់នូវរាល់ចំណែកដែលទាយាទទទួលបាន។
- អាចកំណត់អំពីការផ្តាច់មត៌កពីសន្តតិជនបាន ពោលគឺបុគ្គលនោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងការបែងចែកចំណែកមត៌ក ហើយករណីនេះអាចកើតមានឡើងដោយសារតែ បុគ្គលដែលត្រូវបានកាត់ផ្តាច់នោះទទួលបាននូវផលប្រយោជន៍ពិសេស ឬទទួលបានចំណែកទ្រព្យសម្បត្តិនៅពេលមតកជននៅរស់ មួយវិញទៀតក៏មានករណីមួយចំនួនដែលអាចមកពីធ្វើបាបចំពោះមតកជន ការប្រមាថយ៉ាងធ្ងន់ធ្ងរ មិនយកចិត្តទុកដាក់ទៅលើមតកជននៅពេលដែលមតកជនមានជម្ងឺ ត្រូវបានទទួលសាលក្រម ឬសាលដីការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត និងបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ ជាអាទិ៍។
- ចុងក្រោយនោះ គឺមតកជនក៏អាចប្រើប្រាស់សិទ្ធិក្នុងការទទួលស្គាល់កូន ដោយកំណត់នៅក្នុងមតកសាសន៍បាន។ ការទទួលស្គាល់បែបនេះ គឺក្នុងគោលបំណងកំណត់នូវបិតុភាពចំពោះកូន ឬ ទារកក្នុងគភ៌ ថែមទាំងដើម្បីផ្តល់សិទ្ធិអោយក្លាយជាទាយាទក្នុងការទទួលបានចំណែកមត៌កផងដែរ។[13]

## ១.៣.អានុភាពនៃសន្តតិកម្ម

តាមរយៈគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិសិទ្ធិ និងករណីកិច្ចទាំងឡាយ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ត្រូវតែបន្សល់ដល់សន្តតិជន។ មាត្រា ១១៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមមូលដ្ឋាននៃគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។

[13] មាត្រា៩៩៥ ក្រមរប្បវេណី ឆ្នាំ២០០៧

ដូច្នេះក្រមរដ្ឋប្បវេណី បានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ហើយពុំបានជ្រើសយក គោលការណ៍ជម្រះបញ្ជីនោះទេ។ អាស្រ័យហេតុនេះ សន្តតិជនត្រូវទទួលសិទ្ធិ និងករណីយកិច្ចចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម[14] ក្នុងគោលបំណងឱ្យមាននិរន្តរភាពតាមផ្លូវច្បាប់។[15]

បន្ថែមពីនេះទៀត សន្តតិកម្មអចលនវត្ថុ អាចទទួលបន្តដោយស្វ័យប្រវត្តិនូវ អចលនវត្ថុដែលជាមត៌កនៅពេលដែលមតកជនទទួលមរណភាព ដោយមិនចាំបាច់ធ្វើការចុះបញ្ជី ពាក់ព័ន្ធនឹងការណ៍ដែលបានធ្វើសន្តតិកម្មក្រោមទម្រង់ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ឡើយ។ យើងអាចធ្វើការពិចារណាបានថា ប្រសិនបើមានការចុះបញ្ជីជាលក្ខខណ្ឌដើម្បីទទួលបន្តតាមសន្តតិកម្ម នោះក្នុងអំឡុងពេលមុនសន្តតិជនធ្វើការចុះបញ្ជី ពុំមានអត្ថិភាពម្ចាស់កម្មសិទ្ធិអចលនវត្ថុឡើយ គោលការណ៍នេះអាចផ្តល់ជាស្ថានភាព ដែលទ្រព្យនោះធ្លាក់ ទៅជាទ្រព្យរដ្ឋ។ ក្នុងករណីដែលវត្ថុទាំងនោះ ពុំអាចធ្វើសន្តតិកម្មដោយសន្តតិជនតាមច្បាប់បាន ចាំបាច់ត្រូវអោយបន្តដោយជនដទៃទៀត ឬក៏មានករណីមួយចំនួនដែលមានសហសន្តតិជន (ករណី នៃសហសន្តតិកម្ម)។ បន្ថែមពីនេះសហសន្តតិជនណាម្នាក់អាចទទួលវត្ថុទាំងនោះដោយឯកឯងដោយមិន ស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគ ដូចមានចែងក្នុងមាត្រា ១១៤៨ ទេ។ ដូច្នេះយើងអាចកំណត់ថា វត្ថុទាំងនេះ ត្រូវទទួលបន្ត ដោយយោងតាមឆន្ទៈរបស់មតកជន ឬតាមទំនៀមទម្លាប់ដែលមាន ទោះបីជាមានប្រពន្ធ និងឪពុកម្តាយជាសហសន្តតិជនក៏ដោយ។

**កំណត់សម្គាល់៖**

ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៥៩៣ និងមាត្រា ៦០២ បានចែងថាកាតព្វកិច្ចសន្តតិកម្មត្រូវធ្វើការជម្រះបញ្ជីសិនមុន នឹងធ្វើការបែងចែកមត៌ក ជាអាទិ៍ ហើយមើលទៅដូចជាគោលការណ៍ជម្រះបញ្ជីដែរ ក៏ប៉ុន្តែ នៅក្នុងមាត្រា ៦០៥ និងមាត្រា ៥៨៣ បានចែងថា សន្តតិជនដែលមានភាគបម្រុង មានករណីកិច្ចទទួលបន្តនូវការសងបំណុល ព្រមទាំងមិនអាចបោះបង់សន្តតិកម្មបានទេ ហើយបញ្ហានេះអាចចាត់ទុកថាជាគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមួយប្រភេទដែរ។[16]

[14] "ក្រមរដ្ឋប្បវេណីជប៉ុន", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៤៧

[15] " ក្រមរដ្ឋប្បវេណីជប៉ុ", Cill Code of Japan (Part IV and Part V ( Tentative translation), Act No. 89 of April 27, 1896,

Translation date: January 30, 2024 Article 890 The spouse of a decedent shall always be an heir. In this case, if there is a person to become an heir pursuant to the provisions of Article 887 or the preceding Article, the spouse shall be of the same rank as that person.
Retrieved from: http://www.japanesclawtranslation.go.jp/law/detail/?id=2252&vm=2&rc=02&ncw=1

[16] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

មាត្រា ១១៤៨_ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងរណីដែលមានសន្តតិ ច្រើននាក់
១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗត្រូវទទួលបន្តនូវសិទ្ធិ និងករណីកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ។ ប៉ុន្តែសិទ្ធ ឬ ករណីកិច្ចដែល មិនអាចបែងចែក បានតាមលក្ខណៈនៃសិទ្ធិ ឬ ករណីកិច្ចនោះ ត្រូវទទួលបន្តដោយ អវិភាគីយ៍។
២-មត៌កនេះនឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន។

ក្នុងករណីដែលមានសន្តតិជនច្រើននាក់ ការទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនដោយសហសន្តតិជនម្នាក់ៗ ទៅតាមសមាមាត្រនៃចំណែកមត៌កដែលខ្លួនត្រូវស្នង ក្នុងករណីដែលមានសន្តតិជនច្រើននាក់ ដោយផ្អែកតាមកថាខណ្ឌទី១។

- ក្នុងករណីដែលមតកជនមានសិទ្ធិលើបំណុលជាប្រាក់ចំពោះតតិយជន យើងអាចធ្វើការបែងចែក សិទ្ធិលើបំណុលនេះ តាមចំណែកមត៌កដែលច្បាប់បានកំណត់ដល់សហសន្តតិជននីមួយៗ ដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់រង់ចាំពេលបែងចែកមត៌កទេ។
- ក្នុងករណីដែលមតកជនមានកាតព្វកិច្ច ចំពោះតតិយជន ប្រសិនបើកាតព្វកិច្ចនោះជាប្រាក់ ជាអាទិ៍ ដែលអាចបែងចែកបាន ត្រូវបែងចែកតាមចំណែកមត៌កដែលច្បាប់ បានកំណត់ហើយសហសន្តតិជនត្រូវទទួលករណីកិច្ចសងកាតព្វកិច្ចរបស់មតកជន ប្រសិនបើមិនបានបោះបង់ចោលការស្នងនោះទេ ហើយករណីកិច្ចនេះត្រូវធ្វើទៅតាមសមាមាត្រានៃចំណែកមត៌កដែលច្បាប់បានកំណត់ លើកលែងតែសហសន្តតិជនមិនបានបោះបង់ សន្តតិកម្មនោះទេ។

# ជំពូកទី២

# ការបង្កើតមតកសាសន៍

# ជំពូកទី២
# ការបង្កើតមតកសាសន៍

## ២.១.លក្ខខណ្ឌគ្រឹះនៃការបង្កើតមតកសាសន៍

ជាគោលការណ៍ លិខិតគតិយុត្តឯកតោភាគីទាំងអស់ តែងតែស្ថិតនៅក្រោមលក្ខខណ្ឌជាមូលដ្ឋានដូចគ្នានឹងលក្ខខណ្ឌតម្រូវចំពោះកិច្ចសន្យាដែរ គឺលក្ខខណ្ឌគ្រឹះនៃឆន្ទៈ សមត្ថភាពកម្មវត្ថុ និងមូលហេតុ។[17] ហេតុនេះ តើលិខិតគតិយុត្តជាមតកសាសន៍ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវជាគ្រឹះ តាមគោលការណ៍ខាងលើដែរ ឬយ៉ាងណា? ចម្លើយគឺ គោលការណ៍ខាងលើនឹងត្រូវបានកាត់បន្ថយចំពោះលិខិតគតិយុត្តជាមតកសាសន៍។

តាមពិតទៅ ការកាត់បន្ថយដែលបានលើកឡើងខាងលើ បានពីមូលហេតុដែលថា មតកសាសន៍ជាលិខិតកើតពីឆន្ទៈនៃបុគ្គលតែម្នាក់តែអាចបង្កើតអានុភាព (សិទ្ធិ និងករណីយកិច្ច) ឱ្យដល់បុគ្គលដទៃទៀត (សន្តតិជន ឬអច្ច័យលាភី) ហេតុនេះហើយទើបលក្ខខណ្ឌចាំបាច់ គឺមានតែម្យ៉ាងប៉ុណ្ណោះ ដែលតម្រូវចំពោះសុពលភាពនៃលិខិតមតកសាសន៍[18] ពោលគឺ ភាពពិតប្រាកដនៃឆន្ទៈរបស់មតកជនតែម្តង។ លក្ខខណ្ឌគ្រឹះនៃការបង្កើតមតកសាសន៍នឹងធ្វើការសិក្សាទៅលើសមត្ថភាព ម្ចាស់បណ្តាំពេលធ្វើមតកសាសន៍ និងការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំដោយគ្មានវិការៈ ។

### ២.១.១.សមត្ថភាពរបស់មតកជន

មតកសាសន៍ គឺជារបបមួយដែលបង្កើតឡើង ដើម្បីគោរពឆន្ទៈពិតរបស់ម្ចាស់បណ្តាំ។ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈ នៅពេលធ្វើមតកសាសន៍។ មានន័យថា ប្រសិនបើម្ចាស់បណ្តាំគ្មានសមត្ថភាពខាងឆន្ទៈពេលធ្វើមតកសាសន៍ ដោយសារតែស្រវឹងស្រាខ្លាំង ឬដោយសារមានជំងឺវង្វេងដោយភាពចាស់ជរា ជាអាទិ៍ មតកសាសន៍អាចក្លាយជាមោឃៈ។[19] ក្នុងករណីដែលបុគ្គលដែលបានអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់អំពីការខ្វះសមត្ថភាពនោះ។

បុគ្គលដែលអាចធ្វើមតកសាសន៍បានជាមានដូចជា បុគ្គលជានីតិជន (២.១.១.១.) ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ (២.១.១.២.) និងអនីតិជនដែលទទួលបានអត្តាធីនភាព(២.១.១.៣.)។

---

[17] សូមបញ្ជាក់ថា លក្ខខណ្ឌមូលហេតុនៃការបង្កើតលិខិតនេះ ត្រូវបានទទួលស្គាល់ជាលក្ខខណ្ឌគ្រិះ នៅក្នុងនីតិវិជ្ជមានមានបារាំងប៉ុណ្ណោះ ប៉ុន្តែ នីតិវិជ្ជាមានខ្មែរពុំចាត់ទុកលក្ខខណ្ឌនេះ ជាលក្ខណមួយនៃការបង្កើតរាល់លិខិតគតិយុត្តឡើយ។

[18] សូមមើលសៀវភៅរបស់ Jaques Flour, Jean Aubert, Eric Savex មានចំណងជើងថា "Les obligations, 1. Acted Jordie"បោះពុម្ពលើកទី៨ នាឆ្នាំ២០០០ទំព័រ៣៦១។

[19] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីសេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០១០) មាត្រា ១១៦៩។

### ២.១.១.១.បុគ្គលជានីតិជន

ជាគោលការណ៍ បុគ្គលជានីតិជនអាចធ្វើនូវមតកសាសន៍បាន ហើយមានសមត្ថភាពឯករាជ្យខាងអំពើ ឬសកម្មភាពរបស់ខ្លួន។ នីតិជន គឺសំដៅលើជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ដូចក្រមរដ្ឋប្បវេណីកំណត់ ដោយមានការយល់ឃើញថា បុគ្គលដែលមានវ័យ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើង ទៅមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់។[20] នីតិជនមានសិទ្ធិគ្រប់គ្រាន់ក្នុងធ្វើសកម្មភាព គ្រប់គ្រងទ្រព្យសម្បត្តិ ចាត់ចែងទ្រព្យសម្បត្តិ និងបង្កើតកិច្ចសន្យាផ្សេងៗ។ ចំពោះមតកសាសន៍ ជាប្រភេទសកម្មភាពឯកតោភាគី ដែលនីតិជន ឬមតកជនមានសិទ្ធិធ្វើក្នុងការផ្តល់នូវសិទ្ធិ និងករណីកិច្ចបន្តទៅឱ្យសន្តតិជន ឬអច្ច័យលាភីបាន។

### ២.១.១.២ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ

ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ ក៏អាចធ្វើមតកសាសន៍ដោយខ្លួនឯងបានដែរ ដោយមិនចាំបាច់មានការយល់ព្រមពីអាណាព្យាបាល ឬហិតូបត្ថម្ភឡើយ ហើយមតកសាសន៍ទាំងនោះមិនអាចលុបចោលបានទេ។[21] ទោះជាយ៉ាងនេះក្តី ពួកគេត្រូវមានសមត្ថភាពធ្វើមតកសាសន៍នោះផងដែរ ហើយអ្វីដែលស្មុគស្មាញនោះគឺ ករណីរបស់ជននៅក្រោមអាណាព្យាបាលទូទៅ។ ជននៅក្រោមអាណាព្យាបាលទូទៅ តែងខ្វះសមត្ថភាពក្នុងការធ្វើមតកសាសន៍។ ប៉ុន្តែ ជននៅក្រោមអាណាព្យាបាលទូទៅ ក៏អាចមានសមត្ថភាព ធ្វើមតកសាសន៍នៅពេលខ្វះដែរ ដោយសារតែស្ថានភាពរបស់ជននោះអាចនឹងប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ដូច្នេះ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍បាន តែនៅពេលជននោះជាសះស្បើយមួយរយៈឡើងវិញជាបណ្តោះអាសន្ននូវសមត្ថភាពប៉ុណ្ណោះ។[22] ក្រោយធ្វើមតកសាសន៍ ជននោះអាចបាត់បង់នៅសមត្ថភាព ក្នុងពេលឆាប់ៗម្តងទៀត ក៏ដោយវាមិនប៉ះពាល់ដល់សុពលភាពរបស់មតកសាសន៍នោះទេ។ នៅក្នុងការបង្ហាញ ភស្តុតាងអំពីការជាសះស្បើយមួយរយៈនូវសមត្ថភាពជាបណ្តោះអាសន្ននោះ នៅពេលធ្វើមតកសាសន៍ តម្រូវឱ្យ មានវេជ្ជបណ្ឌិតយ៉ាងតិច ២(ពីរ) នាក់ដើម្បីពិនិត្យបញ្ជាក់ថាជននោះមានសមត្ថភាពគ្រប់គ្រាន់នៅពេលធ្វើបណ្តាំ។ វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិត

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧, ០៨ ធ្នូ ឆ្នាំ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ១០,លេខ៧០។

[21] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០ ០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៦៨ កថាខណ្ឌទី២។

[22] ក្រមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ៣, កែសម្រួលលើការបោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ឆ្នាំ២០១៧), ទំព័រ ៤៩។

ក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ។[23]

បើទោះបីជាជននៅក្រោមហិតូបត្ថម្ភ ជាជនដែលត្រូវបានកម្រិតសមត្ថភាពក៏ដោយ ក៏អាចធ្វើមតកសាសន៍បានដែរ។[24] ម្យ៉ាងទៀតក្រមរដ្ឋប្បវេណី ពុំបានកំណត់អំពីទម្រង់ណាមួយ ដើម្បីបំពេញបន្ថែមក្នុងករណីជននៅក្រោមហិតូបត្ថម្ភ ធ្វើមតកសាសន៍ ដូចករណីជននៅក្រោមអាណាព្យាបាលទូទៅទេ ពោលគឺមាត្រា ១១៦៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ មិនរាប់បញ្ចូលជននៅក្រោមហិតូបត្ថម្ភទេ ហេតុដូច្នេះ អាចបកស្រាយថា ជននៅក្រោមហិតូបត្ថម្ភ ជាជនដែលមានសមត្ថភាពនៅពេលធ្វើមតកសាសន៍ លើកលែងតែមានការអះអាងណាមួយថា ជននៅក្រោមហិតូបត្ថម្ភ បានធ្វើមតកសាសន៍ក្នុងកំឡុងពេលដែលខ្លួនមិនបានយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។

### ២.១.១.៣.បុគ្គលជាអនីតិជនដែលទទួលបានអត្តាធីនភាព

លក្ខខណ្ឌនៃអត្តាធីនភាព ក្នុងករណីដែលអនីតិជនបានដល់អាយុ ១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់ជននោះបាន តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើ តុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជន។ ក្នុងករណីនេះ តុលាការត្រូវសួរ យោបល់ពីអ្នកមានសិទ្ធិអំណាចមេបា។[25] ម៉្យាងទៀត អនីតិជនបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។[26] ក្នុងករណីដែលបានកំណត់ខាងលើនេះបើទោះបី ភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ។

អានុភាពនៃអត្តាធីនភាព ចំពោះអនីតិជនដែលទទួលអត្តាធីនភាព ត្រូវចាត់ទុកថាបានដល់នូវនីតិភាព។ នៅពេលដែលអនីតិជនបានទទួលនូវអត្តាធីនភាព គាត់មានសិទ្ធិធ្វើសកម្មភាពដូចជានីតិជនដែរ។ អនីតិជនដែល បានទទួលអត្តាធីនភាព រួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា អាចធ្វើមតកសាសន៍បាន។[27] ពោលគឺមានន័យថា អនីតិជនដែលទទួលបានអត្តាធីនភាពមានសិទ្ធិក្នុងការធ្វើបណ្តាំ ឬមតកសាសន៍ដូចគ្នា និងនីតិជនដែរ។

---

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៣០ ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ១១៧៦ កថាខណ្ឌទី២។

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧, ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ១១៦៨។

[25] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ២១ កថាខណ្ឌទី២។

[26] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ២១ កថាខណ្ឌទី៣។

[27] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ២២។

### ២.១.២.ការបង្ហាញឆន្ទៈរបស់មតកជន

ម្ចាស់បណ្តាំធ្វើបណ្តាំ គឺក្នុងគោលបំណងសម្តែងនូវការសម្រេចចិត្តចុងក្រោយរបស់ខ្លួនដើម្បីផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនឱ្យទៅសន្តតិជន និងដើម្បីកុំឱ្យកើតមានជម្លោះរវាងសហសន្តតិជន នៅពេលខ្លួនបានទទួលមរណភាព។ មតកសាសន៍ត្រូវបានទទួលស្គាល់ជាអានុភាពផ្លូវច្បាប់ ដោយមានការគោរពឆន្ទៈពិត និងចុងក្រោយរបស់ម្ចាស់បណ្តាំ។[28]

សមត្ថភាពខាងឆន្ទៈ សំដៅដល់ស្ថានភាពដែលបុគ្គលអាចត្រិះរិះគិតពិចារណា ទៅលើអំពើណាមួយដែលខ្លួនធ្វើ ហើយបុគ្គលដែលបានធ្វើសកម្មភាព អាចមើលឃើញជាមុននូវលទ្ធផលផ្លូវច្បាប់ ដែលកើតចេញពីអំពើរបស់ខ្លួន។ ផ្អែកតាមមាត្រា ១៤ នៃក្រមរដ្ឋប្បវេណីបានចែងថា សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន។ ចំពោះការធ្វើមតកសាសន៍ក៏ដូចគ្នាដែរ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈនៅពេលដែលខ្លួនធ្វើមតកសាសន៍។ បន្ថែមពីលើនេះ ការបង្ហាញឆន្ទៈរបស់មតកជន ត្រូវចៀសអំពីវិការៈក្នុងការបង្ហាញឆន្ទៈ។[29]

ទោះបីជាម្ចាស់បណ្តាំ បានធ្វើមតកសាសន៍តាមកំណត់ច្បាប់ និងមានសមត្ថភាពខាងឆន្ទៈត្រឹមត្រូវក៏ដោយមតកសាសន៍នឹងមិនបង្កើតសុពលភាពតាមច្បាប់នោះទេ ប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ។

#### ២.១.២.១.ការភាន់ច្រឡំ

ការភាន់ច្រឡំ គឺជាសកម្មភាពដែលម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈផ្ទុយពីគោលបំណងរបស់ខ្លួន។ ជាគោលការណ៍ច្បាប់ មិនមែនដោយសារតែការភាន់ច្រឡំរបស់ម្ចាស់បណ្តាំតែម្ខាង អាចអះអាងអំពីវិការៈនៃការបង្ហាញឆន្ទៈ និងយកជាមូលហេតុដើម្បីលុបចោលមតកសាសន៍បានឡើយ។ ការភាន់ច្រឡំរបស់ម្ចាស់បណ្តាំអាចយកធ្វើជាមូលហេតុនៃការលុបចោលមតកសាសន៍ គឺជាសកម្មភាពដែលម្ចាស់បណ្តាំមានការភាន់ច្រឡំលើចំណុចសំខាន់ៗ នៃមតកសាសន៍ ហើយភាគីម្ខាងទៀតដែលជាសន្តតិជន ឬជាអច្ច័យលាភី ឬបុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍តាមមតកសាសន៍ អាចដឹងអំពីការភាន់ច្រឡំនោះដែរ។[30] ការភាន់ច្រឡំអាចជាការកាន់ច្រឡំលើចំណុចទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបែងចែក ឬលក្ខណៈនៃសន្តតិជន ឬអច្ច័យលាភីជាដើម។

[28] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣, បោះពុម្ពលើកទី ១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ៤៨។

[29] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៣១២ កថាខណ្ឌទី២។

[30] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ឆ្នាំ២០០៧,មាត្រា ៣៤៦។

**២.១.២.២.ការឆបោក**

ការឆបោក គឺជាទង្វើរបស់សន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈ មតកសាសន៍ ឬតតិយជន មាននូវចេតនាទុច្ចរិត ដោយប្រើប្រាស់ឧបាយកលឆបោក ឬមធ្យោបាយណាមួយក្នុងគោលបំណងដើម្បីឱ្យម្ចាស់បណ្តាំបង្ហាញឆន្ទៈទៅតាមអ្វីដែលខ្លួនចង់បាន។ ក្នុងករណី ដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់សន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ ម្ចាស់បណ្តាំអាចលុបចោលនូវការបង្ហាញឆន្ទៈនោះដោយសារមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតជាសន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍បានដឹង ឬអាចដឹងអំពីការឆបោកនោះ។[31]

**២.១.២.៣.ការគំរាមកំហែង**

ការគំរាមកំហែង គឺជាស្ថានភាពមួយដែលម្ចាស់បណ្តាំធ្វើការបង្ហាញឆន្ទៈ ដោយសារមានការគំរាមកំហែងអំពីសំណាក់សន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍ ឬតតិយជន។[32] ដោយឱ្យម្ចាស់បណ្តាំធ្វើមតកសាសន៍ទៅតាមអ្វីដែលខ្លួនចង់បាន។ ការគំរាមកំហែង គឺអាចស្តែងឡើងតាមរយៈពាក្យសម្តី ឬអំពើហឹង្សា និងក្រោមរូបភាពផ្សេងៗទៀត។

**២.១.២.៤.ព័ត៌មានមិនពិត**

ព័ត៌មានមិនពិត គឺជាស្ថានភាពមួយដោយមាននៅបុគ្គលណាម្នាក់ ឬអាចជាសន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ ដោយបានបង្ហាញទៅភាគីម្ខាងទៀតដែលជាមតកជនខុសអំពីការពិត ហើយភាគីម្ខាងទៀតដែលជាមតកជនបានបង្ហាញឆន្ទៈ ដោយជឿជាក់ថាហេតុទាំងនោះជាការពិត។[33]

**២.១.២.៥.ការរំលោភបំពានលើស្ថានភាពពិត**

ការរំលោភបំពានលើស្ថានភាពពិត មានន័យថាភាគីម្ខាងបានប្រើប្រាស់មិនត្រឹមត្រូវនូវឋានៈរបស់ខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ទាំងខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលផ្ទុយនឹងគោលការណ៍សមភាព ដែលភាពីម្ខាងមិនអាចប្រឆាំងតបបាន។[34] ការរំលោភបំពានលើស្ថានភាពដែលបានកើតឡើងនៅពេលធ្វើមតកសាសន៍ ដោយបុគ្គលមានផលប្រយោជន៍អាច

[31] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៣៥៧។

[32] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៣៥០។

[33] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៣៥៨។

[34] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៣៥៩។

ជាសន្តតិជន ឬអច្ច័យលាភី ឬតតិយជនបានប្រើប្រាស់ឋានៈរបស់ខ្លួនមានអាទិភាពជាម្ចាស់បណ្ដាំ ហើយដូចនេះមតកជនអាចលុបចោលមតកសាសន៍បានដោយហេតុថាមានវិការៈ។

**២.១.៣.កម្មវត្ថុនៃមតកសាសន៍**

វត្ថុដែលអាចផ្ទេរបាន ២.១.៣.១.សិទ្ធីប្រត្យក្ស, ២.១.៣.២.សិទ្ធិឥទេយ្យ, ២.១.៣.៣.សិទ្ធិខាងបញ្ញា, ហើយសិទ្ធិទាំងបីនេះសុទ្ធតែជាសិទ្ធិស្របច្បាប់ ជាសិទ្ធិដែលមានរបស់មតកជន ដូចជាកម្មវត្ថុកិច្ចសន្យាទិញលក់ជាដើម។

**២.១.៣.១.សិទ្ធិប្រត្យក្ស**

សំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។ សិទ្ធិប្រត្យក្ស សំដៅទៅលើសិទ្ធិគ្រប់គ្រងទៅលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដ៏ទៃទៀតបាន ។ មានន័យថាជាសិទ្ធិមួយដែលច្បាប់ បានផ្តល់ឲម្ចាស់កម្មសិទ្ធិគ្រប់គ្រង ដោយផ្ទាល់មុខទៅលើវត្ថុហើយមានលក្ខណៈដាច់ខាតដែលអាចអះអាងចំពោះបុគ្គលដ៏ទៃទៀតបាន។ សិទ្ធិប្រត្យក្សនេះ ជាសិទ្ធិដាច់ខាតមួយដែលម្ចាស់កម្មសិទ្ធិមានសិទ្ធិ ក្នុងការចាត់ចែង និងគ្រប់គ្រងដោយសេរី។ នៅក្នុងក្របខណ្ឌរបស់ច្បាប់ សិទ្ធិនេះបានផ្តល់នូវអានុភាព ដែលអាចតតាំងជាមួយបុគ្គលដ៏ទៃទៀតបាន សូម្បីតែជាមួយរដ្ឋ ។

**២.១.៣.២.សិទ្ធិឥទេយ្យ**

សិទ្ធិដែលបុគ្គលណាម្នាក់(ម្ចាស់បំណុល) អាចទាមទារអ្វីមួយពីបុគ្គលណាម្នាក់ទៀត(កូនបំណុល)

**២.១.៣.៣.សិទ្ធិខាងបញ្ញា**

ជាសិទ្ធិបញ្ចេញស្នាដៃខាងគំនិតប្រាជ្ញា ជាការស្រាវជាវជាការស្រាវជ្រាវ ជាការនិពន្ធ ជាការផលិត។ សិទ្ធិនេះជាទ្រព្យអរូបី ជាសិទ្ធិអាចលក់បាន និងត្រូវបានរក្សាសិទ្ធិ។ សិទ្ធិនេះគេអាចហៅថាជាកម្មសិទ្ធិបញ្ញាក៏បាន ។ បច្ចុប្បន្ន កម្មសិទ្ធិបញ្ញាត្រូវបានការពារដោយច្បាប់ជាតិ និងអន្តរជាតិ។ នៅប្រទេសជឿនលឿន កម្មសិទ្ធិបញ្ញាត្រូវបានគោរពបានយ៉ាងល្អ។

**២.២.លក្ខខណ្ឌទម្រង់នៃមតកសាសន៍**

មតកសាសន៍ ត្រូវធ្វើដោយផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ទើបអាចចាត់ទុកថាមានសុពលភាពតាមទម្រង់។[35] មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ។[36] ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើ

[35] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧០ កថាខណ្ឌទី១។

[36] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧១ កថាខណ្ឌទី១។

ដោយម្ចាស់បណ្តាំដូចគ្នានោះ។ នៅក្នុងករណីដែលមតកសាសន៍ ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើ មតកសាសន៍ទាំងនោះផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។[37]

ផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា មតកសាសន៍អាចធ្វើក្នុងស្ថានភាព ២ (ពីរ) យ៉ាងគឺ ទម្រង់មតកសាសន៍ក្នុងស្ថានភាពធម្មតា ឬទូទៅ និងមតកសាសន៍ស្ថិតក្នុងស្ថានភាពពិសេស។

### ២.២.១.ទម្រង់នៃមតកសាសន៍

#### ២.២.១.១.សាក្សី

សាក្សី គឺជាបុគ្គលដែលជួយសម្រួលដល់ការបញ្ជាក់ពីភាពត្រឹមត្រូវរបស់លិខិតមតកសាសន៍ តាមឆន្ទៈរបស់មតកជន និងមានសុពលភាពពេញលេញនៅក្នុងនីតិវិធីដែលច្បាប់បានកំណត់។ លើកលែងតែមតកសាសន៍ ដែលធ្វើឡើងដោយទម្រង់លិខិតឯកជនមួយប៉ុណ្ណោះ មិនទាមទារឱ្យមានការចូលរួមពីសាក្សី។ ចំពោះមតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់ គឺតម្រូវឱ្យមានការចូលរួមផ្ទាល់ពីសាក្សីជាចាំបាច់។ ដូច្នេះសាក្សី គឺជាបុគ្គលដែលអាចធ្វើការបញ្ជាក់បានថាមតកសាសន៍ពិតជាបានធ្វើឡើងដោយឆន្ទៈ របស់ម្ចាស់បណ្តាំពិតប្រាកដមែន។ ក៏ប៉ុន្តែ មិនមែនមានន័យថា គ្រប់បុគ្គលទាំងអស់សុទ្ធតែមានលក្ខណៈសម្បត្តិធ្វើជាសាក្សីនោះទេ ច្បាប់ក៏បានកំណត់រូបវន្តបុគ្គលមួយចំនួនដែលគ្មានលក្ខណៈសម្បត្តិធ្វើជាសាក្សីនៅក្នុងការតាក់តែងលិខិតមតកសាសន៍ បុគ្គលទាំងនោះរួមមាន៖

- អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះជនដែលមិនទាន់ពេញវ័យនីតិភាព គឺអាយុចាប់ពី១៨ ឆ្នាំ ឡើង ឬជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកស្មារតី ឬជាជនដែលត្រូវបានកម្រិតសមត្ថភាព ក្នុងការធ្វើសកម្មភាព ឬមិនអាចចូលរួមធ្វើសាក្សី ក្នុងការធ្វើមតកសាសន៍បានទេ។ ករណីដែលជនទាំងនេះបាន ធ្វើសាក្សីចូលរួមក្នុងការតាក់តែងលិខិតមតកសាសន៍នឹងធ្វើឱ្យបណ្តាំនោះមិនមានសមភាព កង្វះសមត្ថភាព និងបាត់បង់អានុភាព ដែលជាហេតុច្បាប់បានបញ្ញត្តិមិនឱ្យជនទាំងនោះធ្វើជាសាក្សី។

- សន្តតិជន បុគ្គលដែលបានសន្មតថាជាសន្តតិជន ឬបុគ្គលដែលមានផលប្រយោជន៍ ក៏មិនអាចធ្វើជាសាក្សីក្នុងការតាក់តែងលិខិតមតកសាសន៍បានឡើយ។ ក្នុងនោះរួមមាន អច្ច័យលាភី សហាព័ទ្ធរបស់ម្ចាស់បណ្តាំ ញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងលិខិតមតកសាសន៍ ផងដែរ គឺច្បាប់បានហាមឃាត់ក្នុងការចូលរួមធ្វើសាក្សីនៅពេលធ្វើបណ្តាំមត៌ក។

[37] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧១ កថាខណ្ឌទី២។

• សារការី ច្បាប់បានកំណត់នៅពេលដែលសារការីពាក់ព័ន្ធទៅលើការធ្វើមតកសាសន៍ គឺនាំឱ្យខ្វះលក្ខណៈសម្បត្តិជាសាក្សី នៅក្នុងទម្រង់លិខិតមតកសាសន៍ដោយលិខិតយថាភូត គឺម្ចាស់បណ្តាំប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារចំពោះមុខសារការី ដែលជាអ្នកកត់ត្រាខ្លឹមសារទាំងមូលជាលាយលក្ខណ៍អក្សរ ជាហេតុសារការី មិនអាចចូលរួមធ្វើសាក្សីក្នុងការធ្វើមតកសាសន៍ដោយលិខិតយថាភូតបានទេ។ បើសារការីមានការចូលរួម គឺអាចនិយាយបានថាសារការីដើរតួនាទីពីរ (វិសមិតភាព) ជាអ្នកតាក់តែងនូវខ្លឹមសារផង និងជាសាក្សីផង ដូច្នេះករណីនេះមិនអាចឱ្យមានជាដាច់ខាត ព្រោះវានាំឱ្យមិនមានភាពត្រឹមត្រូវទៅតាមច្បាប់នោះទេ ឬបំពានច្បាប់ដែលជាហេតុ នាំឱ្យមតកសាសន៍ដែលបានធ្វើឡើងនេះមិនមានអានុភាពគតិយុត្តផងដែរ។

មុននឹងបុគ្គលម្នាក់ អាចក្លាយជាសាក្សីក្នុងការចូលរួមធ្វើលិខិតមតកសាសន៍ បុគ្គលនោះត្រូវតែធ្វើការអះអាងនៅចំពោះមុខសារការីថាខ្លួនមិនបានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់នឹងម្ចាស់បណ្តាំ ហើយយល់ព្រមផ្តល់ចម្លើយជូនសមត្ថកិច្ចមន្ត្រីពាក់ព័ន្ធនៅពេលដែលមានការអនុវត្តខ្លឹមសារនៃលិខិតមតកសាសន៍ ក៏ព្រោះ តែសាក្សីមានតួនាទីក្នុងការអះអាងដឹងឮពីភាពត្រឹមត្រូវ ពេញលេញទៅលើសកម្មភាព និងសមត្ថភាពរបស់ម្ចាស់ បណ្តាំនៅក្នុងពេលតាក់តែងលិខិតមតកសាសន៍។

### ២.២.១.២.ប្រភេទនៃមតកសាសន៍

#### ក.មតកសាសន៍ដោយលិខិតយថាភូត

មតកសាសន៍ដោយលិខិតយថាភូត ជាលិខិតដែលធ្វើឡើងដោយសារការី ហើយត្រូវបានគេទទួលស្គាល់ថាជាប្រភេទលិខិតដែលអាចទុកចិត្តបានជាងគេ ដោយហេតុថាលិខិតនេះត្រូវបានធ្វើឡើងដោយអ្នកជំនាញពោលគឺ សារការី ដែលមតកសាសន៍ប្រភេទនេះត្រូវបានរក្សាទុកដោយសារការីតែម្តង។ សារការី ជាបុគ្គលដែលទទួលខុសត្រូវក្នុងការតាក់តែង និងមើលថែរក្សាលិខិតមតកសាសន៍នេះ រហូតដល់ម្ចាស់បណ្តាំទទួលមរណភាព និងបន្តអនុវត្តលិខិតបណ្តាំត្រូវបានបញ្ជាក់ជាស្ថាពរតាមផ្លូវច្បាប់។ ក្នុងករណីនេះសារការីដើរតួជាអ្នកប្រតិបត្តិមតកសាសន៍តែម្តង។

ដើម្បីធ្វើឱ្យមតកសាសន៍ដោយលិខិតយថាភូត មានសុពលភាពគតិយុត្ត ត្រូវតែធ្វើទៅតាមលក្ខខណ្ឌដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។ លក្ខខណ្ឌនៃការបង្កើតមតកសាសន៍ប្រភេទលិខិតយថាភូត ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍នៅចំពោះមុខសារការីដោយត្រូវមានវត្តមានសាក្សីយ៉ាងតិច ០២ (ពីរ) នាក់ ហើយសារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់។ បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរត្រឹមត្រូវហើយជននីមួយៗត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ ប៉ុន្តែ បើម្ចាស់បណ្តាំ

មិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូច កំណត់ខាងលើដោយសរសេរឈ្មោះអាយុ និងលំនៅឋានរបស់ខ្លួន ហើយត្រូវសរសេរបន្ថែមនូវហេតុនេះផង។ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។[38]

បុគ្គលដែលមិនអាចក្លាយជាសាក្សី ឬ អ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍មានដូចជា អនីតិជន ឬជននៅក្រោមអាណាព្យាបាលធម្មតា ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់មតកជន បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ ជាលិខិតយថាភូត ឬជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការី មិនអាចធ្វើជាសាក្សីបានឡើយ។[39]

**ខ.មតកសាសន៍ដោយលិខិតឯកជន**

មតកសាសន៍ដោយលិខិតឯកជន ជាលិខិតមតកសាសន៍ដែលម្ចាស់បណ្តាំជាអ្នកសរសេរផ្ទាល់នូវខ្លឹមសារ ពាក្យពេចន៍ទាំងមូលនៃមតកសាសន៍ព្រមទាំងចុះថ្ងៃ ខែ ឆ្នាំ និងហត្ថលេខាដោយផ្ទាល់ឯង។[40] មូលហេតុ តម្រូវធ្វើការចុះហត្ថលេខា និងចុះថ្ងៃខែឆ្នាំដោយខ្លួនឯងផ្ទាល់ គឺដើម្បីមានភាពងាយស្រួល ករណីមានបញ្ហា ទាក់ទងនឹងសុក្រឹត្យភាពនៃលិខិតមតកសាសន៍កើតឡើង គេមិនអាចទាមទារហៅសាមីខ្លួនដែលបានទទួល មរណភាពមកបញ្ជាក់ពីសេចក្តីថ្លែងការណ៍នោះទេ។ ករណីដែលលិខិតមតកសាសន៍ដោយលិខិតឯកជន ធ្វើឡើងដោយឱ្យអ្នកដទៃជាអ្នកសរសេរជំនួសម្ចាស់បណ្តាំ ឬដែលដោយប្រើម៉ាស៊ីន ដូចជាអង្គុលីលេខជាអាទិ៍ និងត្រូវចាត់ទុកជាមោឃៈ។[41] ចំពោះករណីដែលម្ចាស់បណ្តាំចង់បន្ថែមការលុប ឬការកែប្រែផ្សេងទៀតនៅក្នុងមតកសាសន៍ ម្ចាស់បណ្តាំត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការផ្លាស់ប្តូរនោះ ហើយចាំបាច់ត្រូវចុះហត្ថលេខា ដើម្បីជាការបញ្ជាក់ និងអាចជាភស្តុតាងក្នុងការផ្ទៀងផ្ទាត់នៅពេលក្រោយ ថាតើការផ្លាស់ប្តូរត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំពិតប្រាកដដែរ ឬទេ? ការតម្រូវឱ្យចុះហត្ថលេខាបញ្ជាក់នេះ ដើម្បីបញ្ចៀសករណីដែលមានជនដទៃ ឬសន្តតិជន ឬជនមានផលប្រយោជន៍ដទៃទៀតធ្វើការផ្លាស់ប្តូរខ្លឹមសារនៃលិខិតបណ្តាំ។

**គ.មតកសាសន៍ដោយលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់ ជាវិធីមួយដែលសារការីបញ្ជាក់ថាមានមតកសាសន៍ ប៉ុន្តែអ្វីៗក្នុងមតកសាសន៍នោះ ត្រូវបានរក្សាជាការសម្ងាត់។ ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខាក្នុងលិខិតដោយខ្លួនឯងផ្ទាល់។

---

[38] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧១ កថាខណ្ឌទី២។

[39] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧២។

[40] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៤ កថាខណ្ឌទី២។

[41] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៤ កថាខណ្ឌទី១ វាយខណ្ឌទី២។

ប៉ុន្តែ ម្ចាស់បណ្តាំត្រូវសុំឱ្យអ្នកណាម្នាក់ សរសេរខ្លឹមសារលើមតកសាសន៍ ឬអាចប្រើប្រាស់កុំព្យូទ័របាន។ ម្ចាស់បណ្តាំត្រូវដាក់លិខិតបណ្តាំនោះក្នុងស្រោមសំបុត្របិទជិត ព្រមទាំងសរសេរសញ្ញាសម្គាល់លើមាត់សំបុត្រ ដើម្បីឱ្យដឹងនៅពេលគេបើកស្រោមសំបុត្រ ហើយត្រូវដាក់នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ ដោយថ្លែងការណ៍ថា នេះគឺជាមតកសាសន៍ ជាអាទិ៍។ ប្រសិនបើម្ចាស់បណ្តាំមិនអាចនិយាយបាន គាត់ត្រូវប្រើភាសាសញ្ញា ឬត្រូវសរសេរ។[42] សារការី ម្ចាស់បណ្តាំ និងសាក្សី ត្រូវចុះហត្ថលេខាលើលិខិតបិទជិតនោះ។ បើទោះបីជាមិនស្របនឹងលក្ខខណ្ឌនៃមតកសាសន៍ដោយលិខិតសម្ងាត់ក៏ដោយ ក៏អាចមានស្គាល់ភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ ដរាបណាមតកសាសន៍នោះអនុលោមតាមបញ្ញត្តិស្តីពីលិខិតមតកសាសន៍ដោយលិខិតឯកជន។[43]

### ឃ.មតកសាសន៍ក្នុងស្ថានភាពពិសេស

បន្ទាប់ពីធ្វើការបកស្រាយទៅលើមតកសាសន៍ក្នុងទម្រង់ទូទៅ ឬធម្មតាមកក្រមរដ្ឋប្បវេណីក៏បានបើកផ្លូវផងដែរ ចំពោះស្ថានភាពពិសេសមួយចំនួន ដែលអាចឱ្យម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បានក្នុងស្ថានពិសេសចំនួន ៥ (ប្រាំ) ដូចជា៖ មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ, មតកសាសន៍ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត,  ជនដែលត្រូវជាប់ឃុំឃាំង និងជនជាប់ក្នុងនាវា, ឬ យន្តហោះ មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍, មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស, ។ មតកសាសន៍ក្នុងស្ថានភាពពិសេសមិនមែនជាទម្រង់នៃមតកសាសន៍ខុសពីទម្រង់ធម្មតាទេ គ្រាន់តែជាស្ថានភាពដោយឡែកមួយដែលច្បាប់ជួយសម្រួលឱ្យម្ចាស់បណ្តាំអាច មានលទ្ធភាពក្នុងការធ្វើមតកសាសន៍។

### ឃ.១.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

បើទោះបីជាជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ត្រូវបានចាត់ទុកថាជាជនដែលត្រូវបានកម្រិតសមត្ថភាពក៏ដោយ ក៏ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិ ឱ្យធ្វើបណ្តាំផងដែរនៅពេលដែលជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ នោះបានជាសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាង តិច ២ (ពីរ) នាក់។[44] វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិត មតកសាសន៍ថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ម្ចាស់បណ្តាំពុំបានស្ថិតក្នុង

---

[42] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៩ កថាខណ្ឌទី១។

[43] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣, កែសម្រួលលើកការបោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៧), ទំព័រ៥៣។

[44] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៦ កថាខណ្ឌទី១។

ស្ថានភាព ខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិត។[45]

ប្រសិនជនស្ថិតក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ដោយលិខិតឯកជន ឬលិខិតសម្ងាត់ ក្នុងករណីនេះ ចាំបាច់តម្រូវឱ្យមានវេជ្ជបណ្ឌិត ដើម្បីធ្វើជាសាក្សីនៅពេលសរសេរមតកសាសន៍ដោយផ្ទាល់ ឬនៅពេលដែលម្ចាស់បណ្តាំបង្ហាញខ្លឹមសារនៃមតកសាសន៍ឱ្យទៅសារការី។ រីឯករណីដែលជននោះធ្វើមតកសាសន៍ជាលិខិតយថាភូត ចាំបាច់តម្រូវឱ្យមានវត្តមានសាក្សីផ្សេងទៀតក្រៅពីវេជ្ជបណ្ឌិតផងដែរ។ ផ្ទុយទៅវិញប្រសិនបើគ្មានវត្តមានរបស់វេជ្ជបណ្ឌិត នៅពេលធ្វើលិខិតមតកសាសន៍តាមគ្រប់ទម្រង់នៃលិខិតមតកសាសន៍ដូចបានកំណត់ក្នុងក្រមរដ្ឋប្បវេណីនោះទេ លិខិតមតកសាសន៍ទាំងនោះនឹងត្រូវចាត់ទុកជាមោឃៈ។ មានតែវេជ្ជបណ្ឌិតប៉ុណ្ណោះដែលអាចមានសមត្ថភាពក្នុងការវិនិច្ឆ័យពីស្ថានភាពស្មារតី របស់ម្ចាស់បណ្តាំបាន។

**ឃ.២.មតកសាសន៍ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត**

ជនដែលកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជំងឺ ឬហេតុផ្សេងទៀត មតកជនមានបំណងចង់ធ្វើលិខិតបណ្តាំ ក៏អាចធ្វើបានដែរ ដោយតម្រូវឱ្យមានវត្តមានសាក្សីចំនួន៣ (បី)នាក់ ជាអ្នកបញ្ជាក់ក្នុងស្ថានភាពនាពេលនោះ។ មតកជនត្រូវប្រកាសអំពីខ្លឹមសារនៃមតកសាសន៍នោះដោយផ្ទាល់មាត់ ចំពោះជនម្នាក់ក្នុងចំណោមសាក្សីទាំងបី ហើយជនដែលទទួលបានការប្រកាសដោយផ្ទាល់មាត់ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬឱ្យមើលហើយក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗត្រូវចុះហត្ថលេខាលើលិខិតមតកសាសន៍។[46]

យ៉ាងណាមិញមតកសាសន៍ក្នុងស្ថានភាពជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិតនឹងមិនមានអានុភាពឡើយ ប្រសិនបើសាក្សីណាម្នាក់ ឬបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍ ហើយពុំបានទទួលការបញ្ជាក់ទេ។[47] គួរបញ្ជាក់ផងដែរថា ទោះក្នុងកាលៈទេសៈនេះក៏ដោយ ជនដែលត្រូវហាមឃាត់មិនឱ្យក្លាយជាសាក្សី ឬធ្វើជាអ្នកសង្កេតការណ៍ កំឡុងពេលធ្វើលិខិតបណ្តាំក៏ត្រូវយកមកអានុវត្តដូចគ្នានឹងករណីខាងលើ គឺមិនអាចក្លាយជាសាក្សីបានឡើយ។

[45] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៦ កថាខណ្ឌទី២។

[46] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៧ កថាខណ្ឌទី១។

[47] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៧ កថាខណ្ឌទី២។

### ឃ.៣.មតកសាសន៍ជនដែលត្រូវជាប់ឃុំឃាំង និងជនជាប់ក្នុងនាវា ឬយន្តហោះ

ជនដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែកដោយសាលក្រម ឬសាលដីកា ឬដោយការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បានដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច ២ (ពីរ) នាក់។ [48]ស្ថិតក្នុងស្ថានភាពបែបនេះគេក៏អាចធ្វើមតកសាសន៍តាមលិខិតយថាភូត ឬតាមលិខិតសំងាត់បានដែរដោយនគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ ដើរតួនាទីជាសារការី។

បុគ្គលដែលនៅក្នុងនាវា ឬយន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ និងសាក្សីយ៉ាងតិច ២ (ពីរ) នាក់។[49] បើទោះជាស្ថិតក្នុងស្ថានភាពបែបនេះ មតកជនមិនអាចស្វែងរកសារការីដើម្បីធ្វើលិខិតយថាភូត ឬលិខិតសម្ងាត់បានក៏ដោយ ក៏ក្រមរដ្ឋប្បវេណីបានបើកផ្លូវឱ្យមតកជនអាចធ្វើមតកសាសន៍ដោយលិខិតយថាភូត និងលិខិតឯកជនបានផងដែរ ដោយឱ្យមេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ដើរតួនាទីជាសារការីបាន។[50] ចំពោះម្ចាស់បណ្តាំ ដែលមិនមានជំងឺ ឬមិនចេះសរសេរអក្សរ ក្នុងស្ថានភាពឃុំឃាំង ឬជាប់ក្នុងនាវា ឬយន្តហោះ អាចប្រាប់ផ្ទាល់មាត់ទៅនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬយន្ត ហោះ ឬបុគ្គលិកនាវា ឬយន្តហោះនោះបាន។[51]

មតកសាសន៍ ក្នុងស្ថានភាពដូចបានរៀបរាប់ខាងលើ គ្រាន់តែជាមតកសាសន៍ដែលធ្វើឡើងជាបណ្តោះអាសន្នប៉ុណ្ណោះ ដូច្នេះមតកសាសន៍នឹងបាត់បង់នូវអានុភាព ប្រសិនបើម្ចាស់បណ្តាំអាចរស់នៅរយៈពេល ៦ខែ ក្រោយពេលចេញពីកន្លែងឃុំឃាំង ឬក្រោយពេលចុះពីនាវា ឬយន្តហោះ ជាអាទិ៍។[52]

### ឃ.៤.មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

សម្រាប់ជនពិការផ្នែកណាមួយដូចជា៖ មិនអាចនិយាយបាន តែអាចមើលឃើញ ហើយមានបំណងចង់ធ្វើលិខិតបណ្តាំ តើគាត់ត្រូវធ្វើយ៉ាងដូចម្តេច? យ៉ាងណាមិញឃើញថាទោះបីជាជនពិការក៏ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នៅតែការពារពួកគាត់ដូចបុគ្គលដទៃទៀតដែលមិនពិការដែរ។ ផ្អែកតាមគោលការណ៍

---

[48] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៨ កថាខណ្ឌទី១។

[49] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៨ កថាខណ្ឌទី២។

[50] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣, កែសម្រួលលើកការបោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៧), ទំព័រ៥៤។

[51] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៨ កថាខណ្ឌទី៣។

[52] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៨ កថាខណ្ឌទី៥។

សមភាព នៃសមត្ថភាពទទួលសិទ្ធិ គឺរូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។[53]

មតកសាសន៍ នៃជនដែលមិនអាចនិយាយបាន ត្រូវបានធ្វើឡើងសម្រាប់បុគ្គលមិនអាចនិយាយបាន ដោយប្រើប្រាស់ការធ្វើកាយវិការជំនួសឱ្យការនិយាយ និងមានការបកប្រែពីអ្នកបកប្រែ ឬការសរសេរខ្លឹមសារនៃលិខិតបណ្តាំដោយដៃរបស់ម្ចាស់បណ្តាំផ្ទាល់។ ថ្វីបើម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន ប៉ុន្តែច្បាប់បានអនុញ្ញាតឱ្យប្រើប្រាស់ភាសាសញ្ញាតាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនឯងផ្ទាល់ចំពោះមុខសារការី ឬសាក្សី ដើម្បីជំនួសការនិយាយប្រាប់ពីសេចក្តីថ្លែងការណ៍។[54] ចំពោះករណីខាងលើត្រូវបានប្រើប្រាស់សម្រាប់ម្ចាស់បណ្តាំដែលអាចសរសេរអក្សរបាន និងយល់ដឹងពីអ្វីដែលខ្លួនបានសរសេរ។

ក្រោយពីបានសរសេរលិខិតបណ្តាំជាលាយលក្ខណ៍អក្សររួច សារការីត្រូវអានខ្លឹមសារអត្ថន័យនៅក្នុងបណ្តាំឱ្យម្ចាស់បណ្តាំ និងសាក្សីបានស្តាប់ ឬឱ្យអ្នកបកប្រែជាអ្នកធ្វើកាយវិការតាមភាសាសញ្ញាបង្ហាញដល់ម្ចាស់បណ្តាំ ឬសាក្សីដែលមិនអាចស្តាប់ឮ តែអាចមើលឃើញ។ ករណីសារការី និងជនផ្សេងទៀតត្រូវសរសេរអំពីហេតុទាំងនោះចូលក្នុងលិខិតមតកសាសន៍ផងដែរ។[55]

ក្នុងករណីនេះ អ្នកបកប្រែភាសាសញ្ញាជាបុគ្គលដ៏សំខាន់ក្នុងការធ្វើលិខិតមតកសាសន៍នោះឡើង ប្រសិនបើគ្មានវត្តមានអ្នកបកប្រែភាសាសញ្ញាទេ លិខិតមតកសាសន៍នោះក៏មិនអាចធ្វើឡើងបានដែរ។ ទោះបីជាអាចធ្វើឡើងមកបាន ក៏មិនមានអានុភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍ដែរ ដោយសារតែសារការី និងសាក្សីមិនអាចយល់ពី ភាសាសញ្ញារបស់ម្ចាស់បណ្តាំ ហើយម្ចាស់បណ្តាំក៏មិនអាចយល់ពីខ្លឹមសារដែលសារការីបានសរសេរដែរ។ ដើម្បីឱ្យលិខិតមតកសាសន៍នោះ មានអានុភាពគ្រប់គ្រាន់ទើបចាំបាច់តម្រូវឱ្យមានវត្តមានរបស់អ្នកបកប្រែភាសាសញ្ញាក្នុងការធ្វើលិខិតមតកសាសន៍របស់ជនដែលមិនអាចនិយាយបាន។ ហើយអ្នកបកប្រែសញ្ញានេះទៀតសោតត្រូវបានចាត់ជាសាក្សីដ៏សំខាន់ក្នុងការធ្វើមតកសាសន៍ប្រភេទនេះ។

ចំពោះសាក្សីជាបុគ្គលមិនអាចស្តាប់ឮ(ថ្លង់) តែអាចមើលឃើញ ក៏មិនខុសអ្វីពីម្ចាស់លិខិតមតកសាសន៍ដែលធ្វើឡើងដោយជនដែលមិនអាចនិយាយបានដែរ ដោយតម្រូវឱ្យមានអ្នកបកប្រែភាសាកាយវិការ ឬភាសាសញ្ញា ដើម្បីធ្វើកាយវិការឱ្យសាក្សីនោះបានយល់ពីខ្លឹមសារនៅក្នុងមតកសាសន៍។

---

[53] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ៦។

[54] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៩ កថាខណ្ឌទី១។

[55] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៧៩ កថាខណ្ឌទី៣។

### ឃ.៥.មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស

ជនជាតិខ្មែរដែលមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត លិខិតសម្ងាត់អាចធ្វើនៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ ដែលកុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី។[56]

ម្យ៉ាងវិញទៀត ជនជាតិខ្មែរដែលរស់នៅបរទេសក៏អាចប្រើប្រាស់វិធីសាស្ត្រផ្សេងទៀត ក្នុងការធ្វើលិខិតមតកសាសន៍ទៅតាមទម្រង់មតកសាសន៍នានា ដូចបានកំណត់ក្នុងច្បាប់របស់ប្រទេសដែលខ្លួនរស់នៅ ប៉ុន្តែត្រូវធ្វើនៅចំពោះមុខសារការីនៃប្រទេសដែលខ្លួនរស់នៅ។ ចំពោះការធ្វើលិខិតមតកសាសន៍នេះ ត្រូវធ្វើឡើងនៅចំពោះមុខសារការីដែលជាជនបរទេស និងត្រូវការប្រើប្រាស់ភាសានៃប្រទេសដែលខ្លួនបានរស់ នៅក្នុងការសរសេរខ្លឹមសារនៃលិខិតមតកសាសន៍។ ការធ្វើបែបនេះ គឺដើម្បីអនុញ្ញាតឱ្យជនដែលមិនចេះភាសាបរទេសអាចមានលទ្ធភាពធ្វើមតកសាសន៍ជាលិខិតយថាភូត ឬលិខិតសម្ងាត់ជាភាសាខ្មែរបាន នៅកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តតួនាទីជំនួសសារការី ដើម្បីឱ្យលិខិតមតក សាសន៍នោះមានអានុភាពគ្រប់គ្រាន់ក្នុងការយកមកអនុវត្ត ហើយវត្តមានរបស់កុងស៊ុលគឺមានភាពចាំបាច់ ចំពោះការធ្វើលិខិតមតកសាសន៍របស់ម្ចាស់បណ្តាំដែលរស់នៅបរទេស។[57]

### ឃ.៦. មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

សម្រាប់ជនពិការផ្នែកណាមួយដូចជា៖ មិនអាចនិយាយបាន តែអាចមើលឃើញ ហើយមានបំណងចង់ធ្វើលិខិតបណ្តាំ តើគាត់ត្រូវធ្វើយ៉ាងដូចម្តេច? យ៉ាងណាមិញឃើញថាទោះបីជាជនពិការក៏ច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅតែការពារពួកគាត់ដូចបុគ្គលដទៃទៀតដែលមិនពិការដែរ។ ផ្អែកតាមគោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ គឺរូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។[58]

មតកសាសន៍ នៃជនដែលមិនអាចនិយាយបាន ត្រូវបានធ្វើឡើងសម្រាប់បុគ្គលមិនអាចនិយាយបានដោយប្រើប្រាស់ការធ្វើកាយវិការជំនួសឱ្យការនិយាយ និងមានការបកប្រែពីអ្នកបកប្រែ ឬការសរសេរខ្លឹមសារនៃលិខិតបណ្តាំដោយដៃរបស់ម្ចាស់បណ្តាំផ្ទាល់។ ថ្វីបើម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន ប៉ុន្តែច្បាប់បានអនុញ្ញាតឱ្យប្រើប្រាស់ភាសាសញ្ញាតាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនឯងផ្ទាល់ចំពោះ

---

[56] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ ២០០៧,មាត្រា ១១៨១។

[57]គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី,សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,មាត្រា ១១៨១)។

[58] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា

មុខសារការី ឬសាក្សី ដើម្បីជំនួសការនិយាយប្រាប់ពីសេចក្តីថ្លែងការណ៍។ ចំពោះករណីខាងលើត្រូវបានប្រើប្រាស់សម្រាប់ម្ចាស់បណ្តាំដែលអាចសរសេរអក្សរបាន និងយល់ដឹងពីអ្វីដែលខ្លួនបានសរសេរ។ ក្រោយពីបានសរសេរលិខិតបណ្តាំជាលាយលក្ខណ៍អក្សររួច សារការីត្រូវអានខ្លឹមសារអត្ថន័យនៅក្នុង បណ្តាំឱ្យម្ចាស់បណ្តាំ និងសាក្សីបានស្តាប់ ឬឱ្យអ្នកបកប្រែជាអ្នកធ្វើកាយវិការតាមភាសាសញ្ញាបង្ហាញដល់ម្ចាស់បណ្តាំ ឬសាក្សីដែលមិនអាចស្តាប់ឮ តែអាចមើលឃើញ។ ករណីសារការី និងជនផ្សេងទៀតត្រូវសរសេរ អំពីហេតុទាំងនោះចូលក្នុងលិខិតមតកសាសន៍ផងដែរ។[59]

ក្នុងករណីនេះ អ្នកបកប្រែភាសាសញ្ញាជាបុគ្គលដ៏សំខាន់ក្នុងការធ្វើលិខិតមតកសាសន៍នោះឡើង ប្រសិនបើគ្មានវត្តមានអ្នកបកប្រែភាសាសញ្ញាទេ លិខិតមតកសាសន៍នោះក៏មិនអាចធ្វើឡើងបានដែរ។ ទោះបីជាអាចធ្វើឡើងមកបាន ក៏មិនមានអានុភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍ដែរ ដោយសារតែសារការី និងសាក្សីមិនអាចយល់ពីភាសាសញ្ញារបស់ម្ចាស់បណ្តាំ ហើយម្ចាស់បណ្តាំក៏មិនអាចយល់ពីខ្លឹមសារដែលសារការីបានសរសេរដែរ។ ដើម្បីឱ្យលិខិតមតកសាសន៍នោះ មានអានុភាពគ្រប់គ្រាន់ទើបចាំបាច់តម្រូវឱ្យមានវត្តមានរបស់អ្នកបកប្រែភាសាសញ្ញាក្នុងការធ្វើលិខិតមតកសាសន៍របស់ជនដែលមិនអាចនិយាយបាន។ ហើយអ្នកបកប្រែសញ្ញានេះ ទៀតសោតត្រូវបានចាត់ជាសាក្សីដ៏សំខាន់ក្នុងការធ្វើមតកសាសន៍ប្រភេទនេះ។

ចំពោះសាក្សីជាបុគ្គលមិនអាចស្តាប់ឮ (ថ្លង់) តែអាចមើលឃើញ ក៏មិនខុសអ្វីពីម្ចាស់លិខិតមតកសាសន៍ដែលធ្វើឡើងដោយជនដែលមិនអាចនិយាយបានដែរ ដោយតម្រូវឱ្យមានអ្នកបកប្រែភាសាកាយវិការ ឬភាសាសញ្ញា ដើម្បីធ្វើកាយវិការឱ្យសាក្សីនោះបានយល់ពីខ្លឹមសារនៅក្នុងមតកសាសន៍។

### ឃ.៧.មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស

ជនជាតិខ្មែរដែលមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត លិខិតសម្ងាត់អាចធ្វើនៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ ដែលកុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី។[60]

ម្យ៉ាងវិញទៀត ជនជាតិខ្មែរដែលរស់នៅបរទេសក៏អាចប្រើប្រាស់វិធីសាស្ត្រផ្សេងទៀត ក្នុងការធ្វើលិខិតមតកសាសន៍ទៅតាមទម្រង់មតកសាសន៍នានា ដូចបានកំណត់ក្នុងច្បាប់របស់ប្រទេសដែលខ្លួនរស់នៅ ប៉ុន្តែត្រូវធ្វើនៅចំពោះមុខសារការីនៃប្រទេសដែលខ្លួនរស់នៅ។ ចំពោះការធ្វើលិខិតមតកសាសន៍នេះ ត្រូវធ្វើឡើងនៅចំពោះមុខសារការីដែលជាជនបរទេស និងត្រូវការប្រើប្រាស់ភាសានៃប្រទេសដែលខ្លួនបានរស់នៅក្នុងការ

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩ កថាខណ្ឌទី ៣។

[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨១

សរសេរខ្លឹមសារនៃលិខិតមតកសាសន៍។ ការធ្វើបែបនេះ គឺដើម្បីអនុញ្ញាតឱ្យជនដែលមិនចេះភាសាបរទេសអាចមានលទ្ធភាពធ្វើមតកសាសន៍ជាលិខិតយថាភូត ឬលិខិតសម្ងាត់ជាភាសាខ្មែរបាននៅ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តតួនាទីជំនួសសារការី ដើម្បីឱ្យលិខិតមតកសាសន៍នោះមានអានុភាពគ្រប់គ្រាន់ក្នុងការយកមកអនុវត្ត ហើយវត្តមានរបស់កុងស៊ុល គឺមានភាពចាំបាច់ ចំពោះការធ្វើលិខិតមតកសាសន៍របស់ម្ចាស់បណ្តាំដែលរស់នៅបរទេស។[61]

### ២.២.២.ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

មានតែចំណុចដែលច្បាប់បានកំណត់ទេដែលអាចសរសេរនៅក្នុងមតកសាសន៍នោះបានម្ចាស់បណ្តាំចង់ធ្វើអ្វីៗក្រៅពីចំណុចដែលបានកំណត់នេះក៏បានដែរ ប៉ុន្តែពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ។

❖ **ទាក់ទងនឹងសន្តតិកម្ម**[62]

ក.ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននិងការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន

ខ. ការកំណត់ចំណែកមត៌ក

គ. ការកំណត់នូវវិធីបែងចែកមត៌ក

ឃ. ការហាមឃាត់នូវការបែងចែកមត៌ក

ង. ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

❖ **ទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិ**[63]

ក. អច្ច័យទានសកល អច្ច័យទានពិសេស

ខ. ការវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ

❖ **ទំនាក់ទំនងនឹងឋានៈបុគ្គល**[64]

ក. ការទទួលស្គាល់កូន

ខ. ការកំណត់អ្នកអាណាព្យាបាលរបស់អនីតិជន

---

[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ១១៥១,១១៥៤,១១៨២,១១៨៣,១១៨៦។

[62] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) មាត្រា ១១៨១។

[63] ដដែល, មាត្រា ៩៩៧, ១០៦៨។

[64] ដដែល, មាត្រា ១១៨៨។

### ២.២.២.១.កាលបរិច្ឆេទ និងហត្ថលេខា

រាល់លិខិតបទដ្ឋានគតិយុត្តទាំងអស់ត្រូវតែមាន កាលបរិច្ឆេទមួយច្បាស់លាស់ រួមទាំងលិខិតមតកសាសន៍ផងដែរ។ ការចុះកាលបរិច្ឆេទទៅលើលិខិតមតកសាសន៍ ជាការចាំបាច់ដើម្បីបញ្ជាក់ពីសុពលភាពនៃមតកសាសន៍ ប៉ុន្តែករណីដែលលិខិតមតកសាសន៍ណាមួយ មិនបានចុះកាលបរិច្ឆេទ ដើម្បីធ្វើឱ្យលិខិតមតកសាសន៍នោះអាចមានសុពលភាពបាន លុះត្រាតែលិខិតមតកសាសន៍នោះមិនផ្ទុយនឹងខ្លឹមសារនៃលិខិតមតកសាសន៍ផ្សេងទៀតដែលមានការចុះកាលបរិច្ឆេទ។ លើសពីនេះបើលិខិតមតកសាសន៍ណាមួយដែលមិនបានចុះកាលបរិច្ឆេទច្បាស់លាស់ ហើយមានខ្លឹមសារផ្ទុយពីលិខិតមតកសាសន៍ដែលមានការចុះកាលបរិច្ឆេទ នោះលិខិតដែលមិនចុះកាលបរិច្ឆេទនឹងត្រូវចាត់ទុកជាមោឃៈ។ មួយវិញទៀត ក្នុងករណីដែលមានលិខិតមតកសាសន៍ច្រើនមិនមានកាលបរិច្ឆេទ ហើយមានខ្លឹមសារផ្ទុយគ្នា នោះលិខិតមតកសាសន៍នឹងត្រូវធ្វើការកាត់បន្ថយគ្នាទៅវិញទៅមក។[65]

ចំពោះហត្ថលេខាវិញ មតកជនមិនត្រូវបានអនុញ្ញាតឱ្យផ្តិតមេដៃជំនួសឱ្យការចុះហត្ថលេខាទេ។ ដោយសារតែមានភាពចាំបាច់ត្រូវធ្វើការផ្ទៀងផ្ទាត់មើលហត្ថលេខារបស់មតកជនទៅលើលិខិតផ្សេងៗដែលមតកជនធ្លាប់បានចុះហត្ថលេខា។ ការផ្តិតស្នាមម្រាមដៃ ធ្វើឱ្យពិបាកក្នុងការផ្ទៀងផ្ទាត់មើលពីភាពត្រឹមត្រូវនៃស្នាមម្រាមដៃរបស់មតកជន។ ប៉ុន្តែមតកសាសន៍នៅអាចប្រើប្រាស់ ការសរសេរនាមត្រកូល នាមខ្លួន និងការផ្តិតស្នាមម្រាមដៃ មកប្រើប្រាស់ជំនួសការចុះហត្ថលេខាបាន ក្នុងករណីដែលមានវត្តមានសារការី និងសាក្សីបានចុះហត្ថលេខា បញ្ជាក់ពីការផ្តិតម្រាមដៃរបស់មតកជនដោយយោងតាមទំនៀមទំលាប់ (រដ្ឋប្បវេណី) របស់ព្រះរាជាណាចក្រកម្ពុជា។

### ២.២.២.២.ចំណុចសំខាន់ផ្សេងទៀតដែលតម្រូវដោយច្បាប់

#### ក.ចំណុចនៃមតកសាសន៍

ចំណុចនៃមតកសាសន៍ គឺសំដៅដល់ខ្លឹមសារដែលមាននៅក្នុងមតកសាសន៍មួយ។ ក្រមរដ្ឋប្បវេណីបានកំណត់នូវចំណុចមួយចំនួន ដែលអាចត្រូវបានដាក់បញ្ចូលក្នុងមតកសាសន៍ ហេតុនេះក្នុងករណីដែលមតកជន ឬ ម្ចាស់បណ្តាំបានសរសេរចំណុចផ្សេងៗទៀតក្រៅពីចំណុចដែលច្បាប់បានកំណត់នោះចំណុចទាំងនេះនឹងពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ។

#### ខ.ការកំណត់ចំណែកមត៌ក

មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍បាន ទោះបីជាផ្ទុយនឹងបញ្ញត្តិ ស្តីពីផលប្រយោជន៍ពិសេសក៏ដោយ លើកលែងតែការកំណត់ចំណែកមត៌កនោះបំពានភាគបម្រុង។

[65] មាត្រា១១៧០.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ផ្ទុយទៅវិញ បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវធ្វើឡើងតាមគោលការណ៍នៃការសម្រួលមត៌ក ហើយបើបំពានភាគបម្រុង ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

បុគ្គលណាម្នាក់ក្នុងចំណោមសហសន្តតិជនដែលបានទទួល ផលប្រយោជន៍ពិសេសដូចជា ការទទួលបានប្រទានកម្ម ឬអច្ច័យទានពីមតកជន (ឱកាសអាពាហ៍ពិពាហ៍ ឬការផ្តល់ដើមទុនក្នុងការរកស៊ី) ដោយមានការបង្ហាញឆន្ទៈត្រឹមត្រូវពេលធ្វើសកម្មភាពនោះ ជាហេតុនាំឱ្យតម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មដោយបូកបញ្ចូលនូវតម្លៃប្រទានកម្មត្រូវបានចាត់ទុកជាមត៌ក។[66]

បើប្រទានកម្ម ឬអច្ច័យទានស្មើគ្នានឹងតម្លៃចំណែកមត៌ក ឬលើសពីតម្លៃនៃចំណែកមត៌កទៀត សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កបានឡើយ។[67] លើសពីនេះ ការកំណត់ចំណែកមត៌កនេះមិនអាចធ្វើការបំពានភាគបម្រុងបាននោះទេ ដោយត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង។[68]

### គ.ការកំណត់វិធីបែងចែកដោយមតកសាសន៍

មតកជនអាចកំណត់វិធីបែងចែកតាមមតកសាសន៍ ឬប្រគល់អាណត្តិឱ្យតតិយជនកំណត់ ឬអាចហាមឃាត់មិនឱ្យបែងចែក នៅអំឡុងពេលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម។[69]

**ឧទាហរណ៍៖** មតកជន មានកូន ០៣នាក់ (ក ខ និង គ) ដោយនៅក្នុងមតកសាសន៍នោះ កំណត់ជាក់លាក់ពីវត្ថុដែលជាចំណែករបស់កូននីមួយៗ ដោយនៅក្នុងមតកសាសន៍បានបញ្ជាក់ថា (ក) ជាអ្នកប្រតិបត្តិមតកសាសន៍ (កូនច្បង) ហើយត្រូវគ្រប់គ្រងទ្រព្យសម្បត្តិនេះរហូតដល់ប្អូនៗមាននីតិភាព ទើបធ្វើការបែកចែកចំណែកស្មើៗគ្នា ដែលមតកសាសន៍នេះមានអានុភាពនៅថ្ងៃទី ០១.០១.២០១០ ហើយប្អូនៗរបស់ (ក) នឹងពេញ វ័យនីតិភាពទាំងអស់គ្នា នៅឆ្នាំ ២០១៤។ មានន័យថា (ក) មិនអាចចាត់ចែងមត៌កនោះបានទេ ទោះបីជាសន្តតិកម្មបានចាប់ផ្តើមហើយក៏ដោយ ក៏ត្រូវរង់ចាំប្អូនៗ បានទទួលនីតិភាពផងដែរ។ មួយវិញទៀត មតកជនអាចធ្វើការកំណត់មត៌ករបស់ខ្លួនជាភាគ ដោយប្រើការបែងចែកទ្រព្យសម្បត្តិជាភាគទៅឱ្យសន្តតិជនម្នាក់ៗ។

**ឧទាហរណ៍៖** សុខជាមតកជន ដោយសន្តតិជនរបស់គាត់មានប្រពន្ធ និងកូនបីនាក់។ ដូចនេះកូនទាំងបីរបស់គាត់ទទួលបានចំណែក១/៤ ប៉ុន្តែគាត់បានកំណត់ឱ្យប្រពន្ធរបស់គាត់ទទួលបានចំណែក១/២។

[66] មាត្រា១១៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[67] មាត្រា១១៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[68] មាត្រា១១៨២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[69] មាត្រា១១៨៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឃ.អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន**

មតកជនអាចធ្វើអនុប្បទាននូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែក ឬធ្វើប្រទានកម្ម ឬអច្ច័យទានតាមមតកសាសន៍ ឱ្យទៅជនដែលត្រូវបានសន្មតថាជាសន្តតិជន ឬតតិយជនបានផងដែរ។ មួយវិញទៀតបើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទាននូវទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬច្រើនឱ្យសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះ ត្រូវបានសន្មតថាជាការកំណត់នូវវិធីនៃការបែងចែកមត៌ក លើកលែងតែមតកសាសន៍នោះ មានអត្ថន័យជាអច្ច័យទានច្បាស់លាស់ ដូចជាអច្ច័យទានភ្ជាប់បន្ទុកជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យនោះ មានចំនួនតិចជាងចំណែកមត៌កដែលសន្តតិជននោះត្រូវទទួលខុសត្រូវលុះត្រាតែពុំមានការកំណត់ផ្សេងៗ នៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាកំណត់វិធីបែងចែកមត៌ក ដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ។[70]

**ខ.ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍**

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើននាក់ ឬអាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន។[71] ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍នេះ មិនមែនមានលក្ខណៈចាប់បង្ខំនោះទេ អ្នកដែលត្រូវបានជ្រើសរើសអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិក្នុងការបដិសេធ ដោយធ្វើការជូនដំណឹងដល់សន្តតិជនដោយគ្មានការយឺតយ៉ាវ ប៉ុន្តែកាលបើជននោះបាន បង្ហាញឆន្ទៈយល់ព្រមក្លាយជាអ្នកប្រតិបត្តិមតកសាសន៍នោះ ដើម្បីលាឈប់ត្រូវមានការអនុញ្ញាតពីតុលាការ។[72]

---

[70] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី សន្តតិកម្ម(មេរៀនសង្ខេប) បង្រៀនដោយៈ មេធាវី អ៊ីវ បូលី ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ១៨

[71] មាត្រា១១៨៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[72] មាត្រា១២១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី៣

# អានុភាពនៃមតកសាសន៍

# ជំពូកទី៣
# អានុភាពនៃមតកសាសន៍

បន្ទាប់ពីមតកជនបានទទួលមរណភាព ឬមានការប្រកាសបាត់ខ្លួនពីតុលាការ ឬលក្ខខណ្ឌបង្អង់នៃមតកសាសន៍ ដែលជាប្រធានទើបអានុភាពនៃមតកសាសន៍ត្រូវបានចាប់ផ្តើម ។ ដូច្នេះ នៅពេលមតកសាសន៍ត្រូវបង្កើតអានុភាព តើវានឹងមានអានុភាពយ៉ាងដូចម្តេច? ជាទូទៅ មតកសាសន៍ គឺមានខ្លឹមសារផ្ទេរនូវសិទ្ធិ និងកាតព្វកិច្ចទៅឱ្យអ្នកស្នង ហេតុនេះក្នុងការសិក្សាពីអានុភាពរបស់វា យើងនឹងផ្តោតសំខាន់ទៅលើអានុភាពប្រាំ គឺអានុភាពនៃការកំណត់ចំណែកមត៌ក, អានុភាពនៃការកំណត់ចំណែកមត៌កករណីសន្តតិជនទទួលមរណភាព, អានុភាពចំពោះអាណាព្យាបាលទូទៅ, អានុភាពនៃអច្ច័យទាន និងអានុភាពមតកសាសន៍ និងភាគបម្រុង ។

## ក.អានុភាពនៃការកំណត់ចំណែកមត៌ក

ក្នុងករណីដែល មតកជនបានកំណត់ពីចំណែក ព្រមទាំងវិធីសាស្ត្រក្នុងការកំណត់ចំណែក ទៅលើទ្រព្យសម្បត្តិជាក់លាក់មួយ ឬច្រើន ទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមរយៈមតកសាសន៍នោះអានុភាព នៃការកំណត់លើទ្រព្យសម្បត្តិជាក់លាក់នោះ នឹងត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលនូវទ្រព្យសម្បត្តិនោះដោយស្វ័យប្រវត្តិព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ឬនៅពេលលក្ខខណ្ឌបង្អង់ត្រូវបានបំពេញ។[73] អានុភាពនេះ វាបានទទួលស្គាល់នូវអាទិភាពចម្បងនៃការអនុវត្តមតកសាសន៍ ដែលបានចងជាកាតព្វកិច្ច ឱ្យអ្នកប្រតិបត្តិមតកសាសន៍ ឬតុលាការចេញនូវសេចក្តីសម្រេចទទួលស្គាល់នូវចំណែក និងវិធីនៃការចាត់ចែង ដែលមានស្រាប់ក្នុងមតកសាសន៍ ។ ហេតុនេះនៅពេលប្រតិបត្តិ អ្នកប្រតិបត្តិត្រូវផ្តល់អាទិភាពជាងគេនូវចំណែកដែលបានកំណត់ជាក់លាក់ទាំងនេះ ហើយក្នុងករណីនេះផងដែរ វាក៏ផ្តល់ភាពងាយស្រួលដល់ការចាត់ចែងសន្តតិកម្ម ឬអនុវត្តសន្តតិកម្ម ក្នុងទំហំនៃទ្រព្យសម្បត្តិដែលបានចាត់ចែង និងវិធានបែងចែករបស់មតកជន ។

## ខ.ការកំណត់ចំណែកមត៌កករណីសន្តតិជនទទួលមរណភាពជាអាទិ៍

ក្នុងលក្ខខណ្ឌនៃសន្តតិកម្ម ដែលមតកជនបានកំណត់នូវចំណែកលើទ្រព្យសម្បត្តិជាក់លាក់របស់ខ្លួន ព្រមទាំងវិធីនៃការបែងចែងផងនោះ ក្នុងករណីដែលសន្តតិជនដែលត្រូវបានកំណត់ស្ថិតក្នុងស្ថានភាពមិនអាចបង្កើតអានុភាពដោយហេតុថា សន្តតិជននោះបានទទួលមរណភាពមុនមតកជន ឬសន្តតិជនក្លាយជាអភព្វបុគ្គល ឬសន្តតិជននោះត្រូវបានមតកជនកាត់កាល បើសិនមកតជនមិនបានបង្ហាញឆន្ទៈផ្សេងពីនោះទេ សិទ្ធិ

[73] មាត្រា ១១៩៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

របស់សន្តតិជនទាំងនោះ គឺត្រូវផ្ទេរដោយស្វ័យប្រវត្តិទៅសន្តតិជនជំនួសរបស់ពួកគេ ដែលត្រូវជាចៅ ឬចៅទួត របស់មតកជន ។[74]

**ឧទាហរណ៍ថា ៖** មតកជន A បានធ្វើបណ្តាំមត៌ក លើដីមួយកន្លែង ទៅឱ្យកូនប្រុសពីរនាក់ គឺ B និង C ដោយកំណត់ទទួលបានម្នាក់ ៥0% នៃដីនោះ ។ ប៉ុន្តែជាអកុសល B បានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ដោយបានបន្សល់ទុកកូនម្នាក់ D មួយឆ្នាំមុនពេលមតកជនទទួលមរណភាព ។ ដោយហេតុថា មតកជនមិនបានកែប្រែខ្លឹមសារនៃមតកសាសន៍នោះទេ វាក៏មានន័យថា មតកជន A មានបំណងចង់ប្រគល់ចំណែករបស់ B ទៅកូនរបស់ B ដែល ហេតុនេះ ចំណែករបស់ B ត្រូវធ្លាក់ទៅ D ដោយស្វ័យប្រវត្តិ ។

ប៉ុន្តែជាអញ្ញត្រកម្ម ស្តីពីសន្តតិកម្មជំនួស បានកំណត់ថា បុគ្គលដែលអាចកំណត់យកជាសន្តតិកម្មជំនួសបាន លុះត្រាតែបុគ្គលនោះជាបច្ឆាញាតិផ្ទាល់របស់សន្តតិជននោះប៉ុណ្ណោះ ។[75] ហេតុនេះក្នុងករណីដែលសន្តតិជន B ខាងលើមិនមានបច្ឆាញាតិទេ នោះចាត់ទុកថា មិនមានសន្តតិកម្មជំនួស នោះមតកសាសន៍ត្រង់ការកំណត់ចែកទ្រព្យសម្បត្តិនេះមិនអាចមានអានុភាពឡើយ ។ ក្នុងករណីនេះបញ្ញត្តស្តីពីការបោះបង់សន្តតិកម្ម គឺត្រូវយកមកអនុវត្ត មានន័យថាសន្តតិកម្មមិនមានអានុភាពតាំងពីដំបូង ។

**ឧទាហរណ៍៖** ក្នុងឧទហរណ៍ខាងលើ បើសិន B ពុំមានបច្ឆាញាតិនោះទេ នោះចំណែករបស់គាត់ គឺពុំមានអានុភាពឡើយ ឬនិយាយដោយងាយយល់ ចំណែករបស់ B ចាត់ទុកថាមិនទាន់មានបណ្តាំឡើយ អាចធ្វើជាកម្មវត្ថុ នៃសន្តតិកម្មតាមច្បាប់បាន។

### គ. អានុភាពចំពោះអាណាព្យាបាលទូទៅ

ទោះបីជាមាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណីបានទទួលស្គាល់សិទ្ធិរបស់ជននៅក្រោមអាណាព្យាបាល ទូទៅក្នុងការធ្វើមតកសាសន៍ក៏ពិតមែន ប៉ុន្តែដោយហេតុថា ជននៅក្រោមអាណាព្យាបាលទូទៅត្រូវបានចាត់ទុកថាជាជនត្រូវបានកម្រិតសមត្ថភាព ដែលស្ថិតនៅក្នុងស្ថានភាពជានិរន្ត ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ជាហេតុធ្វើឱ្យការយល់ដឹងរបស់គាត់អាចមានការប្រែប្រួល ។ មូលហេតុទាំងនេះហើយទើបក្រមរដ្ឋប្បវេណីបានបញ្ញត្តិ ក្នុងករណីជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬសហព័ទ្ធ ឬបច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវ ចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ លើកលែងតែអ្នកអាណាព្យាបាលនោះ គឺជាសហព័ទ្ធ

[74] មាត្រា ១១៩៦ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧ និងមាត្រា ១១៩៦ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

[75] មានត្រា ១១៥៧-១-២ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

ឬជាបច្ឆាញាតិ ឬជាបងប្អូនបង្កើត របស់ជននៅក្រោមអាណាព្យាបាលទូទៅ ។ [76] បញ្ញត្តនេះចែងក្នុងអត្ថន័យបង្ការនូវការឆ្លៀតឱកាសដោយហេតុថា អ្នកអាណាព្យាបាលគឺជាអ្នកមើលការខុសត្រូវ និងជួយសម្រួលដល់ការរស់នៅរបស់ជននៅក្រោមអាណាព្យាបាលទូទៅទាំងរូបកាយ និងទ្រព្យសម្បត្តិហើយមានការប្រាស្រ័យទាក់ទងយ៉ាងជិតស្និតជាមួយជននៅក្រោមអាណាព្យាបាល ដែលអាចផ្តល់លទ្ធភាព ឱ្យអ្នកអាណាព្យាបាលប្រើឧបាយកលផ្សេងៗ ដើម្បីបញ្ចុះបញ្ចូលឱ្យមតកជន ធ្វើនូវមតកសាសន៍ដោយផ្តល់ ផលប្រយោជន៍ដល់ខ្លួន ប្រពន្ធ ឬកូនចៅរបស់ខ្លួន ។ ប៉ុន្តែបើសិនជា អ្នកអាណាព្យាបាល ត្រូវជាសហព័ទ្ធជាកូន ឬជាបងប្អូនបង្កើតជាមួយជននៅក្រោមអាណាព្យាបាលទូទៅនោះ ច្បាប់ទទួលស្គាល់ដោយហេតុថា ក្រុម បុគ្គលទាំងនេះ បានមើលថែរក្សាបីបាច់ជននៅក្រោមអាណាព្យាបាលទូទៅដោយមិនមែនដើម្បីតែប្រយោជន៍ និងហានិភ័យក្នុងការប្រើប្រាស់ឧបាយកលទុច្ចរិតដើម្បីឱ្យ មតកជនធ្វើមតកសាសន៍ត្រូវបានកាត់បន្ថយ ។

## ៣.១.ការយល់ព្រម និងការបោះបង់សន្តតិកម្ម

សន្តតិកម្មកម្មតាមបណ្តាំ គឺជាសកម្មភាពឯកតោភាគី របស់មតកជនបង្ហាញឆន្ទៈចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួនជាមុនពេលមានជីវិត ដើម្បីអនុវត្តនៅពេលខ្លួនទទួលមរណភាព ដូច្នេះវាមិនមែនជាសកម្មភាពទ្វេភាគី ដូចជាសកម្មភាពកិច្ចសន្យា ដែលមានអានុភាពចាប់បង្ខំឱ្យគោរព និងអនុវត្តតាម លើភាគីម្ខាងទៀតនៃកិច្ចសន្យាអញ្ចមញ្ចឡើយ។ ហេតុនេះទើបច្បាប់ផ្តល់សិទ្ធិឱ្យសន្តតិជន ឬអច្ច័យលាភី អាចបង្ហាញឆន្ទៈថា ទទួលយក ឬបោះបង់សន្តតិកម្មនោះបានទោះជាសិទ្ធិ ឬកាតព្វកិច្ចក៏ដោយ។ នេះជាផ្នែកមួយដែលបង្ហាញថាក្រមរដ្ឋ ប្បវេណីបានគោរពនូវគោលការណ៍ស្វ័យភាពបុគ្គលក្នុងការទទួលយក ឬបោះបង់នូវសកម្មភាពរបស់មតកជនមកលើខ្លួន ព្រោះដើម្បីការពារនូវសេចក្តីថ្លៃថ្នូរ និងស្ថិរភាពសេដ្ឋកិច្ចរបស់សន្តតិជន។ ហើយការបង្ហាញឆន្ទៈនេះ យើងនឹងបែងចែកជាពីរកថាភាគសំខាន់ៗ គឺកថាភាគទី ១ លក្ខខណ្ឌនៃការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់ មតកសាសន៍ និងកថាភាគទី ២ អានុភាពនៃការយល់ព្រម និងបោះបង់សន្តតិកម្ម ។

### ៣.១.១លក្ខខណ្ឌនៃការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់មតកសាសន៍

ការបង្ហាញឆន្ទៈយល់ព្រម និងបោះបង់មតកសាសន៍ ត្រូវអនុវត្តតាមលក្ខខណ្ឌមួយចំនួនដែលត្រូវ គោរព និងជាការទុកពេលវេលាសមរម្យដើម្បីឱ្យសន្តតិជនពិចារណា និងស្រាវជ្រាវពីផលប្រយោជន៍ និងបន្ទុកនានាដែលអាចធ្លាក់មកលើខ្លួន មុនសម្រេចថាយល់ព្រមទទួល ឬបោះបង់មតកសាសន៍ចំពោះខ្លួន ហើយរបបនេះក៏បញ្ញត្តពីស្ថានភាពខ្លះដែលផ្តល់សិទ្ធិឱ្យសន្តតិជនធ្វើការលុបចោលនូវការយល់ព្រម ឬបោះបង់មតកសាសន៍ នេះវិញបានដែរ ។ ហេតុនេះចំពោះលក្ខខណ្ឌទូទៅនៃការបង្ហាញឆន្ទៈការយល់ព្រម និងបោះបង់មតកសាសន៍នេះ

---

[76] មាត្រា ១១៩៧ ក្រមរដ្ឋប្បវេណី ២០០៧

យើងនឹងលើកយកគោលការណ៍សំខាន់ រួមមាន ៣.១.២. អំឡុងពេលនៃការយល់ព្រម ឬ បោះបង់មតកសាសន៍ ៣.១.៣. លក្ខខណ្ឌនៃការលុបចោលនូវការយល់ព្រម ឬ បោះបង់មតកសាសន៍ និង ៣.១.៤. ការបោះបង់សន្តតិកម្ម ។

### ៣.១.២. អំឡុងពេលនៃការយល់ព្រម ឬ បោះបង់មតកសាសន៍

សន្តតិជន មានពេល ៣(បី) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងថា សន្តតិកម្មបានបង្កើតអានុភាពចំពោះខ្លួនបានចាប់ផ្ដើម ប៉ុន្តែបើមានភាពចាំបាច់ ដូចជាត្រូវការសិក្សាពីប្រភេទ ប្រភព ទីកន្លែង សិទ្ធិ ឬបន្ទុក ជាអាទិ៍ នៃមតកសាសន៍ដែលនឹងមានចំពោះខ្លួន សន្តតិជនអាចស្នើសុំពន្យារពេលបាន ដោយដាក់ពាក្យសុំទៅតុលាការ ។ លើសពីនេះក្នុងករណីអំឡុងពេលដែលបានកំណត់នេះ សន្តតិជនបានទទួលមរណភាព ដោយពុំទាន់បានបង្ហាញឆន្ទៈ ថាយល់ព្រម ឬបោះបង់សន្តតិកម្មនេះទេ រយៈពេល ៣(បី) នោះ ត្រូវគិតពីពេលដែលសន្តតិជនជំនួសបានដឹងថា សន្តតិកម្មមានចំពោះខ្លួន ។[77]

ដោយឡែក ករណីសន្តតិជន ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល ៣ (បី) ខែ ត្រូវគណនាដោយគិតពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានដឹងថា សន្តតិកម្មមានចំពោះអនីតិជន ឬជននៅក្រោអាណាព្យាបាលទូទៅនោះបានចាប់ផ្ដើម ។[78]

ទោះបីជាមានការកំណត់ពីអំឡុងពេលដើម្បីបង្ហាញឆន្ទៈក្នុងការយល់ព្រម ឬបោះបង់មតកសាសន៍បានកន្លងផុតទៅក៏ដោយ បើសិនជាការទទួលយកមតកសាសន៍ បន្ទាប់មកលេចឡើងនូវបន្ទុក ឬអត្ថិភាពនៃកាតព្វកិច្ចថ្មី បានកើតឡើងដោយសន្តតិជន ពុំអាចដឹងបានក្នុងលក្ខណៈនៃជីវភាពទូទៅរបស់មតកជន នោះអំឡុងពេល ០៣ (បី) ខែ ដែលត្រូវកំណត់ ត្រូវគិតពីពេលដែលសន្តតិជនបានដឹងពីហេតុបន្ទុក ឬអត្ថិភាពនៃកាតព្វកិច្ចថ្មីនោះកើតមានឡើង ។[79]

### ៣.១.៣. លក្ខខណ្ឌនៃការលុបចោលនូវការយល់ព្រម ឬ បោះបង់មតកសាសន៍

ការបង្ហាញឆន្ទៈទទួលយក ឬបោះបង់មតកសាសន៍ គឺមិនអាចលុបចោលវិញបានឡើយ ទោះបីជាការបង្ហាញឆន្ទៈនោះស្ថិតក្នុងអំឡុងពេល ៣(បី) ដែលបានកំណត់ក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីក៏ដោយ ព្រោះការបង្ហាញឆន្ទៈរួចមកហើយ វាអាចបណ្ដាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍ភាគីពាក់ព័ន្ធ ដោយហេតុនានា នៃសកម្មភាពប្រតិបត្តិនៃមតកសាសន៍បានដំណើរការ ឬមានវិបាកស្មុគស្មាញដល់ការរៀបចំឡើងវិញនៃការអនុវត្តមតកសាសន៍ជាអាទិ៍ ។ ប៉ុន្តែបើសិនការបង្ហាញឆន្ទៈក្នុងការទទួលយក ឬបោះបង់ មតកសាសន៍នោះ

---

[77] មាត្រា ១១៤៨ និង មាត្រា ១២៤៩ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[78] មាត្រា ១២៥១ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[79] មាត្រា ១២៥១-១ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

កើតឡើងក្នុងស្ថានភាពនៃវិការៈនៃការបង្ហាញឆន្ទៈដូចជា ការភាន់ច្រឡំ ការឆបោក ការគំរាមកំហែង ជាអាទិ៍ នោះអាចធ្វើការលុបចោលនូវការយល់ព្រមទទួល ឬ បោះបង់មតកសាសន៍នោះបាន ។ ប៉ុន្តែ សន្តតិជនត្រូវអនុវត្ត សិទ្ធិលុបចោល ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីដឹងថាខ្លួនអាចផ្តល់សច្ចានុមតិបាន និងមិនអាចអនុវត្ត សិទ្ធិលុបចោលបានឡើយបើសកម្មភាពនៃការយល់ព្រមទទួល ឬបោះបង់មតកសាសន៍នោះ លើស ពី ៥(ប្រាំ) ឆ្នាំ កន្លងផុតទៅហើយនោះ ។[80]

**ឧទាហរណ៍ ៖** ប្រសិនបើ សន្តតិជន A បានបោះបង់ចោលនូវមតកសាសន៍ ដែលផ្តល់ឱ្យខ្លួនជាដី តម្លៃ២០០០០ ដុល្លារ តែត្រូវទទួលបន្ទុកសងប្រាក់ទៅ ម្ចាស់បំណុល B ៣០០០ ដុល្លារ ។ ប៉ុន្តែដោយហេតុថា អំឡុងពេល សន្តតិកម្មមានអានុភាពចំពោះគាត់ និងក្នុងអំឡុងពេលតម្រូវឱ្យមានការបង្ហាញឆន្ទៈឱ្យ A ទទួលស្គាល់ ឬ បោះបង់ចោលមតកសាសន៍ ស្របពេលគាត់ជាប់បំពេញកិច្ចការនៅក្រៅប្រទេស ហើយ A ត្រូវបានសន្តតិជន B ឆបោកថា ដីនោះតម្លៃតែ ២០០០ដុល្លារ ទេទើប A សម្រេចបោះបង់មតកសាសន៍នោះតែម្តង ។ ហេតុនេះ ក្នុងរយៈ ៦ខែ គិតចាប់ពីគិតអាចផ្តល់សច្ចានុមតិបាន ឬចាប់ពីពេលដឹងថាខ្លួនមានសិទ្ធិលុបចោល A អាច លុបចោលនូវការ បោះបង់មកតសាសន៍នោះបាន ដោយការបង្ហាញឆន្ទៈមានវិការៈ។

### ៣.១.៣.១ការយល់ព្រមទាំងស្រុង

ការយល់ព្រមទាំងស្រុង គឺសំដៅលើការយល់ព្រមបន្តនូវសិទ្ធិ និងកាតព្វកិច្ចទាំងស្រុង ដោយគ្មាន កម្រិតរបស់សន្តតិជន ជុំវិញមត៌កដែលមតកជនធ្វើចំពោះសន្តតិជន ។ ក្នុងន័យនេះ ករណីដែលមតកសាសន៍ ធ្វើសម្រាប់សន្តតិជននូវចំណែកទ្រព្យសម្បត្តិ និងបន្ទុកដែលជាកាតព្វកិច្ចនោះ ទៅឱ្យសន្តតិជនម្នាក់ ឬច្រើន នាក់ ក្នុងករណីសន្តតិជនបានទទួលយល់ព្រមទាំងស្រុងនូវមតកសាសន៍ចំពោះខ្លួននោះ សន្តតិជនត្រូវទទួល ទាំងស្រុងដោយមិនគិតពីតម្លៃ ឬទម្ងន់បន្ទុក រវាងសិទ្ធិ និងកាតព្វកិច្ចនោះឡើយ មានន័យថា ទោះបីជាទ្រព្យ សម្បត្តិដែលផ្តល់ឱ្យដោយមតកសាសន៍ មានតម្លៃតិចជាងតម្លៃនៃកាតព្វកិច្ចនោះក្តី ។[81]

ឧទាហរណ៍៖ មតកជន A បានផ្តល់ផ្ទះដែលខ្លួនធ្លាប់រស់នៅជុំគ្រួសារតម្លៃ ៥០០០ ដុល្លារ ទៅឱ្យកូនប្រុស ម្នាក់ B ប៉ុន្តែ B ត្រូវសងបំណុលទៅឱ្យម្ចាស់បំណុលរបស់ A ចំនួន ១០០០០ ដុល្លារ ។ ទោះបីជាផ្ទះមានតម្លៃ តិច ជាង បំណុលពាក់កណ្តាលក្តី B យល់ព្រមដោយខ្លួនគិតថា ផ្ទះនោះមានអនុស្សាវរីយ៍ខ្លាំងចំពោះគាត់ ដោយមិនគិតពីបន្ទុក ។

[80] មាត្រា ១២៥២-១ និង មាត្រា ១២៥២-២ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[81] មាត្រា ១២៥៤ ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧ និង មាត្រា ១២៥៤ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០

លើសពីនេះការយល់ព្រមទាំងស្រុងលើអានុភាពមតកសាសន៍ គឺត្រូវបានបែងចែកជាពីរ គឺការយល់ព្រមទាំងស្រុងដោយការបង្ហាញឆន្ទៈ និងការយល់ព្រមទាំងស្រុងកំណត់ដោយច្បាប់ ។

➢ **<u>ការយល់ព្រមទាំងស្រុងដោយការបង្ហាញឆន្ទៈ</u>**

នៅពេលដែលសន្តតិជន បានដឹងពីការចាប់ផ្តើមនៃអានុភាពសន្តតិកម្មសម្រាប់ខ្លួន អំឡុងពេលកំណត់ ៣ (បី) ខែ ឬលើសក្នុងករណីស្នើសុំទៅតុលាការ ដូចមានចែងក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណី ហើយអំឡុងពេលនោះសន្តតិជនអាចបង្ហាញឆន្ទៈក្នុងការទទួលយកសន្តតិកម្មនោះបាន ។

➢ **<u>ការយល់ព្រមទាំងស្រុងកំណត់ដោយច្បាប់</u>**

ផ្ទុយពីការយល់ព្រមទាំងស្រុងដោយការបង្ហាញឆន្ទៈ ករណីដែលសន្តតិកម្មបានបំពេញ ឬមិនបានបំពេញនូវសកម្មភាពដូចខាងក្រោមច្បាប់បានបញ្ញត្តិថា សន្តតិជនបានយល់ព្រមទទួលទាំងស្រុងនូវមតកសាសន៍ នោះគឺៈ

✓ បើសន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ ប៉ុន្តែបញ្ញត្តិនេះមិនអនុវត្តឡើយក្នុងករណីចំពោះសកម្មភាពរក្សារ និងសកម្មភាពត្រឹមតែជាការគ្រប់គ្រង ឬការចាត់ចែងដោយការភាន់ច្រឡំ ដែលមិនអាចដឹងពី អត្ថិភាពពិតប្រាកដនៃកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ១២៥១ ។

✓ បើសន្តតិជនមិនបានយល់ព្រមដោយមានកម្រិត ឬបោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ ។

✓ ទោះបីជាសន្តតិជនបានយល់ព្រមដោយមានកម្រិត ឬបោះបង់ ក៏ដោយបើសន្តតិជន បានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ប៉ុន្តែករណីនេះសកម្មភាពរបស់សន្តតិជនលំដាប់មុនមិនមានអានុភាពចំពោះសន្តតិជនលំដាប់ក្រោយដោយសារការបោះបង់សន្តតិកម្មឡើយ ។

### ៣.១.៣.២.យល់ព្រមដោយមានកម្រិត

ការយល់ព្រមដោយមានកម្រិតមានគោលបំណង ការពារសន្តតិជនពីការទទួលខុសត្រូវចំពោះកាតព្វកិច្ច របស់មតកជន ដោយអានុភាពនៃការទទួលមត៌ក ។ ផ្ទុយពីការទទួលយកទាំងស្រុង របបទទួលយល់ព្រមមានកម្រិតអាចឱ្យសន្តតិជន បម្រុងទុកនូវសំណងកាតព្វកិច្ច ឬអច្ច័យទានរបស់មតកជន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិ ដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។[82] ទាក់ទងនឹងរបបនៃការយល់ព្រមដោយមានកម្រិតនេះ យើងសិក្សាលើនីតិវិធីនៃការស្នើសុំការយល់ព្រមដោយមានកម្រិត និងអានុភាពនៃការយល់ព្រមដោយមានកម្រិត ។

[82] ទំព័រទី១០១ សៀវភៅសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគទី៣ ឆ្នាំ២០១៧

➢ **<u>នីតិវិធីនៃការស្នើសុំការយល់ព្រមដោយមានកម្រិត</u>**

ដើម្បីបង្កើតសិទ្ធិពេញលេញតាមច្បាប់លើសន្តតិជន ឬសហសន្តតិជនទាំងអស់ក្នុងករណីមានសន្តតិជនច្រើននាក់នៃមត៌ក ដែលចង់ទទួលបានការយល់ព្រមដោយមានកម្រិតលើមតកសាសន៍របស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំអំពីការយល់ព្រមដោយមានកម្រិត ដោយរួមជាមួយនឹងបញ្ជីសារពើភ័ណ្ឌ ទៅតុលាការសាលាដំបូង នៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម នៅអំឡុងពេល ៣ (ខែ) ចាប់ពីសន្តតិជនបានដឹងពីការចាប់ផ្តើម បង្កើតអានុភាពមតកសាសន៍ចំពោះខ្លួន ។ ប្រសិនបើតុលាការ យល់ឃើញថាពាក្យស្នើសុំអំពីការយល់ព្រមដោយមានកម្រិតមានភាពត្រឹមត្រូវ តុលាការនឹងចេញដីកាសម្រេច ដើម្បីទទួលយកពាក្យស្នើសុំនោះ ។[83]

➢ **<u>អានុភាពនៃការយល់ព្រមដោយមានកម្រិត</u>**

នៅពេលដែលតុលាការបានចេញនូវសេចក្តីសម្រេច ទទួលស្គាល់ការទទួលខុសត្រូវដោយមានកម្រិតរបស់សន្តតិជន នោះម្ចាស់បំណុលរបស់មតកជន ទាមទារជម្រះបញ្ជី មិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវទាំងស្រុង ឬដោយប្រើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនទទួលខុសត្រូវ ដោយមានកម្រិតនោះទេ ទោះបីជាតម្លៃនៃមត៌កដែលសន្តតិជនទទួលយកមិនគ្រប់គ្រាន់ សំរាប់សងបំណុលចំពោះម្ចាស់បំណុលក៏ ដោយ ។[84]

ប៉ុន្តែ អានុភាពនៃការយល់ព្រមដោយមានកម្រិត គឺការពារតែសន្តតិជនសុចរិតប៉ុណ្ណោះ ។ ក្នុងករណីដែលសន្តតិជន បានធ្វើសកម្មភាពដោយទុច្ចរិត ដូចជា មិនសរសេរទ្រព្យសម្បត្តិទាំងអស់ ឬមួយភាគទៅក្នុងបញ្ជីសារពើភ័ណ្ឌ ឬបានចាត់ចែងភាគណាមួយនៃទ្រព្យសម្បត្តិ ឬលាក់ ឬប្រើប្រាស់ភាគណាមួយនៃទ្រព្យជាប្រយោជន៍ផ្ទាល់ខ្លួន នោះសន្តតិជនរូបនោះត្រូវបានច្បាប់សន្មតថា បានយល់ព្រមទទួលទាំងស្រុងនៃមតកសាសន៍ចំពោះខ្លួន ។[85]

**ឧទាហរណ៍៖** តាមរយៈមតកសាសន៍ បានផ្តល់ឱ្យសន្តតិជន A ទទួលបានដីមួយកន្លែង មានតម្លៃ ១0000 ដុល្លារ ប៉ុន្តែ ត្រូវសងបំណុលទៅឱ្យម្ចាស់បំណុល B ។ ដោយមិនដឹងថាចំនួនទឹកប្រាក់ត្រូវសងលើម្ចាស់បំណុល B មានចំនួនប៉ុន្មាន នាំឱ្យ A ដាក់ពាក្យទៅតុលាការស្នើសុំសេចក្តីសម្រេចអំពី ការទទួលយកដោយមានកម្រិត ប៉ុន្តែ ក្នុងបញ្ជីរគាត់បានដាក់ថ្លៃលក់ដី តែចំនួន ៥000 ដុល្លារ ដោយសារគាត់យកទៅចាយអស់ ៥000ដុល្លារបាត់ទៅហើយ។ ក្នុងករណីនេះ ទោះបីជាសិទ្ធិលើបំណុលរបស់ B មានតម្លៃ លើសពី ១0000 ក៏ដោយ

[83] មាត្រា ១២៤៨, មាត្រា ១២១២៥៦, មាត្រា ១២៥៧ ក្រមរដ្ឋប្បវេណី ២០០៧ និង មាត្រា៣-២ ច្បាប់ស្តីពី នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[84] ទំព័រទី១០៣ នៃសៀវភៅសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគទី៣ ឆ្នាំ២០១៧

[85] មាត្រា ១២៥៥-១-ក ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក៏ B អាចទាមទារបំណុលទាំងអស់ពី A បានដែរ ព្រោះ A ត្រូវបានសន្មតថា បានទទួលទាំងស្រុងនូវមតក សាសន៍ចំពោះខ្លួន។

**៣.១.៣.៣.ការបោះបង់សន្តតិកម្ម**

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ឬមតកសាសន៍ ត្រូវដាក់ពាក្យស្នើសុំទៅតុលាការ លើក លែងអច្ច័យលាភីមានកំណត់ ។ ការបោះបង់សន្តតិកម្ម មានអានុភាពប្រតិសកម្មដោយចាត់ទុកថា សន្តតិកម្ម នោះគ្មានអានុភាពតាំងពីដំបូងនូវចំណែកនៃការបោះបង់នោះ មានន័យថា បើសន្តតិជន និងអច្ច័យលាភីដែល ជាប្រធាននៃមតកសាសន៍បានបោះបង់មតកសាសន៍ទាំងអស់គ្នា នោះស្មើនឹងគ្មានមតកសាសន៍ ឬមតក សាសន៍គ្មានអានុភាពទាំងស្រុង ។ ប៉ុន្តែ បើសន្តតិជនណាម្នាក់បានបោះបង់សន្តតិកម្មនោះចាត់ទុកថា មិនមាន អានុភាពលើចំណែកនៃការបោះបង់នោះ ឬមកសាសន៍គ្មានអានុភាពដោយផ្នែក ។

## ៣.២.ការប្រតិបត្តិមតកសាសន៍

របបនៃអ្នកប្រតិបត្តិបង្កើតឡើង ដើម្បីសម្រួលដល់ការអនុវត្តមតកសាសន៍ប្រកបដោយភាពត្រឹមត្រូវ ការជឿទុកចិត្ត កាត់បន្ថយការរាំងស្ទះនានា ក្នុងកិច្ចដំណើរការអនុវត្តមតកសាសន៍ ធ្វើយ៉ាងណាឱ្យសម្រេចនូវ ខ្លឹមសារនៃមតកសាសន៍ ។ ហេតុនេះយើងនឹងលើកឡើងនូវចំនុចសំខាន់ៗទាក់ទងនឹងការអនុវត្តមតកសាសន៍ នូវ មូលហេតុចាំបាច់ឱ្យមានអ្នកប្រតិបត្តិ, ការជ្រើសតាំងអ្នកប្រតិបត្តិ, ការលាឈប់ និងការបញ្ឈប់ពីតួនាទីអ្នក ប្រតិបត្តិ, ការកាន់កាប់មុខងារជាអ្នកប្រតិបត្តិ និងអានុភាព, សិទ្ធិនិងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍, កាតព្វកិច្ចអ្នកប្រតិបត្តិមតកសាសន៍ និងបន្ទុកនៃមត៌ក ។

**៣.២.១.មូលហេតុបង្កើតឱ្យមានអ្នកប្រតិបត្តិ**

មូលហេតុចម្បងដែលច្បាប់បង្កើតរបបនៃអ្នកប្រតិបត្តិនេះឡើង គឺដើម្បីឱ្យបុគ្គល ឬក្រុមបុគ្គលជាអ្នក ដែលនឹងក្លាយជាអ្នកប្រតិបត្តិ អនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃមតកសាសន៍ ។ ហេតុនេះនៅពេលខ្លួនក្លាយ ជាអ្នកប្រតិបត្តិមតកសាសន៍ហើយនោះ ត្រូវតែអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងឆន្ទៈរបស់ មតកជន ដើម្បីសម្រេចឱ្យបានទាំងស្រុងនូវខ្លឹមសារមតកសាសន៍ ធានាតម្លាភាព ជម្លោះនឹងជៀសវាង បញ្ហា រាំងស្ទះនានាដែលបង្កឡើងដោយភាគីពាក់ព័ន្ធ ។

**៣.២.២. ការជ្រើសតាំងអ្នកប្រតិបត្តិ**

បុគ្គល ដែលអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ បានតាមរបៀបពីរយ៉ាង គឺតាមរយៈការកំណត់ក្នុង មតកសាសន៍ និងតាមរយៈការជ្រើសតាំងពីតុលាការ ។

- ✓ ការកំណត់អ្នកប្រតិបត្តិតាមរយៈមតកសាសន៍ គឺកើតចេញពីឆន្ទៈរបស់ម្ចាស់បណ្តាំដែលកំណត់ជាមុន នូវអ្នកប្រតិបត្តិជាក់លាក់តែម្តង ឬមតកជនបានកំណត់អ្នកតំណាងដោយអាណត្តិរបស់ខ្លួន ដើម្បីជ្រើសតាំងអ្នកប្រតិបត្តិជំនួសខ្លួន ។
- ✓ ក្នុងករណីដែលមតកសាសន៍មិនបានកំណត់អំពីសមាសភាពអ្នកតំណាងដោយអាណត្តិ ឬអ្នកប្រតិបត្តិ នោះទេ ឬអ្នកតំណាងដោយអាណត្តិ ឬអ្នកប្រតិបត្តិលាលែងពីមុខងារ នោះសន្តតិជន ឬអ្នកពាក់ព័ន្ធ នឹងផលប្រយោជន៍ អាចស្នើសុំទៅតុលាការដើម្បីចាត់តាំងអ្នកប្រតិបត្តិបាន ។

ទោះបីជាមតកសាសន៍បានកំណត់ពីសមាសភាពអ្នកប្រតិបត្តិ ឬផ្តល់សិទ្ធិឱ្យតតិយជនជាអ្នកតំណាងដោយអាណត្តិរបស់ខ្លួនមានសិទ្ធិជ្រើសរើសអ្នកប្រតិបត្តិក៏ដោយ ច្បាប់មិនអនុញ្ញាតឱ្យក្រុមបុគ្គលមួយចំនួនមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍បានដែល ព្រោះមានការបារម្ភពីសមត្ថភាព និងភាពទុកចិត្តក្នុងការអនុវត្តមតកសាសន៍ ដោយបុគ្គលទាំងនោះមានជាអាទិ៍ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ និងជនក្ស័យធន ។[86]

### ៣.២.៣.ការលាឈប់ និង ការបញ្ឈប់ តួនាទីអ្នកប្រតិបត្តិ

អ្នកប្រតិបត្តិអាចលាឈប់ពីតួនាទីរបស់ខ្លួនបានក្នុងករណីខ្លួនមានមូលហេតុត្រឹមត្រូវ ដែលមិនអាច ឬពិបាកបំពេញនូវកិច្ចការអាណត្តិក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍បាន ដោយដាក់ពាក្យស្នើសុំលាឈប់ទៅតុលាការសាលាដំបូងនៃទីកន្លែងចាប់ផ្តើមសន្តតិកម្មបាន ។ នៅក្នុងពាក្យសុំលាឈប់នេះ អ្នកប្រតិបត្តិត្រូវតែបញ្ជាក់ភាពចាំបាច់របស់ខ្លួនដែលមិនអាចបំពេញកិច្ចការប្រតិបត្តិបានយ៉ាងជាក់ច្បាស់ ដូចជា បញ្ហាសុខភាព ការជាប់ទៅបំពេញបេសកកម្មក្នុងរយៈពេលវែងនៅក្រៅប្រទេស ឬមូលហេតុចូលកាន់តំណែង ឬកិច្ចការផ្សេងដែលធ្វើឱ្យមានការមមាញឹក ជាអាទិ៍ ។ ម្យ៉ាងវិញទៀតក្នុងករណីដែលអ្នកប្រតិបត្តិបានធ្វេសប្រហែស ខ្ជីខ្ជា ក្នុងការបំពេញភារកិច្ច ឬមានភាពខ្ជិលច្រអូសក្នុងការបំពេញកិច្ចការរបស់ខ្លួន នោះសន្តតិកម្ម ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍នៃមតកសាសន៍អាចដាក់ពាក្យទៅតុលាការដើម្បីបញ្ឈប់តួនាទីអ្នកប្រតិបត្តិនោះ ។[87]

### ៣.២.៤.ការកាន់កាប់មុខងារជាអ្នកប្រតិបត្តិ និង អានុភាព

នៅពេលអ្នកប្រតិបត្តិមតកសាសន៍ យល់ព្រមទទួលតួនាទីក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ នោះអ្នកប្រតិបត្តិត្រូវចូលកាន់មុខងារ និងចាប់ផ្តើមអនុវត្តមុខងារខ្លួនភ្លាមៗ ។ ក្នុងករណីដែលមតកសាសន៍ត្រូវបានកំណត់សមាសភាពអ្នកប្រតិបត្តិ ឬតតិយជនតំណាងដោយអាណត្តិ មិនបានអនុវត្តតួនាទីរបស់ខ្លួន សន្តតិជន

---

[86] មាត្រា ១២១៧ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[87] មាត្រា ១២២៧ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ និង មាត្រា ១២២៧ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍នៃមតកសាសន៍អាចធ្វើការដាស់តឿនទៅអ្នកប្រតិបត្តិ ឬតតិយជនតំណាងដោយអាណត្តិបាន ក្នុងករណីមិនឆ្លើយតបស្មើនឹងបដិសេធទទួលតួនាទីជាអ្នកប្រតិបត្តិ ឬអ្នកតំណាង ដោយអាណត្តិ ។ ហើយនៅពេលមានអ្នកប្រតិបត្តិ នោះសន្តតិជនពុំអាចចាត់ចែងមត៌ក ឬសកម្មភាពផ្សេងៗ ដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍ឡើយ និងក្នុងករណីសន្តតិជន ធ្វើការចាត់ចែងនូវសកម្មភាពអនុវត្តមតកសាសន៍ នោះសកម្មភាពទាំងនោះ គឺគ្មានអានុភាពឡើយ ។[88]

### ៣.២.៥.សិទ្ធិ និង តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

ក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ អាចបំពេញតួនាទី និងមុខងាររបស់ខ្លួនដោយឯករាជ្យ មិនចំពោះទៅនឹងភាគីណាមួយ ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍ណាមួយឡើយក្រៅតែខ្លឹមសារនៃមតកសាសន៍ ដូច្នេះគ្មានភាគីណាមួយ រួមទាំងសន្តតិជនផងមិនអាចបង្គាប់បញ្ជាឱ្យអ្នកប្រតិបត្តិអនុវត្តនូវសេចក្តីសម្រេចស្រប តាមគំនិតរបស់ខ្លួនឡើយ ព្រោះអ្នកប្រតិបត្តិបំពេញមុខងារក្នុងនាមម្ចាស់បណ្តាំ ស្របតាមស្មារតីរបស់មតកសាសន៍ប៉ុណ្ណោះ ។ ផ្ទុយទៅវិញ សកម្មភាពរបស់អ្នកប្រតិបត្តិត្រូវមានអានុភាពដោយផ្ទាល់ចំពោះសន្តតិជន ។ [89] មូលហេតុដែលច្បាប់ផ្តល់សិទ្ធិអំណាចឯករាជ្យមុខងារដល់អ្នកប្រតិបត្តិ គឺដើម្បីកុំឱ្យអ្នកពាក់ព័ន្ធផលប្រយោជន៍ធ្វើសកម្មភាពរារាំងនានាជាយថាហេតុដល់ការអនុវត្តមតកសាសន៍ ។

អ្នកអនុវត្តមតកសាសន៍ត្រូវអនុវត្តតួនាទី សិទ្ធិ និងមុខងាររបស់ខ្លួនក្នុងនាមជាអ្នកតំណាងអាណត្តិ របស់មតកជន ដើម្បីប្រយោជន៍សន្តតិជន ព្រោះសន្តតិជន ឬអច្ច័យលាភី គឺជាប្រធាននៃសន្តតិកម្ម ដែលជាហេតុសកម្មភាពរបស់អ្នកប្រតិបត្តិមានអានុភាពលើសន្តតិជន និងអច្ច័យលាភី ។ តួនាទី សិទ្ធិ និងមុខងារ សំខាន់ៗរបស់អ្នកប្រតិបត្តិមតកសាសន៍រួមមាន៖

✓ **តួនាទីគ្រប់គ្រង ៖** ក្នុងករណីមតកសាសន៍មានអ្នកប្រតិបត្តិ នោះអ្នកប្រតិបត្តិត្រូវជាអ្នកគ្រប់គ្រងមត៌ក ប៉ុន្តែអ្នកប្រតិបត្តិអាចមានភារកិច្ចគ្រប់គ្រងតែលើទ្រព្យសម្បត្តិ ដែលបានកំណត់ក្នុងមតកសាសន៍ប៉ុណ្ណោះ ពោលគឺទ្រព្យសម្បត្តិរបស់មតកជនដែលមិនបានចែងក្នុងមតកសាសន៍នោះទេ អ្នកប្រតិបត្តិពុំមានភារកិច្ចក្នុងការគ្រប់គ្រង ឬកាន់កាប់ឡើយ ។[90]

[88] មាត្រា ១២១៥, មាត្រា ១២១៦ និងមាត្រា ១២២១ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[89] មាត្រា ១២២០ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[90] មាត្រា ១២៦៣ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

**ឧទាហរណ៍៖** មតកជនមានរថយន្តចំនួន ២០គ្រឿង ប៉ុន្តែនៅក្នុងមតកសាសន៍គាត់បានចែកឱ្យ កូន៣ នាក់របស់គាត់ ដោយម្នាក់ៗ ទទួលបានរថយន្តចំនួន ៤ គ្រឿង ដូច្នេះ អ្នកប្រតិបត្តិអាចធ្វើការកាន់កាប់ និងគ្រប់គ្រងរថយន្តតែ ១២គ្រឿង ដែលជាកម្មវត្ថុនៃមតកសាសន៍ដើម្បីអនុវត្តតាមខ្លឹមសារប៉ុណ្ណោះ ។

✓ **តួនាទីរៀបចំបញ្ជីសារពើភ័ណ្ឌ៖** នៅពេលចូលកាន់តួនាទីជាអ្នកអនុវត្តមតកសាសន៍ អ្នកអនុវត្តត្រូវរៀបចំនូវបញ្ជីសារពើភ័ណ្ឌ ។ បញ្ជីសារពើភ័ណ្ឌសំដៅលើបញ្ជីដែលមានរាយនូវទ្រព្យសម្បត្តិទាំងអស់ ដោយផ្អែកលើការកំណត់ក្នុងមតកសាសន៍ ដោយអនុញ្ញាតផងដែលក្នុងករណីសន្តតិជន ចង់ចូលរួមនៅពេលធ្វើបញ្ជីសារពើភ័ណ្ឌ ។ បន្ទាប់ពីរៀបចំបញ្ជីសារពើភ័ណ្ឌរួចហើយ អ្នកប្រតិបត្តិមតកសាសន៍ត្រូវប្រគល់បញ្ជីនោះទៅឱ្យសន្តតិជនយ៉ាងឆាប់រហ័ស ។

✓ **ត្រួតពិនិត្យពីឋានៈបុគ្គល ៖** អ្នកប្រតិបត្តិមិនត្រឹមតែមានតួនាទីពិនិត្យ ស្រាវជ្រាវតែទៅលើទ្រព្យសម្បត្តិនោះទេ អ្នកប្រតិបត្តិក៏ត្រូវពិនិត្យផងដែល ទៅលើអត្ថិភាពនៃសិទ្ធិរបស់សន្តតិជន ឬអច្ច័យលាភី ។ ក្នុងករណីនេះ អ្នកប្រតិបត្តិត្រូវផ្ទៀងផ្ទាត់ទៅលើខ្លឹមសារនៃសន្តតិកម្មទាក់ទងនឹងឋានៈបុគ្គលជាក់ស្តែង ។ ក្នុងការពិនិត្យនេះ ករណីដែលមតកសាសន៍បានបញ្ញត្តពីការផ្តាច់មត៌ក ឬការលុបចោលការផ្តាច់មត៌ក ឬមតកសាសន៍មានចែងអំពីការទទួលស្គាល់កូន ឬមានការបោះបង់មតកសាសន៍ជាអាទិ៍ អ្នកប្រតិបត្តិត្រូវធ្វើបណ្តឹងនានាទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីប្រាកដថាអ្នកទទួលអានុភាពនៃមតកសាសន៍ត្រូវតែជាអ្នកមានសិទ្ធិ និងមានលក្ខណៈសម្បត្តិត្រឹមត្រូវតាមច្បាប់ និងមតកសាសន៍ ។

✓ **ការបែងចែកចំណែក ៖** ក្នុងករណីវិធីនៃការបែងចែកត្រូវបានកំណត់ដោយមតកសាសន៍ នោះអ្នកអនុវត្តត្រូវអនុវត្តតាមបណ្តាំនោះ តែបើមិនដូច្នេះទេ អ្នកប្រតិបត្តិមានសិទ្ធិធ្វើការបែងចែកទៅតាមសមាមាត្រនៃតម្លៃ ឬសម្របសម្រួលរវាងសន្តតិជន ឬអច្ច័យលាភី ដែលទទួលជាភាគលើវត្ថុតែមួយ ដោយការជ្រើសឱ្យសន្តតិជនណាមួយធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុនោះ ដោយបង់តម្លៃទៅឱ្យចំណែកសន្តតិជនផ្សេង ឬអាចលក់ដោយយកប្រាក់មកបែងចែងតាមចំណែក ជាអាទិ៍ ។[91]

✓ **ការចាត់ចែង ឬ ការប្រគល់៖** វាជាកិច្ចការរបស់អ្នកប្រតិបត្តិដើម្បីបញ្ចប់កិច្ចការរបស់ខ្លួនក្នុងការប្រគល់នូវមត៌កដែលខ្លួនបានគ្រប់គ្រង និងរៀបចំចាត់ចែងប្រគល់ទៅឱ្យសន្តតិជន ឬអច្ច័យលាភីនូវទ្រព្យសម្បត្តិ ព្រមទាំងកាតព្វកិច្ចនានាដែលកំណត់ដោយបណ្តាំ ។ ជាក់ស្តែងក្នុងករណីជាអចលនវត្ថុ អ្នកប្រតិបត្តិត្រូវរៀបចំចាត់ចែងតាមនីតិវិធីដោយស្នើសុំផ្ទេរកម្មសិទ្ធិតាមរយៈការចុះបញ្ជី

[91] មាត្រា ១២៦៦, មាត្រា ១២៦៧ និង មាត្រា ១២៧១ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

តាមនីតិវិធីច្បាប់ ឬករណីចលនវត្ថុ ត្រូវប្រគល់វត្ថុនោះតាមរយៈការប្រគល់ជាក់ស្តែងដូចជាការដក ប្រាក់ក្នុងធនាគារ ឱ្យសន្តតិជនជាដើម។

### ៣.២.៦.ភាតព្វកិច្ចអ្នកប្រតិបត្តិ

អ្នកប្រតិបត្តិមតកសាសន៍ មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នក គ្រប់គ្រងដោយសុចរិត ។ ក្នុងករណីអ្នកប្រតិបត្តិអនុវត្តករណីយកិច្ចខ្ជីខ្ជា ខ្វះការប្រុងប្រយ័ត្ន ដែលបណ្តាលឱ្យ ខូចខាតប្រយោជន៍ដោយមិនសមរម្យចំពោះ អ្នកពាក់ព័ន្ធផលប្រយោជន៍នានានៃមតកសាសន៍ នោះអ្នកពាក់ ព័ន្ធផលប្រយោជន៍នោះអាចទាមទារសំណងនៃការខូចខាតពីអ្នកប្រតិបត្តិបាន ។[92]

ចំពោះការបំពេញតួនាទីទាំងអស់របស់ខ្លួន អ្នកប្រតិបត្តិត្រូវបំពេញដោយខ្លួនឯងផ្ទាល់ ដោយមិនអាច អនុញ្ញាតឱ្យតតិយជនណា ឬតែងតាំងតតិយជនណាមកបំពេញកិច្ចការប្រតិបត្តិជំនួសខ្លួនឡើយ លើកលែងតែ មានការកំណត់អនុញ្ញាតដោយមតកសាសន៍ ។ ក្នុងករណីអ្នកប្រតិបត្តិតែងតាំងតតិយជនឱ្យបំពេញតួនាទី ជំនួសខ្លួន ឬជួយកិច្ចការប្រតិបត្តិរបស់ខ្លួន ស្របតាមមតកសាសន៍ នោះអ្នកប្រតិបត្តិត្រូវត្រួតពិនិត្យលើតតិយ ជនដែល ត្រូវបានតែងតាំងនោះ ចំពោះសន្តតិជន និង អច្ច័យលាភី ដោយធានាថាការបំពេញកិច្ចការជំនួស និង មិនបង្កឱ្យ មានការខូចខាតដល់ផលប្រយោជន៍ណាមួយនៃការប្រតិបត្តិនោះទេ ។ ផ្ទុយទៅវិញក្នុងករណីអ្នក ប្រតិបត្តិធ្វើការ តែងតាំងតតិយជនឱ្យបំពេញកិច្ចការប្រតិបត្តិដោយចិត្តឯង បើសិនបណ្តាលឱ្យខូចខាតនូវ ផលប្រយោជន៍ណាមួយដល់សន្តតិជន ឬអច្ច័យលាភី នោះអ្នកប្រតិបត្តិត្រូវទទួលខុសត្រូវសងនូវការ ខូចខាតទាំងនោះ ។

### ៣.២.៧.បន្ទុកនៃមត៌ក

រាល់សកម្មភាពទាំងអស់នូវការចំណាយចាំបាច់ក្នុងការអនុវត្ត ដើម្បីសម្រេចនូវខ្លឹមសារនៃមតសាសន៍ ជា បន្ទុកលើមត៌ក ដូចជាការចំណាយចាំបាច់ក្នុងការគ្រប់គ្រង ថែរក្សាមត៌ក ឬអនុវត្តនីតិវិធីបញ្ជាក់មតកសាសន៍ ជាអាទិ៍ ។ លើសពីនេះ អ្នកអនុវត្តអាចទទួលបានប្រាក់កម្រៃនៃការបំពេញតួនាទីរបស់ខ្លួនតាមការកំណត់ជាមុន ក្នុងមតកសាសន៍ ឬក្នុងករណីបណ្តាំមិនបានកំណត់ជាមុននូវសោហ៊ុយសំរាប់អ្នកប្រតិបត្តិ ក៏អ្នកប្រតិបត្តិអាច ទាមទារឱ្យតុលាការកំណត់ពីសោហ៊ុយនេះបានដែល ហើយធ្វើការកាត់លើតម្លៃនៃមត៌កតែម្តង ។[93]

---

[92] មាត្រា ៦៤០ និងមាត្រា ១២២៩ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[93] មាត្រា ១២២៦ និងមាត្រា ១២២៨ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

## ៣.៣.ការសម្រួលចំណែកមត៌ក

ការសម្រួលចំណែកមត៌ក គឺធ្វើឡើងដើម្បីឱ្យមានសមភាពត្រឹមត្រូវជាក់ស្តែងនៃចំណែករបស់សហសន្តតិជន ដើម្បីឱ្យសមស្របទៅនឹងករណីមានអ្នកទទួលផលប្រយោជន៍ពិសេសផ្សេងៗ ដោយតម្រូវឱ្យសងមកវិញនូវចំណែកទាំងនោះ។ នៅក្នុងក្រមរដ្ឋប្បវេណី បានកំណត់អំពីការសម្រួលចំណែកមត៌ក ដែលយើងនឹងធ្វើការសិក្សាទៅលើរួមមានដូចជាផលប្រយោជន៍ពិសេស ភាគនៃវិភាគទាន និងប្រទានកម្ម។

### ៣.៣.១. ផលប្រយោជន៍ពិសេស

ផលប្រយោជន៍ពិសេស គឺមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានបញ្ញត្តិថា នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជន នោះតម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ឬអច្ច័យទាននោះចេញពីចំណែកមត៌កដែលត្រូវបានគណនា គឺជាចំណែកមត៌ករបស់មតកជននោះ។[94] ពោលគឺ មាត្រានេះចែងឡើងក្នុងគោលបំណងសម្រួលនូវចំណែកមត៌កសម្រាប់អ្នកដែលទទួលផលប្រយោជន៍ពិសេស ក្នុងចំណោមសន្តតិជនទាំងអស់មានជនដែលទទួលបានទ្រព្យដោយប្រទានកម្ម ជាអាទិ៍ នៅពេលដែលមតកជន នៅរស់ដើម្បីធ្វើឱ្យមានសមភាពត្រឹមត្រូវជាក់ស្តែងរវាងសហសន្តតិជន។ ក្នុងករណីដែលមានការទទួលផល ប្រយោជន៍ពិសេសវិធីគណនាចំណែកមត៌កមានដូចខាងក្រោម៖

ដំបូង ត្រូវបូកទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេសចំពោះមត៌ករបស់មតកជន ដែលហៅថា " ទ្រព្យសម្បត្តិដែលត្រូវចាត់ទុកជាមត៌ក "។ បន្ទាប់មកត្រូវគណនាទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កឱ្យស្របតាម បញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ រួចគណនាចំណែកសន្តតិកម្មរបស់សន្តតិជននីមួយៗ ហៅថា " ចំណែកដែលត្រូវចាត់ទុកថាជាមត៌ក "។ បន្ទាប់មកត្រូវដកនូវទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេសពី ចំណែកដែលត្រូវចាត់ទុកថាជាមត៌ករបស់សន្តតិជនដែលបានទទួលផលប្រយោន៍ពិសេស។[95]

**រូបមន្ត៖**

ទ្រព្យដែលចាត់ទុកជាមត៌ក = ប្រទានកម្ម + អច្ច័យទាន + តម្លៃសរុបនៃមត៌កពេលចាប់ផ្តើម

[94] មាត្រា ១១៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[95] មេរៀនភាគ ៣ នៃក្រមរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ សិក្ខាសាលាស្តីពីមូលដ្ឋានគ្រឹះនៃសន្តតិកម្ម ទំព័រ ១៩

### ៣.៣.១.១. ផលប្រយោជន៍ពិសេសមានតម្លៃតិចជាងចំណែកមត៌ក

ក្នុងករណីដែលប្រទានកម្មមានតម្លៃតិចជាងចំណែកមត៌ក សហសន្តតិជននឹងត្រូវទទួលបាននូវ ចំណែកមត៌កនៃចំណែកបន្ថែមក្រោយពីទទួលបាននូវផលប្រយោជន៍ពិសេសនោះ ដើម្បីបង្គ្រប់ចំណែកមត៌ករបស់បុគ្គលនោះ។

**ឧទាហរណ៍៖** មតកជន **ក** មានកូនចំនួន ៣នាក់ គឺ A, B និង C ដែល ក បានបន្សល់ទុកមត៌កចំនួន ១២០០ ដុល្លារអាមេរិក។ មុនពេលគាត់ទទួលមរណភាព ក បានផ្តល់ផលប្រយោជន៍ពិសេសចំនួន ៣០០ ដុល្លារអាមេរិកឱ្យទៅ B។

យោងតាមមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ទ្រព្យសម្បត្តិនាពេលចាប់ផ្តើមសន្តតិកម្មមានចំនួន ១២០០ ដុល្លារអាមេរិក ដោយត្រូវបូក (+) នឹងចំនួនផលប្រយោជន៍ពិសេសគឺ ៣០០ ដុល្លារអាមេរិក = ១៥០០ ដុល្លារអាមេរិក។

ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង C គឺម្នាក់ៗត្រូវទទួលបាន ៥០០ ដុល្លារអាមេរិក ស្មើៗគ្នា។ ចំពោះ B បានទទួលនូវផលប្រយោជន៍ពិសេសចំនួន ៣០០ ដុល្លារអាមេរិក នោះចំណែកមតិកពិតប្រាកដរបស់ B គឺទទួលបានចំនួន ២០០ ដុល្លារអាមេរិក ដែលជាសមតុល្យបន្ទាប់ពីការដកចំនួន ៣០០ ដុល្លារអាមេរិក ចេញពីទ្រព្យចាត់ទុកជាមត៌កចេញ។

### ៣.៣.១.២.ផលប្រយោជន៍ពិសេសមានតម្លៃស្មើនឹងចំណែកមត៌ក

បើតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ។[96]

| |
|---|
| **រូបមន្ត៖** |
| ចំណែកមតិករបស់សន្តតិជន=(ទ្រព្យដែលចាត់ទុកជាមតិកxចំណែកមតិក)-ប្រទានកម្ម-អច្ច័យទាន |

**ឧទាហរណ៍៖** មតកជន ក មានកូនចំនួន ៣នាក់ A, B និង C នឹងបានបន្សល់ទុកមត៌កចំនួន ២,០០០ ដុល្លារអាមេរិក។ មុនពេលទទួលមរណភាព ក បានផ្តល់ផលប្រយោជន៍ពិសេសឱ្យទៅ B ចំនួន ១,០០០ ដុល្លារអាមេរិក។

តាមមាត្រា ១១៦៣ ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្មគឺ ២,០០០ + ១,០០០ = ៣,០០០ ដុល្លារអាមេរិក ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង Cត្រូវទទួលបាន ១,០០០ ដុល្លារអាមេរិក ស្មើៗគ្នា។ ចំពោះ B ដែលទទួលបាននូវផលប្រយោជន៍ពិសេសចំនួន ១,០០០ ដុល្លារអាមេរិក ដែលស្មើនឹងចំណែកមត៌ក នោះចំណែកមត៌កពិតប្រាកដរបស់ B គឺមិនទទួលបានទៀតនោះទេ។

[96] មាត្រា ១១៦៣ ចំណុចទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ៣.៣.១.៣.ផលប្រយោជន៍ពិសេសមានតម្លៃលើសពីចំណែកមត៌ក

ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេសរួមមានប្រទានកម្ម ឬ អច្ច័យទានដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះពុំចាំបាច់បង្វិលមកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។[97]

ឧទាហរណ៍ទី១៖ មតកជន ក មានកូនចំនួន ៣នាក់ A, B និង C នឹងបានបន្សល់ទុកមត៌កចំនួន ២,០០០ ដុល្លារអាមេរិក។ មុនពេលទទួលមរណភាព ក បានផ្តល់អំណោយឱ្យទៅ B ចំនួន ២,៥០០ ដុល្លារអាមេរិក។

តាមមាត្រា ១១៦៣ ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្មគឺ ២,០០០ - ២,៥០០ = ៤,៥០០ដុល្លារអាមេរិក។

ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង C ម្នាក់ៗត្រូវទទួលបានចំនួន ១,៥០០ ដុល្លារអាមេរិក។ ចំពោះ B ដែលទទួលបាននូវផលប្រយោជន៍ពិសេស ២,៥០០ ដុល្លារអាមេរិក ដែលលើសនឹងចំណែកមត៌ក នោះចំណែកមត៌កពិតប្រាកដរបស់ B គឺមិនទទួលបានទៀតនោះទេ ហើយចំណែកដែលលើស B ក៏មិនចាំបាច់បង្វិលមកវិញដែរ (B លើសចំនួន ១,៥០០ ដុល្លារអាមេរិក)។ ដូចនេះ A និងC ត្រូវទទួលបានចំណែកស្មើៗគ្នានៃចំណែកមត៌កជាក់ស្តែងគឺក្នុងម្នាក់ៗទទួលបាន ១,០០០ ដុល្លារអាមេរិក។

ក្នុងករណីដែលមិនចាំបាច់ឱ្យបង្វិលនូវភាគលើសវិញទេ តម្លៃនៃចំណែកមត៌កជាក់ស្តែងរបស់សហសន្តតិជនផ្សេងទៀតនៅពេលសន្តតិជនចាប់ផ្តើមសន្តតិកម្ម ត្រូវគណនាដោយបែងចែកមត៌កដែលមតកជនមាន នៅពេលចាប់ផ្តើមសន្តតិកម្មនោះតាមសមាមាត្រនៃចំណែកមត៌ករបស់សន្តតិជនម្នាក់ៗ។[98]

**រូបមន្ត៖** ចំណែកមត៌កជាក់ស្តែងសន្តតិជនត្រូវទទួលបាន = តម្លៃនៃទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តិកម្ម ÷ តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជន × ចំណែកមត៌ករបស់សន្តតិជន

**ឧទាហរណ៍ទី២៖** មតកជន ក មានកូនចំនួន ៣នាក់ A, B និង C នឹងបានបន្សល់ទុកមត៌កចំនួន ២,០០០ដុល្លារអាមេរិក។ មុនពេលទទួលមរណភាព ក បានផ្តល់ផលប្រយោជន៍ពិសេសឱ្យទៅ B ចំនួន ២,០០០ ដុល្លារអាមេរិក និង C ក៏បានទទួល ៨០០ ដុល្លារអាមេរិក។

តាមមាត្រា ១១៦៣ ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្មគឺ ២,០០០ - ២,០០០ - ៨០០ = ៤,៨០០ ដុល្លារអាមេរិក

[97] មាត្រា ១១៦៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[98] មាត្រា ១១៦៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង C ត្រូវទទួលបានម្នាក់ៗចំនួន ១,៦០០ ដុល្លារអាមេរិក ស្មើៗគ្នា។ ចំពោះ B ដែលទទួលបាននូវផលប្រយោជន៍ពិសេស ២,០០០ ដុល្លារអាមេរិក ដែលលើសនឹងចំណែកមត៌ក នោះចំណែកមត៌កពិតប្រាកដរបស់ B គឺមិនទទួលបានទៀតនោះទេ ចំពោះ C ដែលទទួលប្រទានកម្មចំនួន ៨០០ ដុល្លារអាមេរិក ដូចនេះ C នៅខ្វះចំនួន ៨០០ ដុល្លារអាមេរិក និងចំណែកមត៌ករបស់ A គឺ ១,៦០០ ដុល្លារអាមរិក។ ចំនួនមត៌កសរុបរបស់សន្តតិជននីមួយៗមានចំនួន(៨០០+១,៦០០= ២,៤០០) ដែលលើសចំនួនមត៌កសរុប (ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្ម ២០០០ ដុល្លារអាមេរិក។

ដូចនេះ A និង C ត្រូវទទួលបានចំណែកមត៌កតាមការធ្វើសមាមាត្រ $\frac{៨០០}{១,៦០០}$ នៃ ២,០០០ ដុល្លារអាមេរិក (១/២) រវាង A និងC។

=>C (៨០០ ÷២,៤០០ × ២,០០០ = ៦៦៦.៦៦ => ទទួលមានមត៌ក ៦៦៦ ដុល្លារអាមេរិក និង

=>A (២,០០០ - ៦៦៦.៦៦ = ១៣៣៣.៣៤) =>A ទទួលបានមត៌ក ១៣៣៣.៣៤ ដុល្លារអាមេរិក។

### ៣.៣.១.៤.ភាគនៃវិភាគទាន

ភាគនៃវិភាគទាននេះ ត្រូវបានចែងឡើងដើម្បីសម្រួលនូវចំណែកមត៌ក។ ភាគនៃវិភាគទាន គឺជាប្រភេទមួយនៃការសម្រួលចំណែកមត៌ក ដោយសារនៅក្នុងចំណោមសន្តតិជនមានបុគ្គលម្នាក់ ឬច្រើននាក់បានធ្វើសកម្មភាពថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មត៌កជន ឬថែទាំព្យាបាលមតកជន ឬបានធ្វើសកម្មភាពផ្សេងៗដែលចម្រើនដល់មតកជន។ ភាគនៃវិភាគទាន គឺជាការបង្រួមចំនួនមត៌កដើម្បីឱ្យមានសមភាពជាក់ស្តែង នៅក្នុងចំណោមសន្តតិជន ដោយបុគ្គលណាម្នាក់ ឬច្រើននាក់បានចំណាយសម្រាប់មតកជនមុនពេលសន្តតិកម្មចាប់ផ្តើម។[99]

| |
|---|
| **រូបមន្ត៖** មតិកជាក់ស្តែង = មតិកពេលចាប់ផ្តើមសន្តតិកម្ម - ភាគនៃវិភាគទាន |

| |
|---|
| ចំណែកមតិកនៃអ្នកធ្វើភាគនៃវិភាគទាន = (មតិកជាក់ស្តែង ÷ ចំនួនសន្តតិជន) + ភាគនៃវិភាគទាន |

**ឧទាហរណ៍ទី១៖** មតកជន ក មានសហព័ទ្ធ ខ និងកូនចំនួន ៣នាក់គឺ A, B និង C។ ពេល ក នៅរស់ A បានចូលរួមវិភាគទានដល់លោក ក ចំនួន ១,០០០ ដុល្លារអាមេរិក។ នៅពេលដែល ក ទទួលមរណភាពបានបន្សល់ទុកមត៌កចំនួន ៣,០០០ ដុល្លារអាមេរិក។ មត៌កជាក់ស្តែង = ៣,០០០ - ១,០០០ = ២,០០០ ដុល្លារអាមេរិក

[99] មាត្រា ១១៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ដោយសន្តតិជនមានចំនួន បួននាក់ គឺ ខ, A, B និង C នោះចំណែកមត៌កត្រូវបែងចែកជា៤ ចំណែក ប៉ុន្តែដោយ A បានចូលរួមវិភាគទានចំនួន ១,០០០ ដុល្លារអាមេរិកនោះ ចំណែកមត៌ករបស់ A = (២,០០០:៤) + ១,០០០ = ១,៥០០ ដុល្លារអាមេរិក

ចំពោះ ខ, B និង C គឺទទួលបានចំណែកស្មើៗគ្នាគឺ => 8= B = C = ២,០០០:៤ = ៥០០ ដុល្លារអាមេរិក

ដូចនេះ ចំណែកមត៌ករបស់ A គឺ ១,៥០០ ដុល្លារអាមេរិក, ចំណែកមត៌ករបស់ ខ, B និង C គឺ ៥០០ ដុល្លារអាមេរិក។

សហសន្តតិជន ត្រូវកំណត់តម្លៃភាគនៃវិភាគទានដោយការពិភាក្សានៅពេលបែងចែកមត៌ក ប៉ុន្តែ ប្រសិនបើក្នុងករណីដែលការពិភាក្សានេះមិនចុះសម្រុងគ្នាជាអាទិ៍ត្រូវឱ្យតុលាការកំណត់។ ចំពោះករណីភាគច្រើនការបែងចែកមត៌កជាអាទិ៍ នេះក៏មិនសូវមានការចុះសម្រុងគ្នាទេ។ ដូច្នេះជាទូទៅពេលដាក់ពាក្យសុំឱ្យតុលាការធ្វើការវិនិច្ឆ័យនូវការបែងចែកចំណែកមត៌ក គេច្រើនតែសុំឱ្យតុលាការកំណត់តម្លៃភាគនៃវិភាគទានព្រមគ្នាដែរ។ ក្នុងករណីដែលសហសន្តតិជនទាំងអស់អាចធ្វើការបែងចែកមត៌កបានដោយខ្លួនឯង បន្ទាប់ពីបានកំណត់តម្លៃភាគនៃវិភាគទានរួចរាល់ នោះគេអាចដាក់ត្រឹមតែពាក្យសុំឱ្យទៅតុលាការកំណត់បាន ប៉ុន្តែករណីបែបនេះកម្រមានណាស់។[100]

- ❖ ករណីភាគនៃវិភាគទាន > ចំណែកមត៌កដែលមានកំណត់ក្នុងបណ្តាំមត៌ក ត្រូវយកបណ្តាំមត៌កជាគោល យោងតាមមាត្រា ១១៦៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

**ឧទាហរណ៍៖** មតកជន ក មានសហព័ទ្ធ ខ និងកូនចំនួន ៣នាក់គឺ A, B និង C បានបន្សល់ទុកមត៌កចំនួន ៣,០០០ ដុល្លារអាមេរិក។ មុនពេល ក ស្លាប់ A បានចូលរួមវិភាគទាន ២,០០០ ដុល្លារអាមេរិក។

- ប្រសិនបើបណ្តាំបានកំណត់ថា A = ១,២០០ ដុល្លារអាមេរិក, B = ៨០០ ដុល្លារអាមេរិក, C = ១,០០០ ដុល្លារអាមេរិក ដោយសារមតកសាសន៍ ឬ បណ្តាំមត៌កមានអានុភាពជាង ហេតុ នេះត្រូវអនុវត្តតាមបណ្តាំនាំឱ្យ A មិនទទួលបានភាគនៃវិភាគនោះទេ។
- ប្រសិនបើបណ្តាំបានកំណត់ថា A  = ៦០០ ដុល្លារអាមេរិក, B = ៨០០ដុល្លារអាមេរិក, C = ១,០០០ ដុល្លារអាមេរិក ដោយសារមតកសាសន៍ ឬ បណ្តាំមត៌កសាសន៍មានអានុភាពជាង ហេតុ នេះត្រូវអនុវត្តតាមបណ្តាំនាំឱ្យ A អាចទទួលបានភាគនៃវិភាគទានតែ ៦០០ ដុល្លារអាមេរិក ប៉ុណ្ណោះ ។ បន្ទាប់ពីបែងចែកទ្រព្យ A =៦០០ ដុល្លារអាមេរិក, B = ៨០០ ដុល្លារអាមេរិក, C = ១,០០០ដុល្លារអាមេរិក => (៣,០០០-៦០០-៨០០-១,០០០ = ៦០០ ដុល្លារអាមេរិក)

[100] មាត្រា ១១៦៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

❖ ករណីមានភាគនៃវិភាគទាន និងផលប្រយោជន៍ពិសេសក្នុងពេលតែមួយ

**ឧទាហរណ៍៖** មតកជន ក មានកូនចំនួន ៣នាក់ គឺA,B និងC។ មុនពេល ក ស្លាប់បានឱ្យលុយ A ចំនួន១០,000 ដុល្លារអាមេរិក និងB ចំនួន ២,000 ដុល្លារអាមេរិក ហើយ C បានចេញថ្លៃព្យាបាល ក ដោយចំណាយអស់ ៨,000 ដុល្លារអាមេរិក ។ នៅពេលបើសន្តតិកម្ម ក បានបន្សល់ទុកមត៌កចំនួន ១៤,000 ដុល្លារអាមេរិក។

មត៌កសរុប = ១៤,000 + ១០,000 + ២,000 - ៨,000 = ១៨,000

- ចំណែកមត៌ករបស់ A = (១៨,000÷៣) - ១០,000 = -៤,000
- ចំណែកមត៌ករបស់ B = (១៨,000÷៣) - ១០,000 = ៤,000
- ចំណែកមត៌ករបស់ C = (១៨,000÷៣) - ៨,000 = ១៤,000

ដោយ A ទទួលបាននូវផលប្រយោជន៍ពិសេសលើសនូវចំណែកមត៌ក ប៉ុន្តែ A មិនចាំបាច់បង្វិលសង វិញនោះទេ។ មត៌កជាក់ស្តែងមាន ១៤,000 ដុល្លារអាមេរិក ហេតុនេះមិនអាចឱ្យទៅ B និងC ទាំងអស់បានទេត្រូវធ្វើតាមវិធានសមាមាត្រ ដូចខាងក្រោម៖

ចំណែករបស់ B = (៤,000 × ១៤,000) ÷ ១៨,000 = ៣១១១.១១ ដុល្លារអាមេរិក

ចំណែករបស់ C = (១៤,000 × ១៤,000) ÷ ១៨,000 = ១០,៨៨៨.៨៩ ដុល្លារអាមេរិក

**៣.៣.១.៥. ប្រទានកម្ម**

កិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួលគេហៅថា "ប្រទានកម្ម" ។[101] អ្នកដែលទទួលទ្រព្យហៅថា "បដិគ្គាហក" និងអ្នកឱ្យទ្រព្យហៅថា "ទាយក"។ ក្នុងករណី បដិគ្គាហកបានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬវិនាសនៅមុនពេលចាប់ផ្តើមសន្តតិកម្ម។ គេត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬនៅពេលបាត់បង់ ឬវិនាសនោះ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហកបានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មត្រូវគណនាដោយចាត់ទុកថាមានស្ថានភាពដើមនៅពេលចាប់ផ្តើមសន្តតិកម្ម។ ការប្រាក់ និងផលចំណេញកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួលពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ។ តម្លៃផលប្រយោជន៍ពិសេស៖

- . ផលប្រយោជន៍ពិសេសកើនឡើង៖ យកតម្លៃថ្ងៃធ្វើប្រទានកម្មមកធ្វើការគណនា

[101] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៤, លេខ ៩៩

- ផលប្រយោជន៍ពិសេសធ្លាក់ចុះ៖ យកតម្លៃថ្ងៃបើកសន្តតិកម្មមកធ្វើការគណនា

ឧទាហរណ៍៖ មតកជន ក មានកូនចំនួន ៣ នាក់ គឺ A, B និង C ដែលជាសន្តតិជន។ មុនពេល ក ទទួលមរណភាពបានឱ្យដីទៅ A ដែលមានតម្លៃ ២០,០០០ ដុល្លារអាមេរិក និងបានឱ្យរថយន្តដែលមានតម្លៃ ៣០,០០០ ដុល្លារអាមេរិក ទៅ B ។ ពេល ក ទទួលមរណភាពបានបន្សល់ទុកមត៌កចំនួន ៤០,០០០ ដុល្លារអាមេរិក។ ដល់ ថ្ងៃបើកសន្តតិកម្ម ដីដែលជាប្រទានកម្មបានកើនឡើងដល់ ៤០,០០០ ដុល្លារអាមេរិក រីឯតម្លៃនៃរថយន្តនៅថ្ងៃ បើកសន្តតិកម្មបានធ្លាក់ចុះសល់ ១០,០០០ ដុល្លារអាមេរិក។

**យោងតាមមាត្រា ១១៦៤ នៃក្រមរដ្ឋប្បវេណី៖**

- ការគណនាតម្លៃដីដែល ក បានធ្វើប្រទានកម្មមកឱ្យ A គឺត្រូវយកតម្លៃនៅថ្ងៃធ្វើប្រទានកម្មគឺ ២០,០០០ ដុល្លារអាមេរិក
- ការគណនាតម្លៃរថយន្តដែល ក បានធ្វើប្រទានកម្មមកឱ្យ B គឺត្រូវយកតម្លៃនៅថ្ងៃបើក សន្តតិកម្មគឺ ១០,០០០ ដុល្លារអាមេរិក

ចំណែកមត៌កសរុប = ៤០,០០០ + ២០,០០០ + ១០,០០០ = ៧០,០០០ ដុល្លារអាមេរិក

**គ.ស្ថានភាពពិសេស**

ស្ថានភាពពិសេសនៃសន្តតិកម្ម គឺជាករណីដែលសន្តតិកម្មចាប់ផ្តើម ដោយគ្មានសន្តតិជន ដែលជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចរបស់មត៌ក ដោយតម្រូវឱ្យមានការស្វែងរកសន្តតិជន ដើម្បីមកស្នងមត៌កទាំងនោះ និងនៅក្នុងករណីគ្មានសន្តតិជន នាំឱ្យមត៌កទាំងនោះអាចត្រូវធ្លាក់ទៅជនមាននិស្ស័យពិសេស (នត្ថិភាពនៃសន្តតិជន)។ មួយវិញទៀត ស្ថានភាពពិសេសនៃសន្តតិកម្ម អាចកើតឡើងបានផងដែរ នៅក្នុងករណី ជនដែលមើលខាងក្រៅហាក់ដូចជាសន្តតិជន បានស្នងមត៌ក និងកាន់កាប់មត៌កនោះដោយគ្មានមូលហេតុគតិយុត្ត ដែលជាមូលហេតុនាំឱ្យសន្តតិជនពិតប្រាកដ អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានផងដែរ។

**ខ.នត្ថិភាពនៃសន្តតិជន**

**ខ.១. នីតិបុគ្គលមត៌ក**

ប្រសិនបើពុំច្បាស់ថាមានសន្តតិជន មត៌កទាំងនោះត្រូវក្លាយជានីតិបុគ្គល។[102] អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ សន្តតិកម្ម ហៅថា "នីតិបុគ្គលមត៌ក" ត្រូវជ្រើសតាំងដោយតុលាការ តាមរយៈពាក្យសុំរបស់បុគ្គលណាម្នាក់ដូចជា៖

- បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍

[102] មាត្រា ១២៩០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

- មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានចុងក្រោយរបស់មតកជន ឬ
- តំណាងអយ្យការ។[103]

នីតិបុគ្គលមត៌កត្រូវគ្រប់គ្រងដោយអ្នកគ្រប់គ្រងមត៌ក។ ការងារសំខាន់ៗរបស់អ្នកគ្រប់គ្រងមត៌ក គឺការក្តាប់ឱ្យដឹងពីមត៌កទាំងអស់ ការសងបំណុលរបស់មតកជន ហើយការបែងចែកមត៌កដែលនៅសល់ទៅឱ្យអ្នកមាននិស្ស័យពិសេស ឬបង្វិលមត៌កនោះទៅឱ្យរដ្ឋ ហើយដើម្បីធ្វើការទាំងនោះក្នុងករណីចាំបាច់ត្រូវចាត់ចែងប្តូរមត៌កនោះឱ្យទៅជាប្រាក់ ដោយត្រូវមានការអនុញ្ញាតពីតុលាការ។ អ្នកគ្រប់គ្រងមត៌ក ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌទាក់ទងនឹងមត៌ក ហើយការធ្វើបញ្ជីនេះត្រូវធ្វើដោយរាប់បញ្ចូលទាំងទ្រព្យសកម្ម និង រាល់កាតព្វកិច្ចនៃសន្តតិកម្មដែលអាចដឹងឮបាន។[104] តុលាការអាចផ្តល់កម្រៃសមរម្យចេញពីក្នុងចំណោមមត៌កឱ្យទៅអ្នកគ្រប់គ្រងបានដោយយកតម្លៃ មត៌កអំឡុងពេលគ្រប់គ្រងកិច្ចការដែលត្រូវធ្វើមកធ្វើជាមូលដ្ឋាននៃការគណនាដើម្បីសម្រេចនូវកម្រៃដោយលក្ខណៈសត្យានុម័ត។[105] ប្រសិនបើដឹងថាមានសន្តតិជន ក្រោយពេលជ្រើសតាំងអ្នកគ្រប់គ្រងមត៌កនោះ នីតិបុគ្គលមត៌កត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង។[106]ករណីនេះសិទ្ធិអំណាចនៃអ្នកគ្រប់គ្រងមត៌កត្រូវ ផុតរលត់ដរាបណាសន្តតិជនយល់ព្រមទទួលសន្តតិកម្ម ហើយអ្នកគ្រប់គ្រងមត៌កត្រូវបង្ហាញឱ្យបាន ច្បាស់លាស់នូវស្ថានភាពដែលខ្លួនបានគ្រប់គ្រងតាំងពីពេលចាប់ផ្តើមរហូតដល់ពេលសន្តតិជននោះយល់ ព្រមទទួលសន្តតិកម្ម។[107]

អ្នកគ្រប់គ្រងមត៌ក ត្រូវជូនដំណឹងជាសាធារណៈបន្ទាប់ពីរយៈពេល ២ (ពីរ) ខែ បានកន្លងផុតទៅម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីទាំងអស់អំពីការណ៍ដែលម្ចាស់បំណុល និងអច្ច័យលាភីទាំងនោះត្រូវស្នើ សុំអំពីការទាមទារក្នុងអំឡុងពេលដែលបានកំណត់។ អំឡុងពេលនេះមិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ។ [108] បន្ទាប់ពីរយៈពេលនៃការជូនដំណឹងកន្លងផុត ប្រសិនបើនៅតែគ្មានដំណឹងពីសន្តតិជន គេអាចដកហូតសិទ្ធិសន្តតិជនបាន។ ការដកហូតសិទ្ធិសន្តតិជន គឺជារបបមួយដែលបង្កើតឡើងដើម្បីធ្វើការសម្រេចឱ្យបានឆាប់រហ័សនូវអ្នកដែលត្រូវទទួលមត៌ក ក្នុងករណីដែលមានមត៌ក ហើយក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មាន

[103] មាត្រា ១២៨០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[104] មាត្រា ១២៨១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ ២០០៧

[105] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះទី៨-៩ មាត្រា១២៨២, ទំព័រ ១៥៣

[106] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះទី៨-៩ មាត្រា១២៨២, ទំព័រ ១៥៤

[107] មាត្រា ១២៨៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[108] មាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

សល់មត៌ក បន្ទាប់ពីការសងបំណុលរបស់មតកជនទេ បើទោះបីជាខិតខំស្វែងរកសន្តតិជនក៏គ្មានប្រយោជន៍ដែរ ដូចនេះតុលាការមិនចាំបាច់ស្វែងរកសន្តតិជនទេ។[109]

**ខ.២. ចំណែកចំពោះជនដែលមាននិស្ស័យពិសេស**

ជនដែលមាននិស្ស័យពិសេស អាចដាក់ពាក្យសុំទៅតុលាការបាន បន្ទាប់ពីអំឡុងពេលស្វែងរកសន្តតិជនបានផុតទៅក្នុងអំឡុងពេល ៣ (បី) ខែ ដើម្បីឱ្យតុលាការចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ឱ្យខ្លួន បានតាមរយៈដីកាសម្រេច។[110] ជនដែលមាននិស្ស័យពិសេស ត្រូវបង្ហាញភស្តុតាងពីនិស្ស័យពិសេសរបស់ខ្លួនជាមួយនឹងមតកជន ទោះបីជាជននោះពុំមានទំនាក់ទំនងញាតិជាមួយមតកជនក៏ដោយ លុះត្រាណាជននោះបានបង្ហាញភស្តុតាងដូចខាងក្រោម៖

- មានជីវភាពជាមួយគ្នានឹងមតកជន
- បានខិតខំមើលថែទាំព្យាបាលមតកជន
- មាននិស្ស័យពិសេសផ្សេងទៀត។

ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកឱ្យទៅជនដែលមាននិស្ស័យពិសេស មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ។

**ខ.៣.មត៌កដែលក្លាយជារបស់រដ្ឋ**

ចំពោះមត៌ក (អចលនវត្ថុ) ដែលជាកម្មវត្ថុនៃសន្តតិកម្ម ប្រសិនបើគ្មានសន្តតិជនស្នងលើអចលនវត្ថុនោះទេ ត្រូវក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ រីឯចំណែកដែលនៅសល់ពីការបែងចែកទៅឱ្យជនដែលមាននិស្ស័យពិសេស និងក្លាយជារបស់រដ្ឋផងដែរ។ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការដោយគ្មានការយឺតយ៉ាវ។

**គ.ការធ្វើបដិទាននៃសន្តតិកម្ម**

បដិទានសន្តតិកម្ម គឺជាការទាមទារមួយដែលជាសិទ្ធិរបស់សន្តតិជនពិតប្រាកដធ្វើការទាមទារចំណែកមត៌កនៃសន្តតិកម្ម ពីបុគ្គលដែលត្រូវបានគេឃើញថាជាសន្តតិជន ប៉ុន្តែការពិតជននោះពុំមែនជាសន្តតិ ជនពិតប្រាកដនោះទេ ដូច្នេះសន្តតិជនពិតប្រាកដអាចទាមទារឱ្យជននោះប្រគល់ចំណែកមត៌កនៃសន្តតិកម្ម នោះមកវិញ។ ហើយការទាមទារឱ្យធ្វើបដិទាននេះទៀតសោត មានភាពខុសគ្នានឹងករណីដែលសន្តតិជនធ្វើ ការទាមទារដើម្បីយកមត៌កមកវិញ ព្រោះថាតតិយជនដែលមិនពាក់ព័ន្ធបានកាន់កាប់មត៌កនោះដោយគ្មាន សិទ្ធិនាំឱ្យមានមូល

[109] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះទី៨-៩ មាត្រា១២៩៧, ទំព័រ ១៥៧

[110] មាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ដ្ឋានគតិយុត្តក្នុងការកាន់កាប់ ហើយការទាមទារដើម្បីយកមត៌កមកវិញគឺអាចទាមទារតាម បញ្ញត្តិស្ដីពីសិទ្ធិប្រត្យក្ស ជាអាទិ៍។ ស្ថានភាពដែលអាចឱ្យកើតមានការធ្វើបដិទានសន្តតិកម្មមានដូចខាងក្រោមៈ

**ទី១៖** ការក្លែងបន្លំសំបុត្រកំណើតរបស់កូន ដែលមិនមែនជាកូនរបស់មតកជនពិតប្រាកដ។

**ទី២៖** ករណីដែលមតកជនមានកូនជាមួយអ្នកផ្សេង ហើយមិនបានទាក់ទងជាមួយគ្នាយូរ ហើយសន្តតិកម្មធ្វើឡើងតែក្នុងរង្វង់គ្រួសារថ្មី ជាអាទិ៍។

**ទី៣៖** សន្តតិជនណាមួយបានទទួលនូវសន្តតិកម្មលើសចំណែកមត៌ករបស់ខ្លួន។[111]

ក្នុងករណីដែលជនដែលមិនមែនជាសន្តតិជនពិតប្រាកដបានទទួលនូវចំណែកសន្តតិកម្ម ហើយបានលក់ទ្រព្យនោះទៅឱ្យតតិយជនបាត់ហើយ ជាគោលការណ៍គឺមិនអាចទាមទារឱ្យធ្វើបដិទានចំពោះអ្នកទិញបានទេ ដោយអាចត្រឹមតែទាមទារនូវថ្លៃលក់ដែលជាវត្ថុជំនួសមត៌កនោះប៉ុណ្ណោះ។[112] ប្រសិនបើអ្នកទិញដឹងថាសន្តតិ ជនដែលជាអ្នកលក់នោះគ្មានសិទ្ធិសន្តតិកម្មនៅលើមត៌កនេះ ហើយនៅតែធ្វើកិច្ចព្រមព្រៀងលក់ទិញទៀត សន្តតិជនពិតប្រាកដអាចទាមទារនូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញបានមកវិញ ដោយអះអាងថាកម្មសិទ្ធិនៃវត្ថុនោះមិនត្រូវបានផ្ទេរទៅអ្នកទិញឡើយ ព្រោះអ្នកទិញទុច្ចរិត និងមានកំហុស។[113] ម្យ៉ាងទៀត ជនដែលមិន មែនជាសន្តតិជនពិតប្រាកដ ត្រូវប្រគល់មកវិញនូវទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្មទៅឱ្យសន្តតិជនពិតប្រាកដ តាមរយៈការទាមទារ។ ប្រសិនបើជនដែលមិនមែនជាសន្តតិជនពិតប្រាកដនោះជាបុគ្គលសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និងការប្រាក់ដែលបានទទួល និងមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលខ្លួនបាន សងតាមរយៈសន្តតិកម្មនោះបាន។[114] ផ្ទុយទៅវិញ ប្រសិនបើជននោះទុច្ចរិត ជននោះមានកាតព្វកិច្ចប្រគល់មកវិញនូវផល និងការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃ ចំពោះទ្រព្យនោះផង។[115] អ្នកដែលមានសិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវអនុវត្តសិទ្ធិរបស់ខ្លួននៅក្នុង អំឡុងពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតតាមរ

[111] សេចក្ដីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹទី៨-៩ មាត្រា១២៩៧, ទំព័រ ១៦២-១៦៣

[112] មាត្រា ១៣០២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ ២០០៧

[113] សេចក្ដីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹទី៨-៩ មាត្រា១៣០២, ទំព័រ ១៦៣

[114] មាត្រា ១៣០៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ ២០០៧

[115] មាត្រា ១៣០៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ ២០០៧

យៈមតកសាសន៍ ឬការពិភាក្សាបែងចែកមត៌ក ឬនៅក្នុងករណីជនម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជនមានអំឡុងពេល ០៥(ប្រាំ)ឆ្នាំ ដោយអាជ្ញាយុកាលនេះ ត្រូវគិតចាប់ពីថ្ងៃមតកជនបានទទួលមរណភាព។[116]

**៣.៣.២.ភាគបម្រុង**

ដោយបានរៀបរាប់ខាងលើមកហើយថា មតកជនអាចសម្រេចចិត្តដោយខ្លួនឯងអំពីនីតិវិធីនៃការបែងចែក ទ្រព្យសម្បត្តិក្រោយពីទទួលមរណភាព តាមរយៈការធ្វើមតកសាសន៍បាន។ ប៉ុន្តែ ដោយសារតែមតកជនបានបែង ចែកមត៌ករបស់គាត់ទៅតាមឆន្ទៈផ្ទាល់ ទើបក្រមរដ្ឋប្បវេណីបញ្ញត្តិអំពីប្រព័ន្ធមួយដែលហៅថា ភាគបម្រុង។ នៅក្នុងចំណោមចំណែកមត៌ករបស់សន្តតិជន ភាគបម្រុង គឺជាផ្នែកមួយដែលមិនអាចធ្វើការបំពានដោយមតកសាសន៍ ជាអាទិ៍ បានឡើយ។

ជាទូទៅ តាមរយៈសន្តតិកម្មតាមមតកសាសន៍ (បណ្តាំ) មតកជនអាចបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន បន្ទាប់ពីខ្លួនទទួលមរណភាព។ ប៉ុន្តែ ជម្រើសនៃការបែងចែកមត៌កតាមវិធីនេះអាចនឹងមានការបំពានដល់ចំណែករបស់សន្តតិជនណាមួយ ក្នុងករណីមតកជនបានកំណត់ក្នុងបណ្តាំថានឹងបែងចែកចំនួនលើសលុបឱ្យទៅសន្តតិជនណាម្នាក់ ជាហេតុធ្វើឱ្យសន្តតិជនម្នាក់ទៀតទទួលបានមត៌កតិចជាងសន្តតិជនផ្សេងទៀត។ ដើម្បីសម្រួលស្ថានភាពបែបនេះ ទើបក្រមរដ្ឋប្បវេណីបានកំណត់នូវបញ្ញត្តិមួយឡើងដើម្បីធានាថាគ្មានការបំពានលើចំណែកមត៌ក ដែលត្រូវទទួលបានដោយសន្តតិជន ដែលរបបមួយនេះហៅថាភាគបម្រុង។

បទបញ្ញត្តិ ស្តីពីភាគបម្រុងនេះទៀតសោតត្រូវបានបង្កើតឡើង ក្នុងគោលបំណងការការពារចាត់ចែងទ្រព្យសម្បត្តិដោយមានភាពសុក្រិត សមភាព និងមិនលំអៀង ឬការមិនរំលោភទៅលើចំណែកមត៌ករបស់សន្តតិជនណាម្នាក់ ដែលធ្វើឡើងដោយមតកជន ដូចជាធានាបាននូវចំណែកមត៌កជាក់លាក់នឹងត្រឹមត្រូវមួយសម្រាប់ជនដែលនឹងត្រូវមានសិទ្ធិទទួលបានមតិក។ មតកជន មានសិទ្ធិធ្វើការបែងចែកមត៌ករបស់គាត់បានគ្រប់រូបភាព ក៏ប៉ុន្តែត្រូវគោរពលក្ខខណ្ឌតាមគោលការណ៍ភាគបម្រុង។[117]

**៣.៣.២.១.និយមន័យ**

ក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្ន មិនមានមាត្រាណាមួយកំណត់និយមន័យជាក់លាក់អំពី អ្វីទៅជាភាគបម្រុងនោះទេ។ ប៉ុន្តែបើយើងក្រឡេកទៅមើលក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧ ឃើញថាបានឱ្យនិយមន័យថា ៖

---

[116] មាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[117] www.ciclyg.com,ហ្វេសបុកផេក៖ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ / Cambodia International Cooperation law

ភាគបម្រុង គឺជារបបមួយនៃបេតិកភណ្ឌ ដែលម្ចាស់បណ្តាំខ្លួនឯងផ្ទាល់ ក៏មិនអាចនឹងចាត់ចែងយ៉ាងណាៗ ដោយសេរីបានឡើយ។[118]

ទោះបីជាក្រមរដ្ឋប្បវេណីមិនបានអោយនិយមន័យនៃរបបភាគបម្រុងនេះក៏ដោយតែយើងអាចកំណត់អំពីអត្ថន័យនៃរបបនេះតាមរយៈការសិក្សាលើមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ថាភាគបម្រុង គឺជាសិទ្ធិដែលទទួលបានមត៌កជាអប្បរមាដែលត្រូវធានាដោយច្បាប់ចំពោះអ្នកមានសិទ្ធិលើភាគបម្រុង។

### ៣.៣.២.២.អ្នកដែលមានសិទ្ធិលើភាគបម្រុង

នៅក្នុងក្រមរដ្ឋប្បវេណី បានកំណត់យកអ្នកដែលមានសិទ្ធិលើភាគបម្រុងមានដូចជាៈ បច្ឆាញាតិផ្ទាល់ ឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជន។ មានន័យថាអ្នកដែលត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនផ្អែកតាមបញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ និងក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង។ លើស ពីនេះទៅទៀតជាគោលការណ៍នៃភាគបម្រុង គឺ ១/២ នៃមតិករបស់មតកជនលើកលែងតែឪពុកម្តាយ ឬជីដូនជីតា ជាសន្តតិជនដែលភាគបម្រុងគឺ ១/៣ នៃមត៌ករបស់មតកជន។ ចំណែកឯ បងប្អូនបង្កើត (សន្តតិជនលំដាប់ទី៣) មិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ ទោះបីត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនក៏ដោយ។

### ៣.៣.២.៣.លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង

ដោយយើងបានដឹងហើយថាសន្តតិជនមានច្រើនប្រភេទ ដូចជាបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់។ ប៉ុន្តែមានតែសន្តតិជនមួយចំនួនប៉ុណ្ណោះ ទើបត្រូវចាត់ទុកជាអ្នកមានសិទ្ធិលើភាគបម្រុងដែលមានដូចជាៈ

- បច្ឆាញាតិរបស់មតលជន
- ឪពុកម្តាយរបស់មតកជន
- ជីដូនជីតារបស់មតកជន
- សហព័ទ្ធរបស់មតកជន។

លក្ខណៈក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង ពុំមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែយើងអាចធ្វើការកត់សម្គាល់ អំពីលក្ខណៈសម្បត្តិ ដើម្បីក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបាន លុះត្រាតែបំពេញនូវលក្ខខណ្ឌ ពីរយ៉ាងគឺ ទី១ អ្នកមានសិទ្ធិលើភាគបម្រុងត្រូវតែជាសន្តតិជនដែលកំណត់ដោយច្បាប់ ហើយលក្ខណៈក្លាយជា សន្តតិជននេះ ក៏មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីផងដែរ។ បន្ថែមពីនេះទៅទៀត ភាពដែលជាសន្តតិជនតែ មួយមុខមិនអាចគ្រប់គ្រាន់នៅឡើយទេគឺ ទី២ វាទាមទារឱ្យមាននូវការបំពានចំណែកមត៌កមួយទៀត ដែលជាធាតុសំខាន់ដែលមិនអាចខ្វះបាន។

[118]មាត្រា៥២៨ ក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧

❖ **បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន**

សន្តតិជនដែលអាចទទួលមត៌កបានលុះត្រាតែបុគ្គលនោះ ជាសន្តតិជនដែលមានជីវិតនៅរស់នៅពេល ចាប់ផ្ដើមសន្តតិកម្មតែប៉ុណ្ណោះ។ ប្រសិនបើជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ បានទទួលមរណភាព មុនពេល ឬតំណាលគ្នានឹងមតកជននោះ សន្តតិជនមិនអាចបំពេញលក្ខខណ្ឌនៅមានជីវិតរស់នៅពេលចាប់ផ្ដើមសន្តតិកម្មនោះទេ ដូច្នេះ មិនអាចទទួលបានសន្តតិកម្មឡើយ។ លើសពីនេះសន្តតិជនត្រូវតែមិនមែនជាអភ័ព្វបុគ្គលហើយត្រូវផ្ដាច់ចេញពីមតិក។[119]

❖ **មានការបំពានលើចំណែកមត៌ក**

ការបំពានលើចំណែកមត៌ករបស់សន្តតិជន គឺជាធាតុមួយដ៏សំខាន់ ដែលមិនអាចខ្វះបានទេ ប្រសិនបើមិនមានការបំពានលើចំណែកមដឹកទេនោះ សន្តតិជនមិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគភាគបម្រុងបានទេ។ **ឧទាហរណ៍៖** មតកជនមាន កូន២ (ពីរ) នាក់ និងសហព័ទ្ធដោយមតកជនបានបន្សល់ទុកនូវទ្រព្យមួយ ចំនួន ១០,០០០០ដុល្លារ។ នៅក្នុងមតកសាសន៍បានកំណត់បែងចែកទ្រព្យសម្បត្តិ ៣០,០០០ដុល្លារ ឱ្យទៅ សហព័ទ្ធ ហើយកូនម្នាក់ៗបាន ៣០,០០០ដុល្លារ ចំណែក ១០,០០០ដុល្លារដែលនៅសល់ត្រូវឱ្យទៅបងរបស់ មតកជន។

**៣.៣.២.៤.ចំណែកនៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗ**

ការកំណត់ចំណែកមត៌ករបស់អ្នកមានសិទ្ធិលើភាគបម្រុង គឺជាអ្វីដែលច្បាប់បានកំណត់ ឬអនុញ្ញាតឱ្យអ្នកមានសិទ្ធិលើភាគបម្រុង មានសិទ្ធិទាមទារនូវចំណែកមត៌ករបស់ខ្លួន តែមិនមែនទាមទារបានដោយសេរីនោះទេ ហេតុនេះហើយបានជាច្បាប់បានកំណត់យ៉ាងជាក់លាក់ អំពីគោលការណ៍នៃចំណែកមត៌ក។

នៅក្នុងការបែងចែកចំណែកនៃភាគបម្រុងនេះ វាពុំមានលក្ខណៈស្មើគ្នានោះទេ គឺវាអាស្រ័យទៅតាមលំដាប់ និងចំនួនសន្តតិជនប៉ុណ្ណោះ។ ខាងក្រោមនេះ គឺជាចំណែកដែលសន្តតិជនម្នាក់ៗ ទទួលបានដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍ភាគបម្រុង គឺ១ ភាគ ២ នៃមត៌ករបស់មតកជន។

• ចំពោះករណីដែលមតកជនមានតែឪពុកម្ដាយ ឬ ជីដូនជីតាសន្តតិជន

ក្នុងករណីដែលមតកជនមានតែឪពុកម្ដាយ ឬ ជីដូនជីតាជាសន្តតិជននោះភាគបម្រុងត្រូវស្មើភាគនឹង ១ ភាគ ៣ នៃទ្រព្យសម្បត្តិរបស់មតកជន។[120]

[119] មាត្រា១១៥០ និងមាត្រា១១៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[120] មាត្រា១២៣០.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍៖** មតកជន មានទ្រព្យសម្បត្តិចំនួន ៦០,០០០ដុល្លារ នោះភាគបម្រុងស្មើនឹង២០,០០០ ដុល្លារ។ បើក្នុងករណីដែលដែលមានតែកូនម្នាក់ និងសហព័ទ្ធរបស់មតកជន ជាសន្តតិជន ភាគបម្រុងសម្រាប់អ្នកទាំងនោះ គឺ ១ ភាគ ២ នៃមត៌ករបស់មតកជន។

• ករណីមានសន្តតិជនច្រើននាក់

ក្នុងករណីដែលសន្តតិជនដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗអាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន។[121]

**កំណត់សម្គាល់៖**

- សហព័ទ្ធមានសិទ្ធិលើភាគបម្រុងជានិច្ច
- បើមានសន្តតិជនលំដាប់ទី១ ជាអ្នកមានសិទ្ធិលើភាគបម្រុង នោះសន្តតិជនលំដាប់ទី២ មិនមានសិទ្ធិនោះឡើយ។

**ឧទាហរណ៍ ៖** មតកជន មិនមានកូន និងសហព័ទ្ធមានតែឪពុក និងម្តាយដូចនេះឪពុកម្តាយជាសន្តតិជនតាមច្បាប់ ករណីខាងលើភាគបម្រុង គឺ ១/៣ នៃមត៌ករបស់មតកជន ដោយសន្តតិជនមានពីរនាក់ ដូចនេះចំណែកនៃសិទ្ធិលើភាគបម្រុង ១/៣ ចែកនឹង២ = ១/៦។ តាមឧទាហរណ៍ខាងលើ ប្រសិនបើ មតកជន មានទ្រព្យ ដែលជាមូលដ្ឋានលើភាគបម្រុង មានចំនួន ៩០.០០០ ដុល្លារ។

ដូចនេះតាមសម្មតិកម្មខាងលើយើងអាចទាញបាន ៖

នាំឱ្យភាគបម្រុង = ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង x (១/៦)

នាំឱ្យភាគបម្រុង = ៩០.០០០ x (១/៦) = ១៥.០០០ ដុល្លារ

សរុបមក ចំណែកនៃមត៌ក ដែលអាចទាមទារបានពីភាគបម្រុង គឺឪពុក និងម្តាយ ទទួលបាន ១៥.០០០ដុល្លារ ស្មើគ្នា។

### ៣.៣.២.៥.ការកាត់បន្ថយភាគបម្រុង

#### ក.ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបានត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ។[122] ជនដែលត្រូវបានបំពានភាគបម្រុង អាចយកសិទ្ធិ ដែលជាកម្មវត្ថុនៃការកាត់បន្ថយនោះមកធ្វើជារបស់ខ្លួនបាន ដោយធ្វើការទាមទារឱ្យកាត់

[121] មាត្រា១២៣០.៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[122] មាត្រា១២៣០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បន្ថយអច្ច័យទាន ជាអាទិ៍ ហើយអ្នកមានសិទ្ធិលើភាគបម្រុង ឬប្រតិសិទ្ធិរបស់ខ្លួនមានសេរីភាពក្នុងការទាមទារ ឬមិនទាមទារ និងប្រសិនបើមិនទាមទារ នាំឱ្យមតកសាសន៍មានសុពលភាពពេញលេញ ហើយជាគោលការណ៍ ការទាមទារឱ្យ កាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ហេតុនេះបើមិនទាមទារ នាំឱ្យបាត់បង់នូវអានុភាពដោយស្វ័យប្រវត្តិ ក្នុងកម្រិតនៃការបំពានសិទ្ធិលើភាគបម្រុងទៅតាមកម្រិតនៃភាគបម្រុង។ ម្យ៉ាងវិញទៀត ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះ មិនចាំបាច់ធ្វើសកម្មភាពបណ្ដឹងឡើយ ដោយតម្រូវឱ្យបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ ប៉ុន្តែបើភាគីម្ខាងទៀតមិនយល់ព្រម ត្រូវដាក់ពាក្យបណ្ដឹង ហើយ ចំពោះការបង្ហាញឆន្ទៈនេះ ត្រូវធ្វើឡើងនៅអំឡុងពេលនៃអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែល ខ្លួនបានដឹងពីការចាប់ផ្ដើមសន្តតិកម្ម ឬ ៥ (ប្រាំ) ឆ្នាំគិតចាប់ពីថ្ងៃដែលចាប់ផ្ដើមសន្តតិកម្ម។ ដែលនាំឱ្យសិទ្ធិនេះ ត្រូវស្នងដោយជនដែលមានសិទ្ធិលើភាគបម្រុង ចាប់ពីពេលដែលបានបង្ហាញឆន្ទៈនោះ ហេតុនេះទោះបីជាដាក់ ពាក្យបណ្ដឹងក្រោយ អំឡុងពេលនេះ ក៏មិនមានបញ្ហាអ្វីឡើយ។[123]

**ខ.លំដាប់នៃការកាត់បន្ថយនៃភាគបម្រុង**

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង រួមមាន អច្ច័យទាន ការកំណត់ចំណែកមត៌ក តាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្ម ។[124] ដើម្បីដឹងថាតើការកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងយ៉ាងដូចម្ដេចនោះ ច្បាប់ក៏បានកំណត់ពីលំដាប់នៃការកាត់បន្ថយផងដែរ។

នៅពេលដែលមានការបំពានភាគបម្រុង អច្ច័យទាន និងចំណែកមត៌ករបស់សន្តតិជននឹងក្លាយជា កម្មវត្ថុនៃការកាត់បន្ថយ មុនដំបូងគេ ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើ ចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ក្នុងគោលគំនិតធ្វើឱ្យមានភាពច្បាស់លាស់នៃនីតិវិធីកាត់បន្ថយអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ក្នុងមតកសាសន៍ និងធ្វើចំណាត់ថ្នាក់នៃអច្ច័យទានរបស់សន្តតិជន និងអច្ច័យ ទានរបស់តតិយជន ដោយហេតុថា សន្តតិជនត្រូវទទួលសន្តតិកម្មនូវឋានៈជាកូនបំណុលនៃអច្ច័យទាន ពីមតកជន ហេតុនេះ ជាដំបូងត្រូវសម្រួលផ្ទៃក្នុងសន្តតិជនជាមុនសិន ហើយប្រសិនបើមិនគ្រប់ទេត្រូវកាត់បន្ថយ ពីតតិយជន។ មួយវិញទៀត អច្ច័យទាន និងចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិ ជាក់លាក់ត្រូវធ្វើ ការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុ ប៉ុន្តែចំពោះករណីអច្ច័យទានរបស់សន្តតិ ជននឹងចំណែក មត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង ផ្នែកដែលលើសពីចំនួនទឹក ប្រាក់នៃភាគ បម្រុងរបស់សន្តតិជន ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ។ លើសពីនេះទៅទៀត ក្នុងករណី

[123] នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប) បង្រៀនដោយ៖ មេធាវី ប៉ូលី ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី

[124] មាត្រា១២៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មានការកំណត់នូវចំណែកមត៌ក ភាគនៃមត៌កត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង លើកលែងតែមតកជន បង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។

មួយវិញទៀតចំពោះប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេស មិនអាចកាត់បន្ថយបានឡើយ ដរាបណាអច្ច័យទាន និងការកំណត់ចំណែកមត៌ក មិនទាន់បានកាត់បន្ថយជាមុននោះទេ។[125] ខ្លឹមសារខាងលើនេះមានន័យ ត្រូវយកអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ មកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយ មុនប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេស។[126] ដោយគោលគំនិតនៃរបបភាគបម្រុង គឺដើម្បីធានាទុកនូវមត៌កមួយភាគសម្រាប់ឱ្យជនដែលមានសិទ្ធិលើភាគបម្រុង។ ប៉ុន្តែ ក្នុងករណីដែលមានការកាត់បន្ថយមត៌កនាំឱ្យទៅជាការបំពានទៅលើភាគបម្រុងទៅវិញ ដោយសារការធ្វើប្រទានកម្មពេលនៅរស់ ដូចនេះ ប្រទានកម្ម ក៏ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយផងដែរ។

ក្នុងករណីដែលមតកជនបានធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិជាច្រើន ទៅឱ្យជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍ នាពេលនៅរស់ ការកាត់បន្ថយប្រទានកម្ម ឬផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ ប៉ុន្តែប្រសិនបើជនដែលត្រូវបានកាត់បន្ថយនោះជាសន្តតិជន ហើយសាមីខ្លួនត្រូវបានបំពានដោយសារការកាត់បន្ថយនោះ ការកាត់បន្ថយនោះត្រូវធ្វើឡើងដោយដកភាគបម្រុង របស់សន្តតិជននោះជាមុនសិន។ មួយវិញទៀត នៅក្នុងករណីដែលប្រទានកម្ម ឬផលប្រយោជន៍ពិសេសនោះ ត្រូវបានធ្វើឡើងលើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស អាចបដិសេធនូវការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ បានដែលនេះគឺជាគោលគំនិតនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដោយបន្ថែមនូវចំនួនឆ្នាំដើម្បីឱ្យមានសមភាពរវាងសន្តតិជន និងអ្នកទទួលផលប្រយោជន៍ពិសេស។

### ៣.៣.២.៦.ការសងផលមកវិញចំពោះបុគ្គលមានសិទ្ធិលើភាគបម្រុង

នៅពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទាមទារទៅឱ្យជនដែលមានករណីយកិច្ច ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ជាអាទិ៍) ដែលត្រូវបានទាមទារឱ្យកាត់បន្ថយ ភាគបម្រុង ត្រូវសងផលមកវិញនូវផលដែលកើតឡើង ចាប់ពីកាលបរិច្ឆេទ ដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ដោយរាប់បញ្ចូលទាំងប្រាក់សំណងផងដែរ។ ផ្ទុយទៅវិញ ប្រសិនបើ សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ មិនអាចសងទ្រព្យ ដែលបានទទួលពីមតកជនវិញបាន ឬមិនអាច

[125] មាត្រា១២៣៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[126] មាត្រា១២៣៦.២ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ក្រសួងយុត្តិធម៌ ២០១០

សងនូវតម្លៃទ្រព្យនោះ ដោយសារអសាធនភាព ការខាតបង់នេះត្រូវធ្លាក់បន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ដែលជាគោលការណ៍អ្នកមានសិទ្ធិលើភាគបម្រុងជាអ្នកទទួលបន្ទុក ហើយមិនអាចទាមទារឱ្យអ្នកមានកាតព្វកិច្ច នៅក្នុងលំដាប់បន្ទាប់សងនូវចំណែកដែលខ្លួនមានសិទ្ធិនោះទេ។

**ឧទាហរណ៍៖** ម្ចាស់បណ្តាំ (ក) បានធ្វើប្រទានកម្មនូវផ្ទះវីឡាសម្រាប់ជួលឱ្យទៅ (ខ) ដោយផលដែលកើតចេញពីផ្ទះវីឡា ជួលក្នុងមួយខែ៣០០០ដុល្លារ ដោយ (ខ) ទទួលបាន៣០០០ដុល្លារ ជារៀងរាល់ខែ ហើយម្ចាស់បណ្តាំបានទទួលមរណភាពនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ហើយនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២៣ សន្តតិជនរបស់ (ក) ក៏បានទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងពី (ខ) ចំពោះផ្ទះវីឡាទាំងមូលហើយ (ខ) ក៏បានប្រគល់ផ្ទះនោះនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២៣។ ដោយ (ខ) បានទទួលផលដែលកើតចេញពីកម្មវត្ថុនៃ ការទាមទារឱ្យកាត់បន្ថយ គឺការបានប្រាក់ឈ្នួលពីការជួលផ្ទះចំនួន ៦ខែ។ ដូនេះ ៦x៣០០០=១៨,០០០ ដុល្លារ ដូច្នេះ (ខ) ត្រូវកាត់ទឹកប្រាក់ចំនួន ៣ខែ ដែលស្មើនឹង ៩,០០០ដុល្លារ ប្រគល់ទៅឱ្យសន្តតិជនរបស់ (ក) ដោយសារការទាមទារនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ហើយទឹកប្រាក់ដែលនៅសល់ចំនួន ៩,០០០ដុល្លារ (ខ) អាចរក្សាទុកបាន ដោយមិនត្រូវបានទាមទារឱ្យកាត់បន្ថយភាគបម្រុងនោះទេ។

### ៣.៣.២.៧.ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

#### ក.អាជ្ញាយុកាល

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម។

ការរំលត់ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជន ផ្សេងទៀតទេ។[127]

ចំពោះប្រទានកម្ម ក្នុងករណីដែលបានធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធ នូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន។[128]

[127] មាត្រា១២៩៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[128] មាត្រា១២៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ខ.ការបោះបង់ភាគបម្រុង**

ភាគបម្រុងអាចបោះបង់ចោលទាំងអស់ ឬមួយផ្នែកបាន។[129] ការបោះបង់ភាគបម្រុង គឺអាចធ្វើបាន ដោយការបង្ហាញឆន្ទៈតែម្ខាងចំពោះអ្នកមានកាតព្វកិច្ច។ ឧទាហរណ៍ ដូចជាការទទួលប្រាក់កំណត់មួយពីជនដែលមានកាតព្វកិច្ច ហើយជាថ្នូរ គឺត្រូវបោះបង់នូវភាគបម្រុងដែលនៅខ្វះជាដើម។

ចំណែកឯ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្មមានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ។[130] ការណ៍នេះ ដើម្បីកុំឱ្យមានការបោះបង់សិទ្ធិនោះជាមុន ដោយសារតែចាញ់អំណាចរបស់ឪពុកម្ដាយ ជាអាទិ៍ ប៉ុន្តែប្រសិនបើមានការបោះបង់ ចាំបាច់ត្រូវតែមានការពិនិត្យតាងនាមជាអាណាព្យាបាលដោយតុលាការ។ តុលាការដែលទទួលពាក្យសុំអនុញ្ញាតនោះ ត្រូវធ្វើការវិនិច្ឆ័យដោយពិនិត្យមើល ថាតើការបោះបង់នោះជាឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុងឬទេ តើការបោះបង់នោះមានភាពសមហេតុផលដែរឬទេ តើចាំបាច់បោះបង់ឬទេ តើមានតម្លៃជាថ្នូរដែរឬទេ។

ម្យ៉ាងទៀតទោះបីជាបានបោះបង់សិទ្ធិនេះ មុនពេលចាប់ផ្តើមសន្តតិកម្មដោយទទួលការអនុញ្ញាតពីតុលាការ ក៏ដោយ ក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចដាក់ពាក្យសុំឱ្យតុលាការលុបចោលការអនុញ្ញាតមុននោះបាន នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរក្រោយពេលបោះបង់សិទ្ធិនោះ។

[129] មាត្រា១២៥៦.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[130] មាត្រា១២៥៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងប្រធានបទ សន្តតិកម្មតាមមតកសាសន៍ រួចមក យើងសង្កេតឃើញថា ប្រធានបទមួយនេះពិតជាមានសារៈសំខាន់សម្រាប់ សិស្សនិស្សិតក៏ដូចជា ប្រជាពលខ្មែរគ្រប់រូបដែលគួរគប្បីយល់ដឹងអំពីដំណើរការបញ្ជាពាក់ព័ន្ធទៅនឹងការធ្វើបណ្តាំនេះ។ ដោយនៅក្នុងសន្ទានុក្រមផ្នែករដ្ឋប្បវេណីបានឱ្យនិយន័យពាក្យថា សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬ ច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ ក្នុងនោះដែរក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញាត្តិទាក់ទងនឹងប្រភេទនៃរបបសន្តតិកម្ម គឺមានពីរប្រភេទ នោះគឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាម មតកសាសន៍។ ដោយឡែកប្រធានបទរបស់យើងនិយាយផ្តោតទៅលើអំពី សន្តតិកម្មតាមមតកសាសន៍ប៉ុណ្ណោះ តែមានបកស្រាយសញ្ញាណទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់បន្តិចបន្តួចផងដែរ ។ បើក្រឡេកមក មើលសន្តតិកម្មតាមមតកសាសន៍វិញ គឺសំដៅទៅលើ ការបង្ហាញឆន្ទៈជាឯកតោភាគីរបស់ម្ចាស់បណ្តាំ ក្នុងការ ផ្ទេរនូវសិទ្ធិ និងករណីយកិច្ចដែលធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយ អំពី ការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន បន្ទាប់ពីទទួលមរណភាព។ ដោយបានបកស្រាយ ក៏ដូចជាការរៀបរាប់ខាង លើមកហើយ តាមច្បាប់កម្ពុជាសព្វថ្ងៃ មតកសាសន៍អាចធ្វើឡើងក្រោមបិទម្រង់គឺ មតកសាសន៍ដោយលិខិត ឯកជន មតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់។ មុនពេលធ្វើបណ្តាំម្ចាស់ប ណ្តាំអាចជ្រើសរើសទម្រង់មួយក្នុងការធ្វើមតកសាសន៍ ដោយត្រូវអនុវត្តតាមច្បាប់ និងអនុលោមទៅតាមបែប បទ នីតិវិធី ក៏ដូចជាដំណើរការនីមួយៗឱ្យបានខ្ជាប់ខ្ជួន។ មួយវិញទៀត រាល់ទម្រង់លិខិតមតកសាសន៍ទាំងអស់ គិតម្រូវឱ្យមានការចូលរួមពីសាក្សីយ៉ាងតិចពីរូប លើកលែងតែទម្រង់លិខិតឯកជនដែលមិនទាមទារឱ្យមានការ ចូលរួមពីសាក្សី។ បែបបទនៃលិខិតមតកសាសន៍ដោយលិខិតឯកជន គឺម្ចាស់បណ្តាំជាអ្នកសរសេរផ្ទាល់នូវខ្លឹម សារទាំងមូលនៃការបែងចែកមត៌ក ព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាដោយសាមីខ្លួនផ្ទាល់។ ករណីដែលម្ចាស់ បណ្តាំធ្វើឡើងដោយឱ្យតតិយជនជាអ្នកសរសេរជំនួសដោយការវាយកុំព្យូទ័រ ឬដោយការសរសេរដោយដៃត្រូវចាត់ ទុកថាមោឃៈ។ ចំពោះមតកសាសន៍ដោយលិខិតយថាភូតវិញ សារការីដើរតួនាទីយ៉ាងសំខាន់ក្នុងការតាក់តែង មតកសាសន៍នេះ ដោយម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារទាំងមូលចំពោះមុខសារការីដើម្បីកត់ត្រាចូល លិខិតបណ្តាំនោះ ហើយត្រូវមានសាក្សីពីររូបយ៉ាងតិចនៅពេលធ្វើមតកសាសន៍នេះ។ ចំណែកឯ មតកសាសន៍ ដោយលិខិតសម្ងាត់វិញ គឺម្ចាស់បណ្តាំ

សរសេរដោយផ្ទាល់ ឬស្នើសុំឱ្យនរណាម្នាក់ជាអ្នកសរសេរក៏បាន។ បន្ទាប់ម្ចាស់បណ្តាំត្រូវធ្វើការចុះហត្ថលេខាដោយខ្លួនឯងផ្ទាល់ ដើម្បីបញ្ជាក់ថាលិខិតមតកសាសន៍បានកើតចេញ ពីម្ចាស់បណ្តាំយ៉ាងពិតប្រាកដ។ ហើយសារការីជាអ្នកបញ្ជាក់ ថាមានលិខិតបណ្តាំរបស់ម្ចាស់បណ្តាំយ៉ាងពិតប្រាកដមែន ហើយខ្លឹមសារនៅក្នុងលិខិតបណ្តាំត្រូវបានរក្សាទុកជាការសម្ងាត់។ ម្ចាស់បណ្តាំត្រូវដាក់លិខិត បណ្តាំនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីររូប បន្ទាប់មកសារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់ លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើស្រោមលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើស្រោមលិខិតនោះជាមួយសាក្សី និងម្ចាស់បណ្តាំ។

សរុបសេចក្តីមកការធ្វើសន្តតិកម្មតាមមតកសាសន៍ គឺត្រូវគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ជាចាំបាច់ ជាពិសេសការធ្វើទៅតាមនីតិវិធីដែលច្បាប់បានកំណត់ជាកំហិត ទើបមតកសាសន៍ដែល បានធ្វើឡើងនោះមានអានុភាពគតិយុត្តក្រោយពេលម្ចាស់បណ្តាំទទួលមរណភាព។ ការធ្វើបែបនេះ គឺគោលបំណងធានាបាននូវភាពមិនប្រក្រតីណាមួយ ក៏ដូចជាចន្លោះប្រហោងផ្នែកអ្វីមួយនៅពេលតាក់តែងលិខិត មតកសាសន៍ ចៀសវាងក្រោយពេលមតកជនបានទទួលមរណភាព មតកសាសន៍នោះមិនមានអានុភាព និង មិនមានលក្ខណៈគ្រប់គ្រាន់ ឬឆន្ទៈពិតប្រាកដដែលជាសមត្ថភាពរបស់ម្ចាស់បណ្តាំផ្ទាល់ ឬរងនូវមោឃភាព ដោយខុសលក្ខខណ្ឌគ្រឹះ ឬលក្ខខណ្ឌទម្រង់ណាមួយដែលច្បាប់បានកំណត់។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវសារណាក្រោមប្រធានបទ សន្តតិកម្មតាមមតកសាសន៍ ទាំងមូលរួចមក ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង ប្រជាពលរដ្ឋកម្ពុជា យើងខ្ញុំសូមចូលរួមផ្តល់អនុសាសន៍ខ្លះៗ ក៏ដូចជាចំណុចខ្វះខាតមួយចំនួនដែលពួកយើង មើលឃើញនៅក្នុងប្រធានបទមួយនេះក្នុងគោលបំណងចង់ឱ្យសិស្សនិស្សិត ព្រមទាំងប្រជាពលរដ្ឋទាំងអស់ គប្បី យល់ដឹងបន្ថែមអំពីច្បាប់ដែលបានចែងក្នុងក្រមរដ្ឋប្បវេណីបន្ថែមពីការតាក់តែងមតសាសន៍ និងនីតិវិធី ក៏ ដូចជា បែបបទនៃការធ្វើសន្តតិកម្មតាមមតកសាសន៍នេះ។ ដោយសង្កេតឃើញថា បញ្ហាទម្រង់នៃការតាក់តែង លិខិត មតកសាសន៍មិនទាន់យល់ដឹងឱ្យកាន់តែទូលំទូលាយនៅឡើយ វាជាបញ្ហាដែលនៅពេលមតកជនបាន ទទួល មរណភាព បែរជាបណ្តាំនោះគ្មានអានុភាព ដោយសារខុសទម្រង់ ឬលក្ខខណ្ឌណាមួយក្នុងពេល តាក់តែងមតក សាសន៍នោះ។ ទោះបីជាយ៉ាងណាបន្ទាប់ពីបានសិក្សាទៅបីប្រធានបទខាងលើរួចមក យើងខ្ញុំ សូមស្នើសុំផ្តល់ ជាអនុសាសន៍មួយចំនួនដែលជាការចូលរួមចំណែក ជាយោបល់ដើម្បីឱ្យរបបស្តីពីសន្តតិកម្ម តាមមតកសាសន៍ នេះ ទទួលបានការចាប់អារម្មណ៍ពីអ្នកសិក្សាច្បាប់ អ្នកប្រកបវិជ្ជាជីវៈ និងប្រជាពលរដ្ឋទូទៅ ដើម្បីធ្វើការត្រិះរិះ ពិចារណាបន្ថែមឈានទៅរកការវិវឌ្ឍន៍កាន់តែប្រសើរជាងនេះទៅទៀត ដែលអនុសាសន៍ទាំង នោះរួមមាន ៖

✓ ករណីមតកសាសន៍ដោយលិខិតឯកជន ឬ លិខិតសម្ងាត់ៈ គឺទម្រង់លិខិតទាំងនេះច្បាប់បាន អនុញ្ញាតឱ្យមតកជនអាចធ្វើបានដោយខ្លួនឯងផ្ទាល់ ជាហេតុដែលការការតាក់តែងឡើងរបស់គាត់អាចមិនបាន គោរពទៅតាមខ្លឹមសារច្បាប់ ឬ ទម្រង់នោះទេ ដោយមូលហេតុនៃចំណេះដឹង ជាពិសេសក៏ត្រូវមានការយល់ដឹង អំពីច្បាប់ពាក់ព័ន្ធផងដែរ។ ដូច្នេះវាអាចមានការបំពានលើភាគបម្រុងជាអាទិ៍ ដូច្នេះគួរគប្បីពិនិត្យលទ្ធភាពក្នុង ការ បង្កើតបទដ្ឋានគតិយុត្តដែលអាចផ្តល់ ភាពងាយស្រួលដល់មតកជន ដូចជាការកំណត់នូវតម្លៃ ក៏ដូចជាការ វាយ តម្លៃទ្រព្យសម្បត្តិជាក់លាក់ ដែលអាចធ្វើការបង្ហាញឆន្ទៈដោយសេរីរបស់មតកជន ដោយមិនចាំបាច់អនុវត្ត របប ភាគបម្រុងនោះទេ ដោយមូលហេតុ ទ្រព្យសម្បត្តិមានតម្លៃតិចតួចនាំឱ្យមានបញ្ហាស្មុគស្មាញ តែបើករណី ដែល ទ្រព្យសម្បត្តិមានច្រើន និងមានតម្លៃ គឺចាំបាច់ត្រូវឱ្យមានការអនុវត្តរបបភាគបម្រុងនេះជាដាច់ខាត ពីព្រោះវាជា បញ្ហាដ៏សំខាន់ដែលអាចមានការរំលោភទៅលើរបបភាគបម្រុងធ្ងន់ធ្ងរ។

✓ នីតិវិធីក្នុងការអនុវត្តមតកសាសន៍: ចំពោះសកម្មភាពរបស់អ្នកអនុវត្តមតកសាសន៍ នៅពេលកំណត់អំពីការបែងចែកចំណែកតាមខ្លឹមសារនៃមតកសាសន៍រួចរាល់ គួរកំណត់យ៉ាងជាក់លាក់ថា ត្រូវស្នើសុំដីកាសម្រេច និងរូបមន្តអនុវត្តពីតុលាការ លើខ្លឹមសារទាំងស្រុងតែម្តង។

✓ មតកសាសន៍ដោយលិខិតយថាភូត: ដោយហេតុថា មានតែសារការីប៉ុណ្ណោះដែលទទួលបានសិទ្ធិអំណាចពីរដ្ឋ និងច្បាប់ ក្នុងការតាក់តែងមតកសាសន៍ជាលិខិតយថាភូត និង មានសិទ្ធិចេញនូវរូបមន្តអនុវត្តដោយមិនចាំបាច់ឆ្លងកាត់ការបញ្ជាក់ ឬ នីតិវិធីនានាតាមផ្លូវតុលាការ ព្រោះច្បាប់បានផ្តល់ឱ្យនូវសិទ្ធិអំណាច និង សន្មតថា សារការីជាមន្ត្រីវិជ្ជាជីវៈជំនាញផ្នែកច្បាប់ ដូច្នេះសារការីដើរតួនាទី និងជាអ្នកអនុវត្តបាននូវកិច្ចការក្នុងការ តាក់តែងលិខិតមតកសាសន៍ទាំងស្រុង។ ដោយហេតុថាមតកសាសន៍ដោយលិខិតយថាភូត មានភាពច្បាស់លាស់ និង ងាយស្រួលក្នុងការអនុវត្តជាងទម្រង់មតកសាសន៍នានា ដូច្នេះដើម្បីជាភាពងាយស្រួល និងទាក់ទាញការ ចាប់អារម្មណ៍អតិថិជន ក៏ដូចជាសាធារណៈជនទទួលទូទៅទទួលមកទទួលសេវាកម្មនេះ គួរតែកំណត់នូវតម្លៃ សេវាកម្មច្បាស់លាស់មានលក្ខណៈទូទៅ ដូចជាសេវាសាធារណៈ ដើម្បីធានាតម្លាភាព និងគណនីភាពជូន ចំពោះអ្នកដែលប្រើប្រាស់សេវានោះ។

✓ បច្ចុប្បន្នកម្ពុជាមានសារការីជាច្រើន បានបំពេញមុខងាររបស់ខ្លួននៅតាមមន្ទីរសារការីជាច្រើននៅទីក្រុងភ្នំពេញ ទន្ទឹមនឹងនេះចំពោះការបំពេញមុខងាររបស់សារការីកម្ពុជាមិនទាន់មានបទដ្ឋានគតិយុត្តដែលរឹងមាំក្នុងការត្រួតពិនិត្យមុខងាររបស់សារការីនៅតាមមន្ទីរសារការីនីមួយៗនៅឡើយ។ ដូច្នេះ រដ្ឋ ឬស្ថាប័នដែលមានសមត្ថកិច្ចគួរតែចូលរួមក្នុងការធ្វើសេចក្តីព្រាង ការរៀបចំ និងការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈសារការីបន្ថែមដើម្បីត្រួតពិនិត្យមុខងាររបស់សារការីឱ្យមានភាពរឹងមាំព្រមទាំងមានភាពឈ្លាសវៃដោយឈរលើគោលការណ៍នៃការទទួលខុសត្រូវចំពោះមុខច្បាប់។

ជាកិត្តិយសរបស់យើងខ្ញុំសូមធ្វើការបង្ហាញពីទឹកចិត្តក្នុងការតម្រែតម្រង់ទិស ក៏ដូចជាសំណូមពរដល់ក្រសួងស្ថាប័ន បណ្តាភាគីពាក់ព័ន្ធទាំងអស់ ស្ថាប័នតុលាការ និងសារការី ពិសេសប្រជាពលរដ្ឋគ្រប់រូប ត្រូវតែចូលរួមអនុវត្ត និងលើកតម្កើងប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួនឱ្យមានដំណើរការប្រកបទៅដោយភាពងាយស្រួល និងមិនស្មុគស្មាញ។ ម្យ៉ាងវិញទៀត អាចធានាទៅលើរាល់ការធ្វើបណ្តាំតាមរយៈលិខិតមតកសាសន៍ឱ្យមាន ភាពត្រឹមត្រូវដោយគោរពទៅតាមទម្រង់ដែលច្បាប់បានចែងកំណត់។ ទោះបីជាច្បាប់បានកំណត់ក៏ដោយ ចំពោះ ការតាក់តែងមតកសាសន៍ សារការីត្រូវតែអនុវត្តការងាររបស់ខ្លួនឱ្យមានភាពយុត្តិធម៌ ប្រកបដោយគុណប្រយោជន៍ ទៅដល់ភាគី ពិសេសចូលរួមផ្សព្វផ្សាយឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដល់បណ្តាសាធារណៈជន ចៀស វាងការទទួលស្គាល់បាននូវភាពមិនសមប្រកប ក៏ដូចជាបំណងរបស់ម្ចាស់បណ្តាំ មិនយល់ពីផ្លូវច្បាប់ ដែលនាំឱ្យ ប្រទេសយើងជះឥទ្ធិពលណាមួយប៉ះពាល់ទៅដល់សង្គមជាតិ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

យើងខ្ញុំសូមអរគុណ យ៉ាងជ្រាវជ្រៅពីសំណាក់អ្នកសិក្សាពីគ្រប់មជ្ឈដ្ឋានដែលបានយកចិត្តទុកដាក់ តាមដានចំពោះការបកស្រាយទៅ លើប្រធានបទខាងលើនេះជាទីគាប់ប្រសើរ តាំងពីពេលចាប់ផ្តើមនៃប្រធានបទរហូតឈានមកដល់ការបញ្ចប់។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងបានផ្តល់ជាចំណេះដឹងបន្ថែម និងបំពេញនូវចំណុចពាក់ព័ន្ធ ឬ ខ្វះខាត ស្តីពីការធ្វើសន្តតិកម្មតាមមតកសាសន៍ពីមួយដំណាក់កាលទៅមួយដំណាក់កាលរហូតដល់មតកសាសន៍នោះ មានអានុភាពឈានទៅរកការបែងចែកទៅតាមចំណែកដែលមតកជនកំណត់ទៅឱ្យសន្តតិជនម្នាក់តាមឆន្ទៈផ្ទាល់របស់មតកជន។ ជាពិសេសជួយការពារផលប្រយោជន៍ ក៏ដូចជាធានាឱ្យបាននូវ យុត្តិធម៌សមភាពចំពោះ មុខច្បាប់ ព្រមទាំងគោលការណ៍នៃសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ ដោយមិនមានការរំលោភបំពានក្នុងគោល បំណងទុច្ចរិតទៅលើចំណែកអ្វីមួយរបស់ជនណាម្នាក់។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម
- លេខ នស/រកម/០២១ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រម
- លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧

## ២. ឯកសារផ្សេងទៀត

- សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-៩ រៀបរៀងដោយក្រុមការងារ ជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តី ព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ភ្នំពេញ ២០១០០
- នីតិរដ្ឋប្បវេណី១ គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា ឧបត្ថម្ភដោយអង្គការ JICA សមិទ្ធិ ផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ៣ រៀបរៀងដោយក្រុមការងារនៃគ្រូបង្គោលនៅសាលា ភូមិន្ទចៅក្រមចៅក្រម ឆ្នាំ២០១៧
- សៀវភៅមេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ រៀបរៀងដោយគម្រោង អភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈ មេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ឆ្នាំ២០១៥
- សេចក្តីផ្តើមនីតិរដ្ឋប្បវេណី និពន្ធដោយៈ សាស្ត្រាចារ្យ ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ បោះពុម្ពលើកទី៥ ភ្នំពេញ ២០១១
- សៀវភៅមេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ៣ រៀបរៀងដោយគម្រោង អភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈ មេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ឆ្នាំ២០១៧
- សៀវភៅមេរៀនសង្ខេប នីតិរដ្ឋប្បវេណី របស់សាស្ត្រាចារ្យ មេធាវី អ៊ីវ ប៉ូលី ឆ្នាំ២០១១
- សៀវភៅជំនួយស្មារតី នីតិបេតិកភណ្ឌ និង គ្រួសារ របស់សាស្ត្រាចារ្យ ព្រំ វិទ្ធី
- សៀវភៅមេរៀនសង្ខេប នីតិសន្តតិកម្ម របស់សាស្ត្រាចារ្យ ជ័យ វិទ្ធី
- សន្ទានុក្រមផ្នែក រដ្ឋប្បវេណី។

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

*ជាតិ សាសនា ព្រះមហាក្សត្រ*

# <u>លិខិតបណ្តាំមត៌ក</u>

**១. អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ(មតកជន)**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..............................ភេទ..........មុខរបរ.............................................. ថ្ងៃខែឆ្នាំកំណើត................................ជនជាតិ...........សញ្ជាតិ............កាន់អត្តសញ្ញាណប័ណ្ណលេខ: ..........................ចុះថ្ងៃទី......ខែ.......... ឆ្នាំ............មានអាសយដ្ឋានបច្ចុប្បន្ន ផ្លូវ........ក្រុម.......... ភូមិ..............ឃុំ/សង្កាត់..................ក្រុង/ស្រុក/ខណ្ឌ.....................ខេត្ត/រាជធានី.....................។

**២. ស្ថានភាពកំពុងសរសេរមតកសាសន៍**

ខ្ញុំសរសេរបណ្តាំមត៌កនេះ ក្នុងស្ថានភាពដែលខ្ញុំមានស្មារតីល្អ ដឹងច្បាស់ពីអ្វីដែលខ្ញុំកំពុងចាត់ចែង ហើយអ្វីដែលខ្ញុំកំពុងសរសេរនៅក្នុងបណ្តាំមត៌កនេះ ជាគោលបំណងរបស់ខ្ញុំនៅពេលខ្ញុំមរណភាព។

**៣. បុគ្គលដែលត្រូវទទួលមត៌ក**

អ្នកដែលត្រូវទទួលមត៌កខ្ញុំ មានជាអាទិ៍

- ឈ្មោះ..................................ត្រូវជា............................................ របស់ខ្ញុំ
- ឈ្មោះ..................................ត្រូវជា............................................ របស់ខ្ញុំ
- ឈ្មោះ..................................ត្រូវជា............................................ របស់ខ្ញុំ
- ឈ្មោះ..................................ត្រូវជា............................................ របស់ខ្ញុំ

**៤. ទំហំនៃទ្រព្យសម្បត្តិ**

ទ្រព្យសម្បត្តិមាន:.............................................................................................................

.....................................................................................................................................

បំណុល: ..........................................................................................................................

**៥. កំណត់អំពីចំណែកមត៌ក ឬ វិធីបែងចែកមត៌ក**

ក/ទ្រព្យ...................................................................ប្រគល់ឱ្យឈ្មោះ................................

ខ/ទ្រព្យ...................................................................ប្រគល់ឱ្យឈ្មោះ................................

គ/ទ្រព្យ...................................................................ប្រគល់ឱ្យឈ្មោះ................................

ឃ/ទ្រព្យ...................................................................ប្រគល់ឱ្យឈ្មោះ................................

សូមបញ្ជាក់ថា.....................................................................................................................។

**៦. កំណត់អ្នកប្រតិបត្តិមតកសាសន៍**

មេធាវី.................................ជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទទួលកម្រៃ.....................។

**៧. ផ្ដាច់មត៌ក**

ឈ្មោះ.............................មិនទទួលបានចំណែកមត៌ករបស់ខ្ញុំទេ ពីព្រោះឈ្មោះបាន...............
.................................................................... ប្រមាថមើល ងាយ ធ្វើឱ្យខ្ញុំពិបាកចិត្តគ្រប់ពេល។

**៨. អច្ច័យទាន**

.................................................................................................

.................................................................................................

**៩. ចំនួន ការរក្សាទុក បើក និងប្រកាសបណ្ដាំមត៌ក**

- បណ្ដាំមត៌កច្បាប់ដើម ធ្វើឡើងចំនួន.........ច្បាប់
- បណ្ដាំមត៌កច្បាប់ដើម រក្សាទុកនៅ.................................................................................
- បណ្ដាំមត៌កនេះ អាចបើកបាន.........ខែ ក្រោយពេលខ្ញុំទទួលមរណភាព
- បណ្ដាំនេះ ត្រូវប្រកាសនៅ...........................................................................................

**១០. បណ្ដាំចុងក្រោយរបស់ម្ចាស់បណ្ដាំ**

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

**ម្ចាស់បណ្ដាំ**

ហត្ថលេខា និងកាលបរិច្ឆេទ

# គម្រូវលិខិតបណ្តាំមត៌ក

(លិខិតបណ្តាំតាមទម្រង់លិខិតឯកជន)

មត្រា១១៧៤

## ១. អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ (មតកជន)

ឈ្មោះ.................................................................................................... .............
.......................................................................................................................................
....................................................................................................................................។

(ចំណុចនេះអាចបញ្ជាក់អំពីសមត្ថភាពរបស់បុគ្គលដែលអាចធ្វើមតកសាសន៍)

មាត្រា១១៦៨

## ២. ស្ថានភាពពេលកំពុងសរសេរមតកសាសន៍

ខ្ញុំសរសេរបណ្តាំមត៌កនេះ ក្នុងស្ថានភាពដែលខ្ញុំមានស្មារតី ល្អ ដឹងច្បាស់ពីអ្វីដែលខ្ញុំ កំពុងតែចាត់ចែង ហើយអ្វីដែលខ្ញុំសរសេរនៅក្នុងបណ្តាំមត៌កនេះ ជាគោលបំណងរបស់ខ្ញុំ នៅពេលដែលខ្ញុំទទួលមរណភាព ។

(ចំណុចនេះ បញ្ជាក់អំពីសមត្ថភាពរបស់ម្ចាស់បណ្តាំនាពេលធ្វើលិខិតបណ្តាំ)

មាត្រា១១៦៩

## ៣. បុគ្គលដែលត្រូវទទួលមត៌ក

អ្នកដែលត្រូវទទួលមត៌ករបស់ខ្ញុំ គឺ កូន... ........................(បញ្ជាក់អំពីអត្តសញ្ញាណរបស់ជនដែលត្រូវទទួលមត៌ក) ។

## ៤. បញ្ជាក់អំពីទំហំនៃទ្រព្យសម្បត្ត

ដីទី១ ដីទី២ ដីទី៣ ដីទី៤ (អត្តសញ្ញាណនៃដី) លុយ (លេខគណនី ឈ្មោះធនាគារ.....) គ្រឿងអលង្កា សិទ្ធិលើបំណុល (ថ្លៃឈ្នួល ភាគហ៊ុន...........) សុរបទាំងអស់ ....................បំណុល ..........................................................................។

## ៥. កំណត់អំពីចំណែកមត៌ក ឬ វិធីបែងចែកមត៌ក

ដីទី១ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យ កូន A

លុយចំនួន......កំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូន B

ធ្វើអច្ច័យទាន នូវគ្រឿងអលង្ការដែលមានកំណត់នៅក្នុងចំណុចទី៤ ឲ្យទៅកូន A

ភាគហ៊ុនដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនA ២០ ភាគរយចំនួន កូនB ២០ភាគរយ កូនC ៦០ភាគរយ ។

ដីទី២ ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនD ប្រសិនបើ D រៀបការ

(មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្អង់)

មាត្រា១១៩៤

## ៦. កំណត់អ្នកប្រតិបត្តិមតកសាសន៍

មេធាវី ..........................................ជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទទួលបានកម្រៃ .........................................។

## ៧. ផ្តាច់មត៌ក

កូន E មិនទទួលបានចំណែកមត៌ករបស់ខ្ញុំទេ ពីព្រោះ កូន ប្រមាថមើលងាយខ្ញុំ ធ្វើឲ្យខ្ញុំពិបាកចិត្តគ្រប់ពេល

(មាត្រា១១៥២)

## ៨. អច្ច័យទាន

ដីទី៣ ដែលមានកំណត់នៅក្នុងចំណុចទី៤ ខ្ញុំប្រគល់ឲ្យG ជាក្មួយរបស់ខ្ញុំ ប៉ុន្តែដីនោះ ត្រូវគ្រប់គ្រងដោយ ប្អូនស្រីរបស់ខ្ញុំ ..................រហូតដល់ ក្មួយរបស់ខ្ញុំមាននីតិភាព ។

(មាត្រា១១៨៤)

## ៩. ចំនួន ការរក្សាទុក បើក និងប្រកាសបណ្តាំមត៌ក

បណ្តាំមត៌កច្បាប់ដើម ធ្វើឡើងចំនួន១ ច្បាប់

បណ្តាំមត៌កច្បាប់ដើម រក្សាទុកនៅការិយាល័យមេធាវី....................

បណ្តាំមត៌កនេះ អាចបើកបាន ២ខែ ក្រោយពេលខ្ញុំទទួលមរណភាព

បណ្តាំមត៌កនេះ ត្រូវប្រកាស នៅផ្ទះរបស់ខ្ញុំ .....................................................................

## ១០. បណ្តាំចុងក្រោយរបស់ម្ចាស់បណ្តាំ

ឪពុកសង្ឃឹមថាកូនចេះស្រលាញ់គ្នា មិនធ្វើបាបគ្នា មិនយកទ្រព្យជាត្រីមុខ បំភ្លេចញាតិភាព ធ្វើឲ្យគ្រួសារក្លាយជាអព្វមង្គល ក្រោយពេលឪពុកស្លាប់។

អ្វីៗដែលឪពុកធ្វើគឺដើម្បីកូន ហើយសង្ឃឹមថាកូនៗ នឹងរស់នៅប្រកបដោយ សុភមង្គល និងបានប្រើប្រាស់ទ្រព្យនេះជាដើមទុន សម្រាប់ជីវភាពទៅអនាគត តាមការចាត់ចែងរបស់ម្ដាយកូន។

(មាត្រា១១៨៧)

**ម្ចាស់បណ្ដាំ**

**ហត្ថលេខារបស់ម្ចាស់បណ្ដាំ និងចុះកាលបរិច្ឆេទ**

មាត្រា១១៧៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតមរតកសាសន៍
# និងការប្រគល់សិទ្ធិឲ្យចាត់ចែងទ្រព្យបណ្ដោះអាសន្ន

**ម្ចាស់បណ្ដាំ និងជាអ្នកប្រគល់សិទ្ធិ**

- នាម-គោត្តនាម : **ម្ចាស់បណ្ដាំ** ភេទ៖ប្រុស ជនជាតិ៖ ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត : ០៧-០៥-១៩៣៧ មុខរបរ៖ ៣...
- ទីកន្លែងកំណើត : សង្កាត់ លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ : **អៀ ឡាំ** ម្ដាយឈ្មោះ៖ **ឡាំ**
- ស្ថានភាពគ្រួសារ : ពោះម៉ាយពីខ្មោចនាង **តាំង ស៊ីមទៀង** និងមានកូន០៧នាក់
- អត្តសញ្ញាណប័ណ្ណលេខ៖ ០១០៤២៦៨៨៣ (០១)
- សៀវភៅគ្រួសារលេខ៖០១.០២៥១៨២ ចុះថ្ងៃទី១៥-១០-២០១០
- ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**អ្នកទទួលអច្ច័យទាន និងជាអ្នកទទួលសិទ្ធិ**

- នាម-គោត្តនាម : **សន្តតិជន** ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត : ០១-០៦-១៩៦២ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត : សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ : **ម្ចាស់បណ្ដាំ** ម្ដាយឈ្មោះ៖ **តាំង ស៊ីមទៀង**(ស្លាប់)
- ស្ថានភាពគ្រួសារ : ប្រពន្ធឈ្មោះ **ជាសារី** កូន៣នាក់
- កំរិតវប្បធម៌៖ ថ្នាក់ទីបញ្ចប់
- កាន់អត្តសញ្ញាណប័ណ្ណ០១០៧១៨៧២៦(០១)
- ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី១៖**

- នាម-គោត្តនាម : **ជា ស៊ីថា** ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត : ០៧-១០-១៩៥២ មុខរបរ៖ ពាណិជ្ជករ
- ទីកន្លែងកំណើត : ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល
- ឪពុកឈ្មោះ : **ជា លី** ម្ដាយឈ្មោះ : **ឌុវ**
- ស្ថានភាពគ្រួសារ : ពោះម៉ាយ កំរិតវប្បធម៌៖ ថ្នារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០១៤៨០៤៨(០១)

- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៦អឺ០ ផ្លូវ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី២៖**

- នាម-គោត្តនាម ៖ **លាង ស្រីខួច** ភេទ៖ស្រី ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ១០/០៣/១៩៨១ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **លាង វ៉ាន់ផុន** ម្តាយឈ្មោះ ៖ **ឈៀង យ៉ុង**
- ស្ថានភាពគ្រួសារ ៖ មានគ្រួសារ កំរិតវប្បធម៌ ៖ បរិញ្ញាប័ត្រ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០៦៧៨២០៣(០១)
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៨ ផ្លូវលេខ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សាក្សីបានអះអាងថាមិនមែនជាញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ ។

**សារការីផ្តល់យថាភូតលើលិខិតមតកសាសន៍**

បណ្ឌិត ៖ **ជាសារការី និងជាប្រធានមន្ទីរសារការី ៖** មានអាសយដ្ឋាននៅ ផ្ទះលេខ ១៣៥ CD ផ្លូវ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។
ទូរស័ព្ទការិយាល័យ ៖ អ៊ីម៉ែល៖

**I-អត្ថន័យនៃបណ្តាំ និងការប្រគល់សិទ្ធិ**

ម្ចាស់បណ្តាំ និងជាអ្នកប្រគល់សិទ្ធិឲ្យគ្រប់គ្រងចាត់ចែងបណ្តោះអាសន្នរួមទាំងបំណុល និងពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ខ្លួន បានប្រកាសជាឱឡារិកជម្រាបជូន **សារការី** នូវទ្រព្យសម្បត្តិដែល ជាកម្មវត្ថុនៃបណ្តាំ និងការប្រគល់សិទ្ធិរបស់ខ្លួនរួមមាន៖

ទ្រព្យសម្បត្តិផ្ទាល់ខ្លួន

១ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

២ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ៖** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៣ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ៖** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៤ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ទទួលស្គាល់ដោយម.រ.ដ.ន.ស **រាជធានីភ្នំពេញ**

៥ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ដ.ន.ស រាជធានីភ្នំពេញ**

៦ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ដ.ន.ស រាជធានីភ្នំពេញ**

៧ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ដ.ន.ស រាជធានីភ្នំពេញ**

៨ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ដ.ន.ស រាជធានីភ្នំពេញ**

៩ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ដ.ន.ស រាជធានីភ្នំពេញ**

១០- **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ដ.ន.ស រាជធានីភ្នំពេញ**

១១- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ដោយ**ម.រ.ដ.ន.ស ខេត្តស្វាយរៀង**

១២- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ទទួលស្គាល់ដោយ**ម.រ.ដ.ន.ស ខេត្តកណ្ដាល**

១៣- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ៖

១៤- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ៖

១៥- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ របស់ឈ្មោះ ចុះថ្ងៃទី

ទទួលស្គាល់ដោយ៖

១៦- លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ របស់ឈ្មោះ

ចុះថ្ងៃទី ទទួលស្គាល់ដោយ៖

ទ្រព្យសម្បត្តិសហកម្មសិទ្ធិ

១ - ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

២ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៣ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៤ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

**ទ្រព្យសម្បត្តិជាក្រុមហ៊ុន**

**អាជីវកម្ម ក្រុមហ៊ុន**

ម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈជាចុងក្រោយនៅចំពោះមុខសារការីមានខ្លឹមសារ ច្បាស់លាស់ថា ម្ចាស់បណ្តាំបានសម្រេចចិត្តធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិជាកម្មសិទ្ធិ និងសហកម្មសិទ្ធិរបស់ខ្លួនដែលមានទំហំ ទីតាំង និងមានឯកសារសម្គាល់ដូចបានបញ្ជាក់ខាងលើនេះ ឲ្យទៅអ្នកទទួលអច្ច័យទានដូចមានអត្តសញ្ញាណខាងលើ ធ្វើជាម្ចាស់កម្មសិទ្ធិ កាន់កាប់ទ្រព្យរបស់ខ្លួនបន្តបន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព ។ ដោយឡែកចំពោះស្ថានភាពបច្ចុប្បន្នម្ចាស់បណ្តាំស្ថិតនៅក្នុងស្ថានភាពសុខភាពពុំល្អ ហេតុនេះបានសម្រេចចិត្តប្រគល់សិទ្ធិឲ្យអ្នកទទួលអច្ច័យទាន មានសិទ្ធិគ្រប់គ្រងលើអាជីវកម្មក្រុមហ៊ុន ដោះស្រាយបំណុលរបស់ក្រុមហ៊ុន និងចាត់ចែងលើទ្រព្យសម្បត្តិដើម្បីឲ្យក្រុមហ៊ុនដំណើរការបានល្អ ។ ក្រៅពីនេះម្ចាស់បណ្តាំបានអះអាងថាខ្លួនមានកូនចំនួន ដែលតាមច្បាប់មានសិទ្ធិទទួលមរតកពីខ្លួន ក៏ប៉ុន្តែខ្លួនបានសម្រេចចិត្តមិនធ្វើការបែងចែកបណ្តាំតាមច្បាប់ទេ គឺបែងចែកបណ្តាំតាមឆន្ទៈរបស់ខ្លួនដោយមានមូលហេតុថា កូនទាំង ផ្សេងទៀតមិនព្រមមកជួយការងាររបស់ម្ចាស់បណ្តាំនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការងាររបស់ខ្លួនមានតែអ្នកទទួលអច្ច័យទានម្នាក់នេះប៉ុណ្ណោះ ដែលបានបំពេញការងារ ជួយដល់ម្ចាស់បណ្តាំ លើគ្រប់កិច្ចការទាំងអស់ ។

៣ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៤ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

**ទ្រព្យសម្បត្តិជាក្រុមហ៊ុន**

**អាជីវកម្ម ក្រុមហ៊ុន**

ម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈជាចុងក្រោយនៅចំពោះមុខសាក្សីមានខ្លឹមសារ ច្បាស់លាស់ថា ម្ចាស់បណ្តាំបានសម្រេចចិត្តធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិជាកម្មសិទ្ធិ និងសហកម្មសិទ្ធិរបស់ខ្លួនដែលមានទំហំ ទីតាំង និងមានឯកសារសម្គាល់ដូចបានបញ្ជាក់ខាងលើនេះ ឲ្យទៅអ្នកទទួលអច្ច័យទានដូចមានអត្តសញ្ញាណខាងលើ ធ្វើជាម្ចាស់កម្មសិទ្ធិ កាន់កាប់ទ្រព្យរបស់ខ្លួនបន្តបន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព ។ ដោយឡែកចំពោះស្ថានភាពបច្ចុប្បន្នម្ចាស់បណ្តាំស្ថិតនៅក្នុងស្ថានភាពសុខភាពពុំល្អ ហេតុនេះបានសម្រេចចិត្តប្រគល់សិទ្ធិឲ្យអ្នកទទួលអច្ច័យទាន មានសិទ្ធិគ្រប់គ្រងលើអាជីវកម្មក្រុមហ៊ុន ដោះស្រាយបំណុលរបស់ក្រុមហ៊ុន និងចាត់ចែងលើទ្រព្យសម្បត្តិដើម្បីឲ្យក្រុមហ៊ុនដំណើរការបានល្អ ។ ក្រៅពីនេះម្ចាស់បណ្តាំបានអះអាងថាខ្លួនមានកូនចំនួន៧នាក់ ដែលតាមច្បាប់មានសិទ្ធិទទួលមរតកពីខ្លួន ក៏ប៉ុន្តែខ្លួនបានសម្រេចចិត្តមិនធ្វើការបែងចែកបណ្តាំតាមច្បាប់ទេ គឺបែងចែកបណ្តាំតាមឆន្ទៈរបស់ខ្លួនដោយមានមូលហេតុថា កូន នាក់ផ្សេងទៀតមិនព្រមមកជួយការងាររបស់ម្ចាស់បណ្តាំនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការងាររបស់ខ្លួនមានតែអ្នកទទួលអច្ច័យទានម្នាក់នេះប៉ុណ្ណោះ ដែលបានបំពេញការងារ ជួយដល់ម្ចាស់បណ្តាំ លើគ្រប់កិច្ចការទាំងអស់ ។

ការអនុវត្តលិខិតបន្តកសាសន៍នេះ នឹងត្រូវធ្វើឡើងដោយ **មន្ទីរសារការី** តាមនីតិវិធីច្បាប់ ដើម្បីឲ្យអច្ច័យទានទាំងអស់តាមម្ចាស់បណ្ដាំទៅអ្នកទទួលអច្ច័យទាន ដោយពេញលេញ និងស្របតាមច្បាប់ ។

ម្ចាស់បណ្ដាំបានយល់ព្រមផ្តិតមេដៃលើលិខិតបន្តកសាសន៍នេះ មុកជាភស្តុតាងតាមច្បាប់ នៅចំពោះមុខសារការី ។

**II-សេចក្តីអះអាងរបស់សាក្សី**

សាក្សីទាំងពីររូបមានអត្តសញ្ញាណដូចខាងលើ ដែលបានយល់ព្រមធ្វើជាសាក្សីក្នុងលិខិតបន្តកសាសន៍ បានអះអាងដោយប្រាកដថា សាក្សីមិនមានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់ជាមួយនឹងម្ចាស់បណ្ដាំឡើយ ហើយយល់ព្រមផ្តល់ចម្លើយជាសាក្សីជូនសមត្ថកិច្ចពាក់ព័ន្ធនៅពេលដែលអនុវត្តខ្លឹមសារ នៃលិខិតបន្តកសាសន៍នេះថាម្ចាស់បណ្ដាំពិតជាបានធ្វើបណ្ដាំដោយស្ម័គ្រចិត្ត ដោយមានសមត្ថភាពពេញបរិបូរណ៍ ដោយមានសាក្សីដែលជារូបខ្លួនបានចូលរួមដឹងឮដោយផ្ទាល់ប្រាកដមែន។

**III-អ្នកទទួលអច្ច័យទាន**

អ្នកទទួលអច្ច័យទានដែលត្រូវជាកូនបង្កើតជាមួយម្ចាស់បណ្ដាំ បានចូលរួម ការធ្វើបណ្ដាំនេះ នៅចំពោះមុខសារការី ហើយក៏បានយល់ព្រមផ្តិតមេដៃ និងទទួលយកនូវអច្ច័យទានជាអចលនទ្រព្យខាងលើ រួមទាំងទទួលសិទ្ធិដោះស្រាយ និងចាត់ចែងអាជីវកម្មក្រុមហ៊ុន និងដោះស្រាយបញ្ហាបំណុល រួមទាំងការចាត់ចែងលើទ្រព្យជាបណ្ដោះអាសន្នក្នុងពេលបច្ចុប្បន្នតាមខ្លឹមសារ នៃលិខិតបន្តកសាសន៍នេះដោយពេញចិត្តពីម្ចាស់បណ្ដាំ ។

**IV-ការរៀបចំ និងការផ្តិតមេដៃលើលិខិតបន្តកសាសន៍**

លិខិតបន្តកសាសន៍នេះ ត្រូវបានរៀបចំឡើងដោយ**មន្ទីរសារការី** ក្រោមការទទួលខុសត្រូវរបស់ លោក ជាសារការី អមដោយលោក ជាលេខាធិការកត់ត្រា និងវាយអក្សរ នៃបណ្ដាំនេះ ។ លិខិតនេះ មានចំនួន ០៣ច្បាប់ ជាច្បាប់ដើម ធ្វើឡើងជាភាសាខ្មែរ និងត្រូវបានផ្តល់ជូនម្ចាស់បណ្ដាំ ចំនួន ០១ច្បាប់ អ្នកទទួលអច្ច័យទានចំនួន ០១ច្បាប់ និងរក្សាទុកនៅ មន្ទីរសារការី លុច ស៊ីអេចឌី ចំនួន ០១ច្បាប់ សម្រាប់ប្រើប្រាស់តាមច្បាប់តទៅ ។

លិខិតបន្តកសាសន៍នេះ បន្ទាប់ពីរៀបចំ និងកែសម្រួលខ្លឹមសារច្បាស់លាស់រួច សារការីបានអានឲ្យម្ចាស់បណ្ដាំ អ្នកទទួលអច្ច័យទាន និងសាក្សី ស្ដាប់ និងអ្នកទាំង អស់គ្នាបានឆ្លើយតបមកវិញ នៅចំពោះមុខសារការីថា ខ្លឹមសារនៃលិខិតបន្តកសាសន៍ នេះពិតជាត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនទាំងស្រុង ហើយយល់ព្រមផ្តិតមេដៃលើលិខិតបន្តកសាសន៍នេះ នៅចំពោះមុខសារការី និងបានសរសេរឈ្មោះរបស់ខ្លួន រៀងខ្លួនៗ នៅលើលិខិតបន្តកសាសន៍នេះ ដោយសារការីបានចុះថ្ងៃខែឆ្នាំចំណាំតទៅ ។

ការអនុវត្តលិខិតមតកសាសន៍នេះ នឹងត្រូវធ្វើឡើងដោយ **មន្ទីរសារការី** តាមនីតិវិធីច្បាប់ ដើម្បីឲ្យអច្ច័យទានទាំងអស់តាមម្ចាស់បណ្តាំទៅអ្នកទទួលអច្ច័យទាន ដោយពេញលេញ និងស្របតាមច្បាប់ ។

ម្ចាស់បណ្តាំបានយល់ព្រមផ្តិតមេដៃលើលិខិតមតកសាសន៍នេះ មុកជាភស្តុតាងតាមច្បាប់ នៅចំពោះមុខសារការី ។

**II-សេចក្តីអះអាងរបស់សាក្សី**

សាក្សីទាំងពីររូបមានអត្តសញ្ញាណដូចខាងលើ ដែលបានយល់ព្រមធ្វើជាសាក្សីក្នុងលិខិតមតកសាសន៍ បានអះអាងដោយប្រាកដថា សាក្សីមិនមានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់ជាមួយនឹងម្ចាស់បណ្តាំឡើយ ហើយយល់ព្រមផ្តល់ចម្លើយជាសាក្សីជូនសមត្ថកិច្ចពាក់ព័ន្ធនៅពេលដែលអនុវត្តខ្លឹមសារ នៃលិខិតមតកសាសន៍នេះថាម្ចាស់បណ្តាំពិតជាបានធ្វើបណ្តាំដោយស្ម័គ្រចិត្ត ដោយមានសមត្ថភាពពេញបរិបូរណ៍ ដោយមានសាក្សីដែលជារូបខ្លួនបានចូលរួមដឹងឮដោយផ្ទាល់ប្រាកដមែន។

**III-អ្នកទទួលអច្ច័យទាន**

អ្នកទទួលអច្ច័យទានដែលត្រូវជាកូនបង្កើតជាមួយម្ចាស់បណ្តាំ បានចូលរួម ការធ្វើបណ្តាំនេះ នៅចំពោះមុខសារការី ហើយក៏បានយល់ព្រមផ្តិតមេដៃ និងទទួលយកនូវអច្ច័យទានជាអចលនទ្រព្យខាងលើ រួមទាំងទទួលសិទ្ធិដោះស្រាយ និងចាត់ចែងអាជីវកម្មក្រុមហ៊ុន និងដោះស្រាយបញ្ហាបំណុល រួមទាំងការចាត់ចែងលើទ្រព្យជាបណ្តោះអាសន្នក្នុងពេលបច្ចុប្បន្នតាមខ្លឹមសារ នៃលិខិតមតកសាសន៍នេះដោយពេញចិត្តពីម្ចាស់បណ្តាំ ។

**IV-ការរៀបចំ និងការផ្តិតមេដៃលើលិខិតមតកសាសន៍**

លិខិតមតកសាសន៍នេះ ត្រូវបានរៀបចំឡើងដោយ**មន្ទីរសារការី** ក្រោមការទទួលខុសត្រូវរបស់ លោក ជាសារការី អមដោយលោក ជាលេខាធិការកត់ត្រា និងវាយអក្សរ នៃបណ្តាំនេះ ។ លិខិតនេះ មានចំនួន ០៣ច្បាប់ ជាច្បាប់ដើម ធ្វើឡើងជាភាសាខ្មែរ និងត្រូវបានផ្តល់ជូនម្ចាស់បណ្តាំ ចំនួន ០១ច្បាប់ អ្នកទទួលអច្ច័យទានចំនួន ០១ច្បាប់ និងរក្សាទុកនៅ មន្ទីរសារការី លុច ស៊ីអេចឌី ចំនួន ០១ច្បាប់ សម្រាប់ប្រើប្រាស់តាមច្បាប់តទៅ ។

លិខិតមតកសាសន៍នេះ បន្ទាប់ពីរៀបចំ និងកែសម្រួលខ្លឹមសារច្បាស់លាស់រួច សារការីបានអានឲ្យម្ចាស់បណ្តាំ អ្នកទទួលអច្ច័យទាន និងសាក្សី ស្តាប់ និងអ្នកទាំង អស់គ្នាបានឆ្លើយតបមកវិញ នៅចំពោះមុខសារការីថា ខ្លឹមសារនៃលិខិតមតកសាសន៍ នេះពិតជាត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនទាំងស្រុង ហើយយល់ព្រមផ្តិតមេដៃលើលិខិតមតកសាសន៍នេះ នៅចំពោះមុខសារការី និងបានសរសេរឈ្មោះរបស់ខ្លួន រៀងខ្លួនៗ នៅលើលិខិតមតកសាសន៍នេះ ដោយសារការីបានចុះថ្ងៃខែឆ្នាំចំណាំតទៅ ។





ស្នាមមេដៃស្តាំអ្នកធ្វើបណ្តាំ



ស្នាមមេដៃស្តាំអ្នកទទួលអច្ច័យទាន



**ឈ្មោះ ម្ចាស់បណ្តាំ**

**អច្ច័យលាភី**

ស្នាមមេដៃស្តាំសាក្សីទី ១



ស្នាមមេដៃស្តាំសាក្សីទី២



លិខិតមរតកសាសន៍នេះ ត្រូវបានពិនិត្យ និងធ្វើការបញ្ជាក់
ជាលិខិតយថាភូតដោយចុះបញ្ជី

**លេខ**
**នៅមន្ទីរសារការី**
ក្រោមការទទួលខុសត្រូវរបស់
**សារការី**

មានខ្លឹមសារបញ្ជាក់ដូចតទៅ ៖

១. សារការីបានពិនិត្យឯកសារច្បាប់ដើមរួមមាន៖
- អត្តសញ្ញាណប័ណ្ណឈ្មោះ: ម្ចាស់បណ្តាំ
- អត្តសញ្ញាណប័ណ្ណឈ្មោះ: អច្ច័យលាភី
- អត្តសញ្ញាណប័ណ្ណឈ្មោះ: សាក្សីទី១
- អត្តសញ្ញាណប័ណ្ណឈ្មោះ: សាក្សីទី២
- សៀវភៅស្នាក់នៅរបស់ឈ្មោះ: ម្ចាស់បណ្តាំ

ប័ណ្ណកម្មសិទ្ធិជាកម្មវត្ថុ នៃមរតកសាសន៍នេះ

២. សារការីធ្វើការកត់សម្គាល់បញ្ជាក់ឆន្ទៈរបស់ភាគីពាក់ព័ន្ធថា៖

ម្ចាស់បណ្តាំឈ្មោះ: ម្ចាស់បណ្តាំ និងអ្នកទទួលអច្ច័យទានឈ្មោះ: អច្ច័យលាភី រួមទាំងសាក្សីទាំងពីរនាក់ពិតជាបានយល់ព្រមដោយស្ម័គ្រចិត្តផ្តិតមេដៃលើលិខិតមរតកសាសន៍នេះ ទុកជាចំណាំតាមច្បាប់ តាមឆន្ទៈរៀងខ្លួន នៅចំពោះ មុខសារការី។

៣. **អត្ថបទច្បាប់**

សារការីបានបង្កើតលិខិតមរតកសាសន៍នេះ ដោយផ្អែកតាមមាត្រា ១១៦៩ មាត្រា ១១៧០ មាត្រា ១១៧១ មាត្រា១១៧២ មាត្រា ១១៧៣ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៤. **មន្ទីរសារការី** ទទួលអនុវត្តលិខិតមតកសាសន៍នេះ តាមសំណើរបស់ ម្ចាស់បណ្តាំ និងរបស់អ្នកទទួលអច្ច័យទាន តាមនីតិវិធី និងច្បាប់ ។

៥. ការបង្កើតលិខិតមរតកសាសន៍នេះ អនុឡោមតាមអនុក្រឹត្យលេខ (**អនុក្រឹត ទទួលស្គាល់មន្ទីស** របស់រាជរដ្ឋាភិបាលកម្ពុជា ។

លិខិតមតកសាសន៍នេះមានសុពលភាពអនុវត្ត

ចាប់ពីថ្ងៃ ខែ ឆ្នាំ សំរឹទ្ធិស័ក ព.ស ២៥៦២

ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ

**មន្ទីសារការី** (នាមករណ៍)

**សា រ កា រី**

(ហត្ថលេខា និងត្រា)

(ឈ្មោះ សារការី)